ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរកការពិត



◆ ការបង្រៀនអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ

◆ រស់ ផាត អតីតលេខាស្រុកសេរីសោភ័ណ្ឌ

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ១៦៤ ខែសីហា ឆ្នាំ២០១៣

# ស្វែងរកការពិត

លេខ១៦៤ ខែសីហា ឆ្នាំ២០១៣

## ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

## មាតិកា

◆ ការបង្រៀនអំពីប្រវត្តិសាស្ត្រកម្ពុជា ........................................ ១

**ផ្នែកឯកសារ**

◆ ចម្លើយ ជួរ ច័ន្ទ សារិ ហៅ ជិន ហួរ ........................................ ២

◆ កម្ចាត់កម្មសិទ្ធិសួនតួឲ្យជ្រះស្រឡះ ........................................ ៥

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

◆ ចិន និងរបបខ្មែរក្រហម ........................................ ៩

◆ រស់ ផាត អតីតលេខាស្រុក ........................................ ១៩

◆ សុខចិត្តយកប្ដីដើម្បីគេចពីការសម្លាប់ ........................................ ២០

◆ អាយុប្រាំឆ្នាំនៅថ្ងៃ១៧មេសា ........................................ ២២

◆ ជនជាតិកាវ៉ែត និងជីវភាពរស់នៅ ........................................ ២៤

◆ ហេតុអ្វីខ្មែរក្រហមជម្លៀសប្រជាជនចេញពី ........................................ ២៧

**ផ្នែកច្បាប់**

◆ កម្មវិធីវិទ្យុសហគមន៍របស់មជ្ឈមណ្ឌល ........................................ ៣២

**វេទិកាពិភាក្សាសាធារណៈ**

◆ ការបោះឆ្នោត និងសាលាក្ដីខ្មែរក្រហម ........................................ ៣៧

◆ ពាក្យបចាមអារ៉ាម និងការពុតគេថា ........................................ ៣៨

◆ ជនជាប់ចោទ នួន ជា ប្រឆាំងទៅនឹងការបំបែក ........................................ ៤១

◆ ប្រវត្តិសាស្ត្រខ្មែរក្រហមក្រោមសម្ពាធនយោបាយ ........................................ ៤៤

**ទំព័រស្រាវជ្រាវរកគ្រួសារ**

◆ ទណ្ឌិតផ្លែល្ពៅ ........................................ ៤៨

◆ ជីតាខ្ញុំរៀបរាប់ប្រាប់ ........................................ ៥៦

◆ បទពិសោធន៍ពុកម៉ែធ្វើឲ្យខ្ញុំរៀនប្រវត្តិ ........................................ ៥៩

◆ ហូបមិនគ្រប់ ម្ដាយខ្ញុំធ្លាក់ខ្លួនឈឺ ........................................ ៦០



វគ្គបណ្ដុះបណ្ដាលគ្រូបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ នៅខេត្តតាកែវ ពីថ្ងៃទី១៧ ដល់២២ ខែសីហា ឆ្នាំ២០១៣

**រក្សាសិទ្ធិ**

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ

ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា

ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មាន

លេខ០២៩១ពម.៩៩

ចុះថ្ងៃទី២ ខែសីហាឆ្នាំ១៩៩៩

រូបថតឯកសារៈមជ្ឈមណ្ឌលឯកសារកម្ពុជា

និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

***ស្នេរលេខនេះ*** ***:*** *ចន ឆរឆើអារី, ឡុង ដានី, អ៊ុន សុដាវី, ចាន ប្រាថ្នា, រ៉េនឌល ឌីហ្វាល់កូ, ម៉ែន ពិចិត្រ, លន់ ដាលីន, អាន ហាញឌល, សៃមិន ក្រុស័រ, ឌី ខាំបូលី, លី សុខឃាង, ឆាយ ស៊ូឆាត្រ, រ៉េត ណៃហ៊ីរ, កោ សែប* ***អ្នកនិពន្ធនិងស្រាវជ្រាវ :*** *ទាវ សារៈមុនិន្ទ, ស៊ិន សុធីតា* ***អ្នកបកប្រែ :*** *នង ច័ន្ទមល្លិកា និង ភួង ច័ន្ទប្រណិត* ***និពន្ធនាយកទូទៅ :*** *ឆាំង យុ និង ញាណ សុជាតិ* ***ជំនួយការនិពន្ធនាយក :*** *សោម ប៊ុនថន* ***ក្រាហ្វិកកុំព្យូទ័រ :*** *សោម ប៊ុនថន* ***គ្រប់គ្រងការចែកផ្សាយ :*** *ឆេង វ៉េង*

Email: dccam@online.com.kh, Homepage: www.dccam.org, www.cambodiatribunal.org, www.cambodiasri.org

# ការបង្រៀនអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ

មជ្ឈមណ្ឌលឯកសារកម្ពុជា មានបេសកកម្មជំរុញឲ្យមានការអប់រំអំពីប្រវត្តិសាស្ត្រនៃអំពើប្រល័យពូជសាសន៍នៅកម្ពុជា និងផលប៉ះពាល់នៃអំពើនេះមកលើជីវិតរស់នៅរបស់ប្រជាជនកម្ពុជានាពេលបច្ចុប្បន្ន ។ គម្រោង "សិក្សាអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ" របស់មជ្ឈមណ្ឌលឯកសារកម្ពុជាត្រូវបានរៀបចំឡើង ដើម្បីជំរុញឲ្យមានការផ្សះផ្សាជាតិ យុត្តិធម៌ ការបង្រួបបង្រួមជាតិ និងលទ្ធិប្រជាធិបតេយ្យនៅកម្ពុជា ។ ក្រោមគម្រោងនេះ មជ្ឈមណ្ឌលឯកសារកម្ពុជាបានបោះពុម្ពសៀវភៅ "ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ១៩៧៥-១៩៧៩" សម្រាប់ការប្រើប្រាស់នៅតាមអនុវិទ្យាល័យ និងវិទ្យាល័យទាំងអស់នៅទូទាំងប្រទេស ។ មកទល់ពេលនេះ មជ្ឈមណ្ឌលឯកសារកម្ពុជា បានផ្តល់ការបណ្តុះបណ្តាលដល់គ្រូបង្រៀនអនុវិទ្យាល័យ និងវិទ្យាល័យជាងបីពាន់រូប អំពីរបៀបបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ដែលជាផ្នែកមួយនៃគម្រោងអប់រំពីអំពើប្រល័យពូជសាសន៍ ។ ក្នុងឆ្នាំ២០១៣ មជ្ឈមណ្ឌលឯកសារកម្ពុជា បានបន្តផ្តល់ការបណ្តុះបណ្តាលដល់គ្រូប្រវត្តិវិទ្យា-ភូមិវិទ្យា អក្សរសាស្ត្រខ្មែរ និងសីលធម៌-ពលរដ្ឋ មកពីខេត្តតាកែវ កំពត កំពង់ចាម ក្រចេះ កំពង់ធំ និង ខេត្តសៀមរាប ។ ខ្ញុំជឿជាក់ថា មានតែការរៀនសូត្រអំពីប្រវត្តិសាស្ត្រប៉ុណ្ណោះ ដែលអាចឲ្យយើងផ្សាភ្ជាប់ឡើងវិញនូវបំណែកជាច្រើននៃសង្គមបាក់បែករបស់យើងបាន ។

**ឆាំង យុ**



វគ្គបណ្តុះបណ្តាលគ្រូបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ នៅខេត្តតាកែវ ពីថ្ងៃទី១៧ ដល់២២ ខែសីហា ឆ្នាំ២០១៣

# ចម្លើយ ជួរ ច័ន្ទ សារិ ហៅ ជិន ហួរ (និស្សិតពេទ្យ) អំពីប្រវត្តិសកម្មភាពក្បត់

***ដកស្រង់ចេញពីឯកសារចម្លើយសារភាព J០០៨៥៥***

*ជួរ ច័ន្ទ សារិ ជានិស្សិតពេទ្យឆ្នាំទីមួយនៅទីក្រុងភ្នំពេញក្នុងឆ្នាំ១៩៧៤ ។ សារិ ត្រូវបានចាប់ខ្លួននៅខែមិថុនា ឆ្នាំ១៩៧៧ នៅសហករណ៍បន្ទាត់បោះ ឃុំទានកម្ម ស្រុកព្រះនេត្រព្រះ តំបន់៥ ភូមិភាគពាយ័ព្យ ។ ខាងក្រោមគឺជាការដកស្រង់ចេញពីសារភាពរបស់ ជួរ ច័ន្ទ សារិ ដែលមានរៀបរាប់ដូចតទៅនេះ ។*

*ខ្ញុំបាទឈ្មោះ ជួរ ច័ន្ទ សារិ ហៅ ជិន ហួរ អាយុ២៣ឆ្នាំ កើតនៅភូមិអង្គស្នួល ឃុំពើក ស្រុកអង្គស្នួល ខេត្តកណ្តាល ជានិស្សិតឆ្នាំទីមួយនៃមហាវិទ្យាល័យឱសថសាស្ត្រ ភ្នំពេញ ។*

*នៅឆ្នាំ១៩៦៤ ខ្ញុំបានចូលរៀននៅថ្នាក់ទី៩ សាលាអង្គស្នួល ហើយនៅឆ្នាំ១៩៦៦ ខ្ញុំបានប្រលងជាប់ថ្នាក់ទី៦ នៃអនុវិទ្យាល័យបែកចាន ។*

*នៅឆ្នាំ១៩៦៩ ខ្ញុំបានចូលរៀនបន្តនៅថ្នាក់ទី៣ ហើយដោយសារខ្ញុំរៀនពូកែ សាស្ត្រាចារ្យ អាំ ជួន ក៏ឲ្យសៀវភៅវប្បធម៌ និងអរិយធម៌លោកសេរីមួយក្បាលមកខ្ញុំ ។ នៅឆ្នាំនោះ អាំ ជួន បានណែនាំខ្ញុំឲ្យស្គាល់ ប៉ោ អស្សារិទ្ធ អតីតចាងហ្វាងការសែត រាស្ត្រសប្ចុះ ហើយ អស្សារិទ្ធ បានរៀបចំ និងទទួលស្គាល់ខ្ញុំជាភ្នាក់ងារសេ.អ៊ី.អា ។*

*នៅឆ្នាំ១៩៧០ ខ្ញុំបានប្រលងឌីប្លូមជាប់ និងបានមករៀននៅថ្នាក់ទី២ នៃសាលាយុគន្ធរ ដែលមានសាស្ត្រាចារ្យ អាំ ជួន បង្រៀននៅទីនោះដែរ ។ នៅឆ្នាំ១៩៧១ ខ្ញុំបានស្គាល់សាស្ត្រាចារ្យ ជុំ ណារិទ្ធ ដែលបង្រៀននៅសាលានោះទៀត ហើយគាត់ក៏បានណែនាំខ្ញុំបន្តឲ្យស្គាល់ អ៊ុង ទី ប្រធានសិស្សសាលាប្រុវីជង្ស ។*

*នៅឆ្នាំ១៩៧៣ ខ្ញុំបានប្រលងជាប់បាក់អង់ និងបានមក*



គិលានដ្ឋានដែលខ្មែរក្រហមបោះបង់ចោលក្នុងអំឡុងពេលដែលខ្លួនកាន់អំណាចពីឆ្នាំ១៩៧៥ - ១៩៧៩

រៀនថ្នាក់ទីបញ្ចប់នៅសាលាស៊ីសុវត្ថិវិញ ដែលនៅទីនោះ អ៊ុង ទី ណែនាំឲ្យខ្ញុំស្គាល់ឈ្មោះ គុយ ចាន់វុទ្ធី (សិស្សថ្នាក់ទីបញ្ចប់) ។ នៅឆ្នាំដដែល អ៊ុង ទី បានចាត់តាំងខ្ញុំឲ្យដើរចងបដាជាមួយ គុយ ចាន់វុទ្ធី បែកត្រាក់ ខិត្តប័ណ្ណ តាមផ្ទះជិតខ្ញុំ និងផ្លូវសាធារណៈដែលក្នុងត្រាក់នោះមានន័យថា ៈ

- ◆ អង្គការខ្មែរក្រហមសម្លាប់កូនសិស្សខ្មែរ
- ◆ ខ្មែរក្រហមសម្លាប់ប្រជាជន និងវះពោះស្ត្រីមានផ្ទៃពោះ
- ◆ អង្គការខ្មែរក្រហមជាទមិឡឥតសាសនា

នៅឆ្នាំ១៩៧៣ដដែល អ៊ុង ទី បានណែនាំខ្ញុំឲ្យស្គាល់ កាំង ហេង បើកហាងក្រណាត់ និង ញឹក ឌឹម ទៀត ។ រហូតដល់ពាក់កណ្ដាលឆ្នាំ១៩៧៣ កាំង ហេង និង ញឹក ឌឹម បានចាត់តាំងខ្ញុំឲ្យដើររកមនុស្សដែលមានវោហារ និងចង់បានប្រាក់ខែច្រើនធ្វើការ ។ ដូច្នេះ ខ្ញុំក៏ទៅអប់រំឈ្មោះ ហៃ បើកឡានឲ្យក្រសួងអាកាសចរណ៍ ដែលមានផ្ទះនៅអង្គស្នួលមកជួប ញឹក ឌឹម ។ ពេលនោះ ខ្ញុំក៏បានចេញចូលអង្គស្នួលញឹកញាប់ដើម្បីយកការណ៍ពីប្រពន្ធរបស់ ហៃ និងដើម្បីរកមនុស្សដែលចេញពីតំបន់រំដោះមកទិញអីវ៉ាន់នៅផ្សារអង្គស្នួលដើម្បីផាយទាក់ទងឲ្យចូល សេ.អ៊ី.អា ។

នៅឆ្នាំ១៩៧៣ អង្គការបានវាយរំដោះទីប្រជុំជនអង្គស្នួល និងបានជម្លៀសគ្រួសារខ្ញុំ និងគ្រួសារ ហៃ ដោយមិនដឹងថាទៅទីណានោះទេ ។

នៅឆ្នាំ១៩៧៤ ខ្ញុំបានចូលរៀននៅមហាវិទ្យាល័យឱសថសាស្ត្រឆ្នាំទី១ ហើយរហូតមកដល់ដើមឆ្នាំ១៩៧៥ ទើបខ្ញុំទទួលដំណឹងតាមរយៈ កាំង ហេង និង ញឹក ឌឹម ថា គ្រួសារខ្ញុំជម្លៀសទៅស្រុក៥៤ តំបន់៣៣ ភូមិភាគនិរតី ។

នៅខែកុម្ភៈ ឆ្នាំដដែល កាំង ហេង និង ញឹក ឌឹម បានចាត់តាំងឲ្យខ្ញុំចូលទៅតំបន់រំដោះមុន ដើម្បីស៊ើបរក ៈ

១) ឈ្មោះរបស់អង្គការដែលគ្រប់គ្រងភូមិរំដោះ

២) កន្លែងទុកអង្ករ

៣) កម្លាំងយោធា និងឃ្លាំងអាវុធ ។

ដំបូង ខ្ញុំបានទៅជួបឈ្មោះ ព្រំ កងឈ្លបពិសេសរបស់អង្គការក្នុងស្រុកសំរោង តំបន់៣៣ នៅស្ពានកន្ទួត រួចហើយ ព្រំ ក៏ជូនបន្តទៅជួប ហៃ ។ ក្រោយមក ហៃ ក៏បានជូនខ្ញុំទៅជួបគ្រួសារនៅភូមិតាខ្វយ ឃុំដើងគួន ស្រុកសំរោង តំបន់៣៣ និងបាននាំខ្ញុំទៅបង្ហាញខ្លួនដល់ តាប៊ូ គ្រូសង្គមកិច្ចដោយប្រាប់ថា ជាក្មួយបង្កើតរបស់គាត់ (ហៃ) ។

បន្ទាប់ពីរស់នៅតំបន់រំដោះបានមួយខែកន្លះ អង្គការបានចាត់តាំងខ្ញុំ, តាប៊ូ និង ឡោ ឲ្យធ្វើទូក ដោយពេលនោះ ខ្ញុំបានកាត់ឈើឲ្យខ្ទិៗខូចអស់ជាច្រើនកំណាត់ ។ ចំណែកនៅឱកាសលើកភ្លឺស្រែខែមិថុនា ឆ្នាំ១៩៧៥ ខ្ញុំបានស្រែកទៅប្រធានកងថា «លើកភ្លឺស្រែធំៗធ្វើអ្វី ព្រោះគ្មានទឹកត្រឹមទ្រូងទេ បើស្រុកក្ររហេមរហាមទឹកយ៉ាងនេះ រកទឹកហូរហៀរឯណាបាន» ។ ក្រោយមកទៀត ខ្ញុំបានបំផុសប្រជាជនថ្មី ដោយ ៈ ១) មិនឲ្យដាំដំណាំផ្សេងៗ ២) បើដាំក៏មិនបានស៊ីខ្លួនឯង គឺអង្គការបញ្ជូនទៅសមរភូមិមុខទាំងអស់ ៣) នាំបងប្អូនរុះរើជញ្ជាំងផ្ទះធ្វើជាខសដុត ។

នៅខែកក្កដា ឆ្នាំ១៩៧៥ ពេលរដូវស្ទូង ខ្ញុំបានណែនាំបងប្អូនឲ្យធ្វើការបំផ្លាញសំណាប និងសន្ទូងព្រោះយើងមិនដឹងអង្គការជម្លៀសទៅទីណាទេ ។ ចំណែកពេលភ្ជួរ ខ្ញុំក្រោកឡើងពេលថ្ងៃរះ និងភ្ជួរឈប់ៗ ព្រមទាំងលែងគោឲ្យស៊ីសំណាបទៀត ។ ពេលនោះប្រធានកងបានចុះមកណែនាំឲ្យភ្ជួរលឿន តែខ្ញុំបានតបទៅវិញថា «ឲ្យភ្ជួរលឿនលុះត្រាតែយកបាយមកឲ្យស៊ីឆ្អែតទើបមានកម្លាំង» ។ ក្រៅពីនោះ អង្គការបានណែនាំបងប្អូនឲ្យជញ្ជូនជីលាមកទៅចាក់ស្រែ ខ្ញុំបានប្រឆាំងដោយយកជីទៅចាក់ចោលអស់មួយគំនរ និងបាននិយាយបំផុសប្រជាជនថា «តាំងពីដូនតាមកគេមិនដែលយកអាចម៍ទូលលើក្បាលទេ» ។

នៅចុងឆ្នាំ១៩៧៥ អង្គការបានជម្លៀសខ្ញុំឲ្យមករស់នៅក្នុងសហករណ៍បន្ទាត់បោះ ឃុំទានកម្ម ស្រុកព្រះនេត្រព្រះ តំបន់៥ ហើយមកដល់ដើមឆ្នាំ១៩៧៦ អង្គការក៏បានចាត់តាំងប្រជាជនឲ្យចុះច្រូត ពេលនោះខ្ញុំបានច្រូតបំផ្លាញ និងដើរកាត់គុម្ពស្រូវធ្វើឲ្យជ្រុះគ្រាប់ស្រូវជាច្រើន ។

នៅដើមឆ្នាំដដែលខ្ញុំបានជួប អឿង គណៈសង្កាត់ទានកម្ម ពេលដែលគាត់មកសួរពីប្រវត្តិរូបសិស្សក្នុងសហករណ៍បន្ទាត់បោះ ។ ក្រោយពេលស្គាល់គ្នា អឿង ក៏បានណែនាំខ្ញុំឲ្យជួយរកម៉ាញ៉េមួយគ្រឿងយកទៅឲ្យគាត់ដើម្បីប្រើប្រាស់ រួចហើយគាត់ក៏បានចាត់តាំងខ្ញុំឲ្យធ្វើជាជំនួយស្ថិតិ ។ តមកទៀតគាត់ក៏បានតែងតាំងខ្ញុំឲ្យធ្វើ

ជាប្រធានកងធំ ដឹកនាំបងប្អូនលើកភ្លឺស្រែ និងបានដាក់ផែនការឲ្យខ្ញុំអនុវត្តគឺ៖

១) លើកភ្លឺកុំឲ្យត្រង់ និងធំពេក

២) ប្រើហិង្សាឃោរឃៅ ចាប់ចងធ្វើបាបប្រជាជន ទោះឈឺក្តីដេញឲ្យទៅធ្វើការទាំងអស់

៣) បង្អត់បាយប្រជាជនណាដែលលើកភ្លឺស្រែប្រវែងប្រាំម៉ែត្រមិនបាន

៤) ត្រូវឃោសនាប្រានទម្លាក់កំហុសទាំងអស់នេះប្រាប់ដល់ប្រជាជន

ក្រោយមក អង្គការបានចាត់តាំងខ្ញុំឲ្យទៅភ្ជួរស្រែរនាម ។ នៅទីនោះ ខ្ញុំបានជួបជាមួយ កាញ់ ប្រធានក្តាប់រួមភ្ជួរស្រែរនាម ។ កាញ់ បាននិយាយថា បើកុំតែបដិវត្តន៍គាត់មិនលំបាកដូច្នេះទេ ព្រោះធ្លាប់ធ្វើស្រែតែបន្តិចសោះ សល់ស្រូវហូរហៀរជង្រុក ។ ខ្ញុំក៏ឆ្លៀតតបទៅគាត់ថា បើកុំតែខ្មែរក្រហមវាយឈ្នះភ្នំពេញ កុំអីរូបខ្ញុំក៏មិនលំបាកវេទនាព្រាត់ប្រាស់បងប្អូនមករស់នៅទីនេះដែរ ។

រហូតដល់ពាក់កណ្តាលឆ្នាំ១៩៧៦ ទើបខ្ញុំត្រឡប់ពីស្រែរនាម ។ រហូតដល់ចុងឆ្នាំ១៩៧៦ អង្គការបានដាក់ភារកិច្ចខ្ញុំឲ្យជញ្ជូនកណ្តាប់ស្រូវតាមទូកដោយពេលនោះខ្ញុំបានពន្លិចស្រូវ និងទុកឲ្យស្រូវរលួយជាច្រើន ព្រមទាំងបានបំផុសបងប្អូនដែលច្រូតស្រូវឲ្យត្រឡប់ទៅផ្ទះវិញ ។

លុះដល់ដើមឆ្នាំ១៩៧៧ ឱកាសដែលអង្គការហៅទៅធ្វើការផ្នែកស្ថិតិ ខ្ញុំបានឃោសនាបំផុសពីការសើរើឯកជន ចែកគោ ក្របីដល់ប្រជាជនឲ្យធ្វើរៀងៗខ្លួន ធ្វើឲ្យមានការរំដើបរំជួល និងស្មុះការងារបដិវត្តន៍ និងអសកម្មដោយមិននាំគ្នាចេញទៅច្រូត ។ ក្រៅពីនោះ ខ្ញុំបានធ្វើឲ្យគោមួយក្បាលងាប់ទៀតផង ។

នៅឆ្នាំដដែល អង្គការបានចាត់តាំងខ្ញុំឲ្យដឹកនាំបងប្អូនរុះរើភ្លឺស្រែដើម្បីធ្វើសាជាថ្មី និងជីកស្រះ ប៉ុន្តែខ្ញុំមិនបានធ្វើតាមទេ គឺបានណែនាំឲ្យបងប្អូនធ្វើឲ្យតូច វៀចជាបន្តទៀត ។ រីឯសកម្មភាពលើកស្រះ ខ្ញុំបានដឹកនាំបងប្អូនលើកឈប់ៗ គេចវេះការងារដែលអង្គការដាក់ឲ្យសម្រុកដោយណែនាំដល់បងប្អូនថា “ការងារបដិវត្តន៍មិនងាយចប់ទេ ។ អង្គការឲ្យបងប្អូនហូបមិនឆ្អែតហើយបង្ខំឲ្យបងប្អូនពេលព្រឹក លើកភ្លឺស្រែ ល្ងាចជីកស្រះទៀត ។ សកម្មភាពលើកភ្លឺនិងជីកស្រះនេះខ្ញុំបានអនុវត្តរហូតដល់ខែមិថុនា ឆ្នាំ១៩៧៧ ទើបអង្គការចាប់ខ្លួនខ្ញុំមកទីនេះ ។ **សោម ប៊ុនថន**



អ្នកទោសដែលត្រូវបានសម្លាប់នៅមន្ទីរស-២១

# កម្ចាត់កម្មសិទ្ធិបុគ្គលស្ងួនតួឱ្យជ្រះស្រឡះហើយពង្រឹង និងពង្រីកកម្មសិទ្ធិសមូហភាពឱ្យបានខ្លាំងក្លា

*ដកស្រង់ចេញពីសៀវភៅ យុវជន និងយុវនារីបដិវត្តន៍ លេខ១១ វិច្ឆិកា ឆ្នាំ១៩៧៥*

ហៅថាកម្មសិទ្ធិ គឺការហួងហែង ការលោភលន់ ឬបំណងប៉ងប្រាថ្នាទៅលើអ្វីមួយរបស់ជនម្នាក់ ឬរបស់ជនច្រើននាក់របស់វណ្ណៈច្រើន ។ មនុស្សយើង ឬវណ្ណៈនីមួយៗតែងមានកម្មសិទ្ធិច្រើនបែបយ៉ាងដូចជា ៖

◆ កម្មសិទ្ធិខាងសម្ភារជារបស់របរប្រើប្រាស់ ស៊ីចុក ស្លៀកពាក់ ។

◆ កម្មសិទ្ធិខាងសតិអារម្មណ៍ ដូចជាបុគ្គលនិយម សេរីនិយម អំនួតអួតអាង មុខមាត់ បុណ្យសក្តិ កិត្តិយសផ្ទាល់របស់ខ្លួន ។ល ។

◆ កម្មសិទ្ធិអំណាច ដូចជាអាជ្ញានិយម នាម៉ឺននិយម ការិយាល័យនិយម ក្រសួងនិយម ផ្នែកនិយម ។

◆ កម្មសិទ្ធិខាងមនោសញ្ចេតនា ដូចជាស្រឡាញ់ ខឹង អាណិតអាសូរ ព្រួយ សប្បាយរីករាយ ។ល ។

តែបើសរុបទៅ កម្មសិទ្ធិមានតែពីរបែបទេ គឺកម្មសិទ្ធិឯកជន និងកម្មសិទ្ធិសមូហភាព ។

**ក. កម្មសិទ្ធិឯកជន ៖** គឺការលោភលន់ការហួងហែង ចង់មាន ចង់បានរបស់បុគ្គលម្នាក់ទៅលើសម្ភារផ្សេងៗ នៅក្នុងសតិអារម្មណ៍ នៅក្នុងមនោសញ្ចេតនា ។ ដូចពាក្យចាស់យើងតែងថា អ្វីក៏អញ អ្វីក៏ជារបស់អញ ។ ពោលគឺ អាត្មាអញហ្នឹង វាគ្របដណ្តប់ទៅលើសង្គមមនុស្សដែលនៅជុំវិញខ្លួនទាំងអស់ ។ សតិអារម្មណ៍កម្មសិទ្ធិឯកជននេះ ជាសតិអារម្មណ៍របស់វណ្ណៈជិះជាន់ ដែលគិតតែពីកេងប្រវ័ញ្ច គិតតែពីរឹបជាន់ឆក់ប្លន់ប្រជាជនក្រីក្រ យកមកធ្វើមានបាន ធ្វើជាកម្មសិទ្ធិរបស់ខ្លួនទាំងអស់ ចង់អ្នកណារងទុក្ខវេទនាយ៉ាងណា ក៏មិនឈឺក្បាល ចង់ប្រជាជនអត់ឃ្លានដាច់ពោះស្លាប់ ក៏មិនឈឺចាប់អ្វីដែរ ។ កម្មសិទ្ធិឯកជននេះ ជាទស្សនៈគោលជីហរសតិអារម្មណ៍របស់ពួកចក្រពត្តិ វណ្ណៈសក្តិភូមិ និងវណ្ណៈនាយទុន ដែលយុវជន យុវនារីបដិវត្តន៍យើង ត្រូវវាយកម្ទេចឲ្យអស់ពីក្នុងសង្គមកម្ពុជា ក៏ដូចពីជួរបដិវត្តន៍យើង និងពីក្នុងខ្លួនយើង ។

**ខ. កម្មសិទ្ធិសមូហភាព ៖** គឺការហួងហែង ឬជាសម្បត្តិរួមរបស់ប្រជាជន ពលករដ៏ច្រើនកុះករ ដែលជាអ្នកបង្កបង្កើនផល ជាអ្នកច្នៃប្រឌិតកសាងកែប្រែសង្គម និងជាអ្នកកសាងប្រវត្តិសាស្ត្រមនុស្សលោក ។ ដូច្នេះ កម្មសិទ្ធិសមូហភាពគឺល្អ គឺយុត្តិធម៌ ។ សតិអារម្មណ៍កម្មសិទ្ធិសមូហភាពនេះហើយ ដែលបដិវត្តន៍យើងចង់បាន ដែលយុវជន យុវនារីបដិវត្តន៍យើងត្រូវខិតខំកសាងនៅក្នុងសង្គមកម្ពុជាយើង នៅក្នុងជួរបដិវត្តន៍យើង ក៏ដូចជានៅក្នុងខ្លួនយើងម្នាក់ៗដែរ ។

## ១) សភាពកម្មសិទ្ធិ នៅក្នុងសង្គមកម្ពុជាបច្ចុប្បន្ន

ក្រោយពេលរំដោះទូទាំងប្រទេស ចក្រពត្តិអាមេរិក និងបរិវារត្រូវវាយបណ្តេញចេញអស់ពីកម្ពុជា ។ វណ្ណៈសក្តិភូមិ និងវណ្ណៈនាយទុន ត្រូវវាយរំលំអស់ជាមូលដ្ឋាន ទាំងរបបនយោបាយ ទាំងមូលដ្ឋានសេដ្ឋកិច្ច ។ មធ្យោបាយផលិតកម្ម ទាំងតូច ទាំងមធ្យម ធំ ត្រូវធ្លាក់មកក្នុងកណ្តាប់ដៃរដ្ឋ កម្មករ កសិករ និងក្នុងកណ្តាប់ដៃប្រជាជនសហករណ៍អស់រលីងហើយ ។

ឧទាហរណ៍ ៖ នៅទីក្រុង រោងចក្រ កំពង់ផែ ផ្លូវគមនាគមន៍ទាំងជើងទឹក ទាំងជើងគោក ត្រូវធ្លាក់មកក្នុងកណ្តាប់ដៃកម្មករ កសិករទាំងអស់ ។ កម្មករដែលរស់នៅធ្វើការងារក្នុងរោងចក្រទាំងអស់សុទ្ធតែស្ថិតក្នុងក្របខណ្ឌសហជីពមានលក្ខណៈជាសមូហភាពអស់ហើយដែរ ។

ចំណែកឯនៅជនបទ មធ្យោបាយផលិតកម្មសំខាន់ៗដូចជាដីធ្លី ស្រែចម្ការ គោក្របី រទេះ សាឡី ពូជធារ ។ល ។ ចំនួនជាង៩៩ភាគរយ សុទ្ធសឹងជាកម្មសិទ្ធិសមូហភាពរបស់សហករណ៍ទាំងអស់ ។ ដូច្នេះសព្វថ្ងៃ សភាពការណ៍នៅជនបទ ទាំងតំបន់រំដោះចាស់ ទាំង

តំបន់រំដោះថ្មី ប្រជាជនយើងស្ថិតនៅក្នុងសហករណ៍ទាំងអស់ ។ ទាំងកម្លាំងមនុស្ស ទាំងមធ្យោបាយផលិតកម្ម ទាំងការរស់នៅធ្វើការងារប្រចាំថ្ងៃ មានលក្ខណៈជាសមូហភាពអស់ហើយ ។ ឯកម្មសិទ្ធិឯកជន ត្រូវបានកម្ចាត់ជាបណ្តើរៗ ។ សព្វថ្ងៃ បងប្អូនកសិករយើងទាំងថ្មី ទាំងចាស់ មានការរស់នៅ ការធ្វើការងារ ការរៀនសូត្រ ការកម្សាន្ត ការសុខដុមរមនា ឬការអត់ឃ្លានជាសមូហភាពក្នុងសមូហភាពនៃសហករណ៍ ក្រោមការដឹកនាំរបស់បក្ស ។ ដូច្នេះ ខាងគោលជំហរស្មារតី សតិអារម្មណ៍ ក៏ឈានទៅសមូហភាពកាន់តែខ្ពស់ឡើងៗដែរ ។

សរុបមក ឃើញថាក្នុងសង្គមកម្ពុជាថ្មីបច្ចុប្បន្ននេះ ប្រជាជនកម្មករ កសិករ ទាំងនៅជនបទ ទាំងនៅទីក្រុង មានស្មារតីសមូហភាព និងមានការចាត់តាំងសមូហភាពកម្រិតខ្ពស់ហើយ ។ តទៅអនាគតពេលដែលសហករណ៍ និងសហជីព វាចេះតែពង្រីង និងពង្រីកខ្លួនតទៅទៀត គោលជំហរកម្មសិទ្ធិសមូហភាពរបស់ប្រជាជនយើង វានឹងចេះតែវិវត្តខ្ពស់ឡើងជាលំដាប់ទៀត រីឯកម្មសិទ្ធិឯកជន វាឈានទៅរលំរលាយទាំងស្រុងហើយ ។ នេះជាទិដ្ឋភាពល្អ និងជាទិសវិវត្តល្អនៃសង្គមកម្ពុជាថ្មីយើង ។

## ៣) សភាពកម្មសិទ្ធិ នៅក្នុងជួរបដិវត្តន៍យើង

នៅក្នុងជួរបដិវត្តន៍យើង យុទ្ធជន យុទ្ធនារី និងកម្មាភិបាលយើងទាំងអស់សុទ្ធតែបានលះបង់កម្មសិទ្ធិផ្ទាល់ខ្លួន ជាផ្ទះសម្បែងស្រែចម្ការ ច្បារដំណាំ ជាគ្រួសារម៉ែ បងប្អូន កូនចៅ និងជាទ្រព្យសម្បត្តិផ្សេងៗទៀតទាំងអស់ ដើម្បីបម្រើបក្ស បដិវត្តន៍ និងប្រជាជន ។ ចូលមកក្នុងជួរបដិវត្តន៍ ហើយដោយបានបក្សឃោសនាអប់រំតម្រែតម្រង់ជាប់ មិត្តយើងទាំងអស់បានខិតខំកសាងនូវគោលជំហរលះបង់ខាងសម្ភារ ទាំងខាងសតិអារម្មណ៍ និងមនោសញ្ចេតនាខ្ពស់ថែមទៀត ។ តែទោះបីយ៉ាង នេះហើយក្តី ក៏សតិអារម្មណ៍ឯកជន មិនទាន់បានកម្ចាត់អស់រលីងពីក្នុងជួរយើងនៅឡើយទេ ។ នេះជាការពិតជាក់ស្តែង ដែលយើងត្រូវឃើញ ត្រូវចាប់អារម្មណ៍ ហើយខិតខំវាយកម្ចាត់វាជាបន្តទៀត ។ យើងត្រូវឃើញឲ្យច្បាស់ ហើយមានទស្សនៈឲ្យត្រឹមត្រូវថា មិត្តយើងទាំងអស់គ្នា ទោះចេញពីស្រទាប់វណ្ណៈដើមជាអ្វីក៏ដោយ សុទ្ធសឹងតែចេញមកពីសង្គមចក្រពត្តិ សក្តិភូមិ នាយទុន ហើយសុទ្ធតែធ្លាប់បានរស់នៅច្រើនសិបឆ្នាំ ក្នុងសង្គមកម្មសិទ្ធិ ឯកជននេះ ។ ដូច្នេះ ទោះចង់ ឬមិនចង់ដឹងខ្លួនក្តី ឬមិនដឹងខ្លួន ទោះតិច ឬច្រើន សុទ្ធតែមានជក់ជាប់នូវសតិអារម្មណ៍កម្មសិទ្ធិឯកជន ឬហៅថាកម្មសិទ្ធិបុគ្គលសួនតួដែលជាឥទ្ធិពលនៃសង្គមចាស់គ្រប់ៗគ្នា ។ ដូច្នោះហើយ បានជានៅក្នុងជួរយុវជន យុវនារីបដិវត្តន៍យើង មានស្តែងចេញជាបាតុភាពខុសឆ្គងផ្សេងៗ ដែលលេចចេញមកពីគោលជំហរកម្មសិទ្ធិឯកជន ដូចជា

កម្មសិទ្ធិខាងសម្ភារ មានការប្រមូលជ័យភណ្ឌយកទុកដាក់សម្រាប់អង្គភាពខ្លួន ឬបុគ្គលខ្លួន ការប្រើប្រាស់ជ័យភណ្ឌ ឬសម្ភាររួមសេរីខុសអង្គការវិន័យ ខុសលក្ខការណ៍ចាត់តាំង ការហួងហែងលើសម្ភារផ្សេងៗដែលជារបស់រួម ។ល ។

◆ កម្មសិទ្ធិខាងអំណាច អាជ្ញានិយមដាក់ប្រជាជន អាជ្ញានិយមលើប្រជាជន លើយុទ្ធជន យុទ្ធនារី ក្នុងក្រសួងខ្លួន ជេរស្តីបន្ទោសយុទ្ធជន យុទ្ធនារី ដែលធ្វើការមិនត្រូវចិត្តខ្លួន ដាក់ទោសដាក់ទណ្ឌកម្មលើយុទ្ធជន យុទ្ធនារី ដែលធ្វើខុសឆ្គងបន្តិចបន្តួចរហូតដល់មិត្តខ្លះ ហ៊ានប្រើអាជ្ញាសម្រេចប្រហារជីវិតមនុស្សដែលមានការខុសឆ្គង តែពុំមែនជាខ្លាំងទេ ។

មិត្តខ្លះ នាម៉ឺននិយម ឬការិយាល័យនិយម វាយឫកក្រអឺតក្រទម ជាអ្នកត្រួតត្រា គ្រប់គ្រងប្រជាជន ឬយុទ្ធជនយុទ្ធនារីឯទៀត ធ្វើការងារអីបានតែបញ្ជាគេឯង តែខ្លួនឯងមិនចុះជាប់នឹងការងារពលកម្មជាក់ស្តែង មិនជាប់ជិតស្និទ្ធ យល់ដឹងសុខទុក្ខប្រជាជន ឬយុទ្ធជនយុទ្ធនារីឯទៀត ។ល ។

◆ កម្មសិទ្ធិលើក្រសួង លើផ្នែក លើអង្គភាពរបស់ខ្លួន ។ ឧបមាបើប្រមូលជ័យភណ្ឌអីបានយកលាក់ទុកប្រើប្រាស់សម្រាប់តែអង្គភាពខ្លួន ក្រសួងខ្លួន ផ្នែកខ្លួន មិនគិតដល់រួមទូទាំងប្រទេស ឬដល់ផ្នែកដល់ក្រសួងដទៃឡើយ ទោះបីប្រជាជន ទោះបីអង្គភាព ឬក្រសួងឯទៀតខ្វះខាត ត្រូវការចាំបាច់យ៉ាងណាក៏មិនគិត ។

ឧបមា បើមានគេធ្វើអ្វី ឬថាអី ឬតិទៀនអីប៉ះពាល់ដល់ក្រសួងខ្លួនគឺក្តៅក្រហាយខឹងសម្បារ ប្រឡោតតោតតូង ហើយធ្វើការសងសឹក ដោយវាយប្រហារទៅលើអង្គភាព ឬក្រសួងដទៃវិញ គ្មានគិតគូរក្រែងប៉ះពាល់ដល់បញ្ហាសាមគ្គីភាព ឯកភាពផ្ទៃក្នុងឡើយ ។ ឧបមាបើមានរឿងអីកើតមានឡើង ឃើញតែក្រសួងខ្លួន ផ្នែកខ្លួន អង្គភាពខ្លួនត្រូវ ឯក្រសួងគេ ផ្នែកគេ អង្គភាពគេ ចេះតែខុសទាំងអស់ ។

◆ កម្មសិទ្ធិខាងសតិអារម្មណ៍ ៖ ដូចជាអំនួតអួតអាង មិនសុភាពរាបសារបដិវត្តន៍ បុគ្គលនិយម អាត្មានិយម សេរីនិយម អត្តនោម័តិនិយម មុខមាត់ បុណ្យសក្តិ តំណែងនាទី កិត្តិយសផ្ទាល់ខ្លួន ។

◆ កម្មសិទ្ធិតម្រិះវិជ្ជា ៖ ដោយមានទស្សនៈ គោលជំហរប្រកាន់ថា មានតែខ្លួនទេ ទើបជាអ្នកចេះ អ្នកដឹង អ្នកយល់ច្រើន ដូច្នេះ បដិសេធ ឬមិនទទួលមតិរបស់មហាជន ឬការយល់ដឹងរបស់មហាជនឡើយ ។ អ្នកមានកម្មសិទ្ធិខាងតម្រិះវិជ្ជា ច្រើនទុកមតិខ្លួនជាធំ ដូច្នោះមិនសូវស្តាប់ការណែនាំរបស់បក្ស ទេ ។

◆ កម្មសិទ្ធិខាងមនោសញ្ចេតនា គិតគូរ ឬអាណិតស្រណោះស្រឡាញ់តែក្រុមគ្រួសារខ្លួន ញាតិមិត្តខ្លួន បងប្អូនខ្លួន ឪពុកម្តាយខ្លួន ។ តែបើចំពោះប្រជាជនវិញ ទោះបីឈឺថ្កាត់ ឬអត់ឃ្លានដាច់ពោះស្លាប់ក៏មិនឈឺឆ្អាល ហើយចាត់ទុកថាជាការធម្មតា ឬមួយទៀតស្រឡាញ់ពេញចិត្តតែបុគ្គលណា ដែលចេះបញ្ចើចបញ្ចើផ្គាប់ផ្គុនប្រណិតប្រណាក់នឹងខ្លួន តែចំពោះយុទ្ធជន យុទ្ធនារីណាដែលគ្នាខិតខំធ្វើការ ហើយមិនបានមកផ្គាប់ផ្គុនខ្លួន បែរទៅជាសោះអង្គើយ ឬរហូតដល់មិនពេញចិត្តទៀត ។

ទាំងអស់នេះ សុទ្ធសឹងជាបាតុភាពខុសឆ្គង ដែលស្តែងចេញមកអំពីគោលជំហរកម្មសិទ្ធិបុគ្គលស្ងួនតួទាំងអស់ ដែលជាសតិអារម្មណ៍របស់វណ្ណៈជិះជាន់ មានចក្រពត្តិ សក្តិភូមិ និងនាយទុនជាដើម ។ យុវជន យុវនារីបដិវត្តន៍យើង ត្រូវឃើញ ហើយមានទស្សនៈឲ្យច្បាស់លាស់ថា សតិអារម្មណ៍កម្មសិទ្ធិបុគ្គលស្ងួនតួ វានៅមាននៅក្នុងជួរបដិវត្តន៍ ក្នុងជួរយុវជន យុវនារីបដិវត្តន៍យើង ក៏ដូចនៅក្នុងខ្លួនយើងនៅឡើយដែរ ។ យើងឃើញយ៉ាងនេះ មិនមែនដើម្បីទុទិដ្ឋិនិយមអស់សង្ឃឹម ឬអនុគ្រោះបណ្តែតបណ្តោយទុកឲ្យវារស់រានមានជីវិត ពួនសម្ងំនៅក្នុងខ្លួនយើង ក៏ដូចនៅក្នុងជួរបដិវត្តន៍ និងជួរយុវជន យុវនារីបដិវត្តន៍យើងតទៅទៀតនោះឡើយ ។ យើងឃើញសភាពសត្យានុម័តិយ៉ាងនេះ ដើម្បីប្រុងប្រយ័ត្នជាប់តស៊ូនឹងវាជានិច្ច ហើយមានវិធានការជាក់ស្តែង ទប់ទល់នឹងវាយកម្ចាត់វាឲ្យបានដាច់ខាត ។

### ៣) យុវជន យុវនារីបដិវត្តន៍យើង ត្រូវកម្ចាត់កម្មសិទ្ធិបុគ្គលស្ងួនតួឲ្យជ្រះស្រឡះ ហើយកសាងបំពាក់បំប៉នឲ្យខ្លួននូវកម្មសិទ្ធិ

### ៤) សមូហភាពឲ្យខ្លាំងក្លាឡើងជានិច្ច

បច្ចុប្បន្ននេះ យើងឈានចូលដល់ដំណាក់កាលបដិវត្តន៍សង្គមនិយមហើយ ហើយកំពុងត្រៀមលក្ខណៈសម្បត្តិឈានទៅកសាងសង្គមនិយមនៅកម្ពុជាទៀត ដើម្បីសង្គមនិយមបាន វាទាមទារឲ្យយុវជន យុវនារីយើង ក៏ដូចជាប្រជាជនយើងទាំងមូលមានគោលជំហរកម្មសិទ្ធិសមូហភាពខ្ពស់ និងរឹងប៉ឹងបំផុត ។

ឃើញសភាពប្រជាជនយើងក្នុងសង្គមកម្ពុជាបច្ចុប្បន្ន ហើយនិងឃើញសភាពកម្មសិទ្ធិឯកជន នៅក្នុងជួរបដិវត្តន៍យើងយ៉ាងនេះ តើយុវជនយុវនារីបដិវត្តន៍យើង អាចកសាងគោលជំហរសមូហភាពខ្ពស់ឈានទៅសង្គមនិយមបាន ឬមិនបាន? ឈរលើសភាពសត្យានុម័តិជាគុណសម្បត្តិ និងជាការខ្វះខាតដូចពោលខាងលើនេះ យើងជឿជាក់ថា យុវជន យុវនារីបដិវត្តន៍យើង អាចឈានទៅដល់ទិសដៅសមូហភាពនេះជាប្រាកដ ហើយត្រូវតែខំឈានទៅឲ្យដល់ទិសដៅសមូហភាពនេះដាច់ខាត ។

កន្លងមក យើងបានវាយបណ្តេញចក្រពត្តិ និងរបបអាណានិគមនិយមថ្មីរបស់វា ឲ្យចេញអស់ពីទឹកដីកម្ពុជា ។ យើងបានវាយរំលំវណ្ណៈសក្តិភូមិ និងវណ្ណៈនាយទុនអស់ជាមូលដ្ឋាន ។ ដូច្នេះ គឺយើងបានវាយកម្ទេចនូវរបបកម្មសិទ្ធិឯកជន របបកម្មសិទ្ធិបុគ្គលស្ងួនតួ ឲ្យជ្រះស្រឡះអស់ពីសង្គមកម្ពុជាយើងហើយ ។ សព្វថ្ងៃនេះប្រជាជនកម្ពុជាយើង ក៏បានលះបង់កម្មសិទ្ធិឯកជនគ្រប់បែបយ៉ាងមានតាំងពីស្រែចម្ការ គោក្របី រហូតដល់កម្លាំងពលកម្ម និងកម្លាំងបញ្ញារបស់ខ្លួនទៀត មកដាក់រួម ធ្វើជាកម្មសិទ្ធិសមូហភាពរបស់សហករណ៍ទាំងអស់ ។ ដូច្នេះសង្គមកម្ពុជាបច្ចុប្បន្នឈានទៅសមូហភាពហើយ ហើយកំពុងវិវត្តទៅកាន់តែល្អកាន់តែរឹងប៉ឹង ។ ការវិវត្តនេះ មានដំណើរលឿនស្ទេវណាស់ ដែលពុំអនុញ្ញាតឲ្យយុវជន យុវនារីបដិវត្តន៍យើងនៅបង្អែបង្អង់រ៉ែរ៉ៃបានឡើយ ។ ម្យ៉ាងទៀត យុវជនយុវនារី បដិវត្តន៍យើង ក៏ស្ថិតនៅក្នុងការចាត់តាំងសមូហភាពហើយ ។ មិត្តយើងបានលះបង់សព្វគ្រប់បែបយ៉ាង មកចូលក្នុងជួរបដិវត្តន៍ ដើម្បីបម្រើបក្ស បម្រើប្រជាជន ដោយឥតលក្ខខណ្ឌ ។ ព្រមជាមួយនេះ មិត្តយើង យុវជន យុវនារីយើងសុទ្ធតែចង់កសាងខ្លួន ចង់បម្រើឲ្យទាន់ចលនា គ្មាននរណាម្នាក់ឡើយចង់ជ្រុះពីចលនា ឬដាច់ឆ្ងាយពីចលនាឡើយ ។

ទាំងអស់នេះ សុទ្ធសឹងជាលក្ខណៈសម្បត្តិល្អ ដែលអនុគ្រោះ ហើយជំរុញឲ្យយុវជន យុវនារីបដិវត្តន៍យើង ឈានទៅកម្ចាត់កម្មសិទ្ធិបុគ្គលសួនតួបានជ្រះស្រឡះ ហើយពង្រឹង និងពង្រីកនូវកម្មសិទ្ធិសមូហភាពឲ្យបានកាន់តែខ្ពស់ កាន់តែខ្លាំងក្លាបានជាដាច់ខាត ។ ចំណែកឯការខ្វះខាតដែលមានដូចរៀបរាប់ពីខាងលើ វាគ្រាន់តែជាបាតុភូតបណ្តោះអាសន្ន ដែលកំពុងតែវិវត្តចុះទៅក្នុងចលនាតស៊ូវណ្ណៈដ៏សន្ធោរសន្ធៅបច្ចុប្បន្ននេះ ។ តែព្រមជាមួយគ្នានេះ យុវជនយុវនារីបដិវត្តន៍យើង ក៏ត្រូវឃើញថា គោលជំហរកម្មសិទ្ធិបុគ្គលសួនតួ វានៅមានអានុភាពខ្លាំងក្លានៅឡើយដែរនៅក្នុងជួរបដិវត្តន៍ ក៏ដូចជានៅក្នុងខ្លួនយើងម្នាក់ៗ ។ បើយើងគ្មានវិធានការជាក់ស្តែង គ្មានការប្តេជ្ញាចិត្តខ្ពស់នឹងវាយកម្ចាត់វាទេ វាអាចរស់រានមានជីវិត ហើយពង្រឹងពង្រីកខ្លួនវាតទៅទៀត នៅក្នុងជួរបដិវត្តន៍ ក៏ដូចនៅក្នុងខ្លួនយើងម្នាក់ៗដែរ ។

ព្រមជាមួយគ្នានេះ យុវជន យុវនារីបដិវត្តន៍យើង ត្រូវយល់ឃើញ ហើយមានទស្សនៈឲ្យច្បាស់លាស់ថា ការតស៊ូរវាងសតិអារម្មណ៍កម្មសិទ្ធិឯកជន និងសតិអារម្មណ៍កម្មសិទ្ធិសមូហភាព នៅក្នុងជួរបដិវត្តន៍ ក៏ដូចនៅក្នុងខ្លួនយើង ជាផ្នែកមួយនៃការតស៊ូវណ្ណៈ ។ ដូច្នេះ វាជាការតស៊ូស្លាប់រស់ តឹងតែង ស៊ុតស្មាញមួយដែរ ដែលយុវជន យុវនារីយើងពុំអាចសម្រុះសម្រួល ឬអធ្យាស្រ័យបណ្តែតបណ្តោយនោះ គោលជំហរកម្មសិទ្ធិសមូហភាព មុខជានឹងចាញ់គោលជំហរកម្មសិទ្ធិឯកជន បុគ្គលសួនតួពុំខានឡើយ ។ ដូច្នោះបានសេចក្តីថា បដិវត្តន៍នឹងចាញ់របបសក្តិភូមិ នាយទុនហើយ ។ ដូច្នេះ មហាជនដែលដើរលឿនទៅមុខឆ្ងាយណាស់ហើយនៅលើមាគ៌ាសមូហភាពនេះ ហើយដែលមានសំណូមពរចង់ឲ្យយុវជន យុវនារីយើងឈានទៅមុខឲ្យបានលឿនទាន់ចលនាក្តៅនេះ ប្រាកដជាពុំអនុញ្ញាតឲ្យគោលជំហរសក្តិភូមិ នាយទុននេះដណ្តើមប្រៀបវិញបានដាច់ខាត ។ ដូច្នេះ បើមិត្តយុវជន យុវនារីយើងណានៅតតិបតតុបពីរឿងកម្មសិទ្ធិសួនតួ នៅស្តាយស្រណោះអាឡោះអាល័យពីរឿងកម្មសិទ្ធិសួនតួនេះទៀត ក៏នៅឱបកម្មសិទ្ធិសួនតួនេះចុះ ប្រជាជន មហាជន និងចលនាបដិវត្តន៍ គេពុំអាចឈប់ចាំមិត្តឡើយ គេមុខជាទៅមុខចោលមិត្តហើយ ដូច្នេះ បានសេចក្តីថា មិត្តជ្រុះពីចលនាហើយ ។

ឃើញសភាពសត្យានុមតិយ៉ាងនេះ មិត្តយុវជន យុវនារីបដិវត្តន៍យើងគ្រប់រូប ខាងផ្នែកអត្តនោម័តិរបស់ខ្លួន ត្រូវខិតខំរត់ឲ្យទាន់ចលនា ។ យើងពុំអាចឈប់សម្រាកមួយសន្ទុះបានឡើយ ។ ដូច្នេះមិត្តត្រូវយល់ឃើញថា មិត្តបានលះបង់គ្រប់បែបយ៉ាងជាបន្តបន្ទាប់មក រហូតដល់ហ៊ានលះបង់អាយុជីវិតដ៏ក្មេងខ្ចីរបស់ខ្លួនជូនបក្សបដិវត្តន៍ និងប្រជាជនក្នុងការវាយកម្ទេចរបបអាណានិគមនិយមថ្មីរបស់ចក្រពត្តិអាមេរិក និងរបបសក្តិភូមិ នាយទុន ឲ្យរលំរលាយអស់ពីទឹកដីកម្ពុជា ។ ដូច្នេះ តើមិត្តមានហេតុផលអីទៅស្តាយស្រណោះ ឬឱបក្រសោបយកកម្មសិទ្ធិបុគ្គលសួនតួ ដែលជាកាកសំណល់នៃរបបអាណានិគមនិយម សក្តិភូមិនិយម នាយទុននិយមដែលយើងទាំងអស់គ្នាបានទាត់វាចោលហើយនោះឡើយ ។ គ្មានសម្ភារអ្វីប្រសើរថ្លៃថ្លាជាងសង្គមនិយមឡើយ ។ មិត្តបានរួមចំណែកធ្វើការតស៊ូតឹងតែងលំបាកវេទនារហូតដល់សម្រេចបដិវត្តន៍ប្រជាជាតិ ប្រជាធិបតេយ្យ ។ ឥឡូវបក្ស និងប្រជាជនប្រគល់ភារៈជូនមិត្តបន្តវេនធ្វើបដិវត្តន៍សង្គមនិយមតទៅទៀត ។ នេះជាកិត្តិយសខ្ពង់ខ្ពស់ឧត្តុង្គឧត្តម និងជាសុភមង្គលថ្លៃថ្លាបរិសុទ្ធបំផុតរបស់យុវជន យុវនារីបដិវត្តន៍យើង ដែលយើងទាំងអស់គ្នាត្រូវតែប្តេជ្ញាសម្រេចឲ្យបានដាច់ខាត ។ ដូច្នេះ យើងត្រូវតែទម្លាក់ចោលសំពាយចាស់ ដែលជាកម្មសិទ្ធិបុគ្គលសួនតួ ហើយបំពាក់បំប៉ននូវគោលជំហរកម្មសិទ្ធិសមូហភាពឲ្យបានរឹងប៉ឹង និងខ្លាំងក្លាដើម្បីជាកម្លាំងជំរុញដំណើរយើងឲ្យឈានលឿនទៅមុខជានិច្ច ឆ្ពោះទៅកាន់ទិសដៅសង្គមនិយមដាច់ខាត ។ **ធាច សារៈមុនិន្ទ**

# អានទស្សនាវដ្តីតាមគេហទំព័រ

ទស្សនាវដ្តីស្វែងរកការពិតទាំងអស់ត្រូវបានផ្សព្វផ្សាយតាមគេហទំព័ររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ អ្នកអានអាចរកបានតាមៈ http://d.dccam.org/Projects/Magazines/Magazine_Searching.htm . ព័ត៌មានបន្ថែម សូមទាក់ទង ញាណ សុជាតិ ទូរស័ព្ទលេខ ០ ១៦ ៨៧៦ ៦៩២ ឬ ០២៣ ២១១ ៨៧៥

# ចិន និងរបប ប៉ុល ពត



គណៈប្រតិភូចិនដឹកនាំដោយ វ៉ាង ដុងស៊ីង (ឆ្វេង) ទស្សនកិច្ចប្រទេសកម្ពុជាក្នុងខែវិច្ឆិកា ឆ្នាំ១៩៧៨ ទទួលស្វាគមន៍ និងអមដំណើរពីព្រលានយន្តហោះដោយ ប៉ុល ពត

ការគាំទ្ររបស់ប្រទេសចិនដល់របប ប៉ុល ពត នៅតែជាទិដ្ឋភាពមួយក្នុងចំណោមទិដ្ឋភាពក្តៅក្នុងប្រវត្តិសាស្ត្រសង្គ្រាមត្រជាក់របស់ប្រទេសចិន ។ ចន្លោះខែមេសាឆ្នាំ១៩៧៥ ដល់ខែមករា ឆ្នាំ១៩៧៩ ប្រទេសចិនគឺជាដៃគូបរទេសដ៏សំខាន់របស់រដ្ឋាភិបាលយោរយៅនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ តាំងពីយូរណាស់មកហើយ រដ្ឋាភិបាលចិនបានបន្ទាបទំនាក់ទំនងរវាងប្រទេសទាំងពីរខណៈដែលមេដឹកនាំកម្ពុជាមានបំណងកសាងទំនាក់ទំនងជាមួយទីក្រុងប៉េកាំងសាជាថ្មី ។ ទោះបីជាយ៉ាងនេះក៏ដោយ រឿងហេតុនេះក៏ត្រូវបានដឹកកកាយឡើងអំឡុងពេលការជំនុំជម្រះក្តីអតីតមេដឹកនាំខ្មែរក្រហមដោយតុលាការដែលគាំទ្រដោយអង្គការសហប្រជាជាតិនៅទីក្រុងភ្នំពេញ ។ ក្នុងឆ្នាំ២០០៩ នៅពេលដែលការជំនុំជម្រះក្តីដំបូងបានចាប់ផ្តើមឡើង អ្នកនាំពាក្យក្រសួងការបរទេសចិន លោកស្រី ចាង យូ៉ បានការពារទំនាក់ទំនងមិត្តភាពរបស់ចិនជាមួយនឹងរដ្ឋាភិបាលជាច្រើនជំនាន់រួមមានរបប ប៉ុល ពតផង ។ ក្នុងឆ្នាំ២០១០ ឯកអគ្គរដ្ឋទូតចិនប្រចាំការនៅប្រទេសកម្ពុជាបានទទួលស្គាល់ថា ប្រទេសរបស់លោកបានផ្តល់ស្បៀងអាហារ ប៉ុន្តែបានទទូចថា រដ្ឋាភិបាលចិនមិនដែលចូលរួមប្រឆើអន្តរាគមន៍ក្នុងគោលនយោបាយរបស់របបកម្ពុជាប្រជាធិបតេយ្យនោះឡើយ ។ មានអ្នកប្រឆាំងមួយចំនួនតូចបានបញ្ចេញមតិប្រឆាំងជាសាធារណៈ ដោយចោទប្រកាន់ប្រទេសចិនពីបទសម្លាប់ប្រជាជនកម្ពុជាមួយផ្នែកតូច ហើយបានប្រកាសថា «ប្រទេសចិនជំពាក់ការសូមទោសប្រជាជនកម្ពុជា» ។

តួនាទីរបស់ចិននៅក្នុងរបប ប៉ុល ពត ត្រូវបានលើកមកពិចារណាក្នុងបន្ទប់សវនាការតាំងពីដំបូងមកម៉្លេះ ។ ក្នុងឆ្នាំ១៩៧៩ តុលាការប្រជាជនបដិវត្តន៍ត្រូវបានបង្កើតឡើងដោយរបបសាធារណរដ្ឋប្រជាមានិតកម្ពុជាដែលគាំទ្រដោយវៀតណាមដើម្បីជំនុំជម្រះ ប៉ុល ពត និង អៀង សារី រដ្ឋមន្ត្រីក្រសួងការបរទេសរបស់របបកម្ពុជាប្រជាធិបតេយ្យ ។ តុលាការនោះបានស្តីបន្ទោសប្រទេសចិន

ជាច្រើន អំពីអំពើឃោរឃៅ ដែលបានកើតឡើងក្នុងរបបខ្មែរក្រហម ក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីបង្អាប់កិត្តិយសប្រទេសចិន នៅពេលដែលសង្គ្រាមនៅក្នុងតណ្ឌចិនលើកទីបីបានកើតឡើង ។ សេចក្តីសម្រេចរបស់តុលាការបានអះអាងថា ចិនបានបង្កើនជំនួយផ្នែកយោធាជាច្រើន ហើយបានបង្កើតទីប្រឹក្សាដើម្បីគ្រប់គ្រងសកម្មភាពរបស់មេដឹកនាំរបបកម្ពុជាប្រជាធិបតេយ្យជំរុញឲ្យក្រុមរបស់ខ្លួនអនុវត្តគោលនយោបាយប្រល័យពូជសាសន៍ប្រឆាំងប្រជាជនរបស់យើង និងសង្គ្រាមឈ្លានពានប្រឆាំងវៀតណាម និងបម្រើមុខងារជាអ្នកញុះញង់លើផែនការនេះ ។ ទោះបីជាដំណើរនីតិវិធីនាពេលបច្ចុប្បន្ន ទំនងជានឹងមិនដាក់បញ្ចូលភាពលម្អៀងស្រដៀងគ្នាប្រឆាំងទៅនឹងទីក្រុងប៉េកាំង មានសំណួរជាច្រើននៅតែមានទំនាក់ទំនងទៅនឹងលក្ខណៈ និងឥទ្ធិពលរបស់ប្រទេសចិនមកលើរបបកម្ពុជាប្រជាធិបតេយ្យ ។

អត្ថបទនេះ គាំទ្រការឆ្លុះបញ្ចាំងដល់ទំនាក់ទំនងរវាងប្រទេសចិន និងរបបកម្ពុជាប្រជាធិបតេយ្យ តាមរយៈការត្រួតពិនិត្យមើលលក្ខណៈនៃសម្ព័ន្ធមិត្តរបស់ប្រទេសទាំងពីរ ហើយថាតើសម្ព័ន្ធមិត្តបានធ្វើឲ្យប៉ះពាល់ដល់ឥទ្ធិពលរបស់ប្រទេសចិនថ្នាក់មូលដ្ឋានយ៉ាងដូចម្តេច ។ ដើម្បីស្វែងរកបញ្ហានេះ អត្ថបទនេះបានទាញយកបទសម្ភាសន៍ជាមួយអតីតកម្មាភិបាលខ្មែរក្រហម ដែលធ្វើការជាមួយនឹងមន្ត្រីចិនចន្លោះឆ្នាំ១៩៧៥ដល់ឆ្នាំ១៩៧៩ ព្រមទាំងកំណត់ហេតុក្នុងរបបកម្ពុជាប្រជាធិបតេយ្យជាផ្លូវការ ដែលមិនបានលើកឡើងដោយមជ្ឈមណ្ឌលឯកសារកម្ពុជា និងចម្លើយសារភាពថ្មីៗនៅសាលាក្តីខ្មែរក្រហម ។ ទោះបីជាប្រភពថ្មីទាំងនេះបានលាតត្រដាងព័ត៌មានថ្មីតិចតួចអំពីដំណើរការក្នុងការសម្រេចចិត្តក្នុងរង្វង់ខ្មែរក្រហម ឬអ្នកកាន់កាប់ការិយាល័យនយោបាយចិនក៏ដោយ ក៏ប្រភពថ្មីទាំងនោះផ្តល់នូវទិដ្ឋភាពផ្នែកខាងក្នុងដ៏សំខាន់ដែលភាគីទាំងពីរយល់ដឹងអំពីសម្ព័ន្ធភាព ហើយត្រូវបានអនុវត្តនៅតាមថ្នាក់មូលដ្ឋានយ៉ាងដូចម្តេច ។

ភស្តុតាងទាំងនោះបង្ហាញនូវសម្ព័ន្ធភាពដែលភ្ជាប់ដោយមន្ទិលសង្ស័យទៅវិញទៅមក និងគោលដៅជាយុទ្ធសាស្ត្រ និងការ



យោធាខ្មែរក្រហមនិងក្រុមជំនាញការចិននៅប្រាសាទអង្គរវត្តក្នុងអំឡុងដំណើរទស្សនកិច្ចនៅជនបទក្នុងរបបខ្មែរក្រហម

សហការជារួម ជាជាងភាពដូចគ្នានៃមនោគមវិជ្ជា ។ ប្រទេសចិនបានជះឥទ្ធិពលទៅលើផ្នែកបច្ចេកទេស និងការិយាធិបតេយ្យក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ប៉ុន្តែភ័ស្តុតាងនោះបានលើកឡើងថាឥទ្ធិពលរបស់ប្រទេសចិនមានភាពទន់ខ្សោយលើគោលនយោបាយរបស់កម្មាភិបាលខ្មែរក្រហមជាន់ខ្ពស់ស្តីពីកិច្ចការសន្តិសុខ និងការងារផ្ទៃក្នុង ។ មន្ត្រីចិនមួយចំនួន មិនយល់ស្របជាមួយនឹងគោលនយោបាយរបបកម្ពុជាប្រជាធិបតេយ្យ ហើយបានជំរុញឲ្យមានការកែប្រែ ប៉ុន្តែមេដឹកនាំរបបកម្ពុជាប្រជាធិបតេយ្យបានការពារស្វ័យភាពរបស់ខ្លួនយ៉ាងមុតមាំ ។ ប្រទេសចិនមិនមានប្រតិកម្មខ្លាំងទៅនឹងរបបកម្ពុជាប្រជាធិបតេយ្យ សូម្បីតែនៅពេលដែលគោលនយោបាយយង់ឃ្នងរបស់របបកម្ពុជាប្រជាធិបតេយ្យបានបំផ្លាញដល់លទ្ធភាពនៃភាពជោគជ័យរបស់របបកម្ពុជាប្រជាធិបតេយ្យ ធ្វើឲ្យអាម៉ាស់មុខដល់ប្រទេសចិនក្នុងឆាកអន្តរជាតិ និងការបង្កសង្រ្គាមជាមួយប្រទេសវៀតណាមក៏ដោយ ។ ទស្សនៈរបស់ប្រទេសចិនស្តីពីផលប្រយោជន៍ ជាយុទ្ធសាស្ត្ររបស់ខ្លួន បានធ្វើឲ្យចុះទន់ខ្សោយដល់ឥទ្ធិពលទីក្រុងប៉េកាំង ហើយអាចធ្វើឲ្យមេដឹកនាំរបបកម្ពុជាប្រជាធិបតេយ្យអាចគ្រប់គ្រងទំនាក់ទំនងបានយ៉ាងប្រសើរ ។ ការសិក្សាអំពីទំនាក់ទំនងរវាងប្រទេសចិន និងរបបកម្ពុជាប្រជាធិបតេយ្យ គឺជាគំរូដ៏សំខាន់នៃសមត្ថភាពរបស់រដ្ឋទន់ខ្សោយក្នុងការជះឥទ្ធិពល និងការធ្វើស្វ័យភាពក្នុងសម្ព័ន្ធមិត្ត ពេលខ្លះជះឥទ្ធិពលដល់ការបំផ្លិចបំផ្លាញសម្ព័ន្ធមិត្តរបស់ខ្លួន ដែលនេះគឺជាមេរៀនដែលពាក់ព័ន្ធទៅនឹងទំនាក់ទំនងការបរទេស នាពេលបច្ចុប្បន្នរបស់ប្រទេសចិន ។

**ការជំរុញឲ្យមានភាពជាដៃគូ**

បន្ទាប់ពីជ័យជម្នះនៅខែមេសាឆ្នាំ១៩៧៥ ជនបដិវត្តន៍ខ្មែរក្រហម បានងាកទៅរកប្រទេសចិនដោយគ្មានជម្រើស ។ ជនបដិវត្តន៍ទាំងនោះ បានមើលងាយលោកខាងលិច និងសហភាពសូវៀត ដែលមានទំនាក់ទំនងយ៉ាងជិតស្និទ្ធនឹងប្រទេសវៀតណាមខាងជើង ប៉ុន្តែលោកខាងលិច និងសហភាពសូវៀត បានផ្តល់ការគាំទ្រសង្រ្គាមស៊ីវិលរបស់ខ្មែរក្រហម ហើយបានពិចារណាលើកិច្ចព្រមព្រៀងសន្តិភាពក្នុងឆ្នាំ១៩៧២ ក្នុងតំបន់ឥណ្ឌូចិន ដែលបានធ្វើឲ្យរបប លន់ នល់ ស្តាំនិយមចូលកាន់អំណាចនៅក្នុងប្រទេសកម្ពុជា ។ ភ្លាមៗបន្ទាប់ពីកាន់កាប់ប្រទេសទាំងមូល កងយោធាខ្មែរក្រហមបានចូលក្នុងស្ថានទូតសូវៀត ហើយបានចាប់ចងអ្នកការទូតសូវៀត រួចហើយបានបញ្ជូនចូលទៅក្នុងស្ថានទូតបារាំង ដើម្បីបណ្តេញចេញជាមួយនឹងជនបរទេសដទៃទៀត ។ មេដឹកនាំខ្មែរក្រហមក៏បានជំទាស់នូវសំណើក្រុងហាណូយ ក្នុងការបង្កើតទំនាក់ទំនង ជាពិសេស ដោយភ័យខ្លាចថា វៀតណាមមានបំណងគ្រប់គ្រងប្រទេសកម្ពុជា ហើយបង្វែរប្រទេសកម្ពុជាទៅជាសហព័ន្ធឥណ្ឌូចិន ។ ផ្ទុយទៅវិញ នៅដើមខែឧសភា កងកម្លាំងរបស់របបកម្ពុជាប្រជាធិបតេយ្យ បានវាយប្រហារកោះចំនួនពីរដែលមានជម្លោះ ដែលស្ថិតក្រោមការគ្រប់គ្រងរបស់វៀតណាមក្នុងឈូងសមុទ្រថៃ ដោយធ្វើឲ្យប៉ះពាល់ដល់ការគ្រប់គ្រងរបស់វៀតណាមមកលើដែនកោះរបស់ប្រទេសកម្ពុជា ហើយបានបង្កឲ្យមានការរង្គោះរង្គើទំនាក់ទំនង ។

សាធារណរដ្ឋប្រជាមានិតចិន ស្ទើរតែមិនមានកំណត់ត្រាគាំទ្រជនកុម្មុយនីស្តកម្ពុជា ។ ប្រទេសចិនបានគាំទ្រសម្តេចព្រះ នរោត្តម សីហនុ ប្រឆាំងទៅនឹងក្រុមខុទ្ទាមខ្មែរក្រហមអំឡុងទសវត្សរ៍៦០ ហើយបានប្រមូលផ្តុំជនបះបោរកម្ពុជា បន្ទាប់ពី លន់ នល់ ចូលកាន់អំណាចក្នុងឆ្នាំ១៩៧០ ហើយបន្តការផ្សះផ្សាជាមួយនឹងសហរដ្ឋអាមេរិកចន្លោះពីឆ្នាំ១៩៧១ និង ១៩៧២ ។ យ៉ាងណាក៏ដោយ ខ្មែរក្រហមបានទទួលស្គាល់ទីក្រុងប៉េកាំង ពីព្រោះលទ្ធិម៉ៅនិយមស្របទៅនឹងការសិក្សាអំពីមនោគមវិជ្ជារបស់ខ្លួន ហើយខ្មែរក្រហមទាំងនោះ មិនបានត្រៀមខ្លួនឲ្យបានល្អដើម្បីក្រោកឈរឡើងដោយខ្លួនឯងនោះឡើយ ។ ប្រទេសចិនបានអបអរសាទរ ប៉ុន្តែបានអះអាងយ៉ាងមុតមាំក្នុងសេចក្តីថ្លែងការណ៍រួមថា រដ្ឋាភិបាលថ្មីនឹងត្រូវបានដឹកនាំដោយសម្តេចព្រះ នរោត្តម សីហនុ ដែលជាមិត្តភក្តិរបស់ប្រទេសចិន ដែលកំពុងគង់នៅទីក្រុងប៉េកាំងចាប់តាំងពីរដ្ឋប្រហារឆ្នាំ១៩៧០ ប្រឆាំងនឹងព្រះអង្គមក ។

មេដឹកនាំរបបកម្ពុជាប្រជាធិបតេយ្យ បានតែងតាំងសម្តេចព្រះនរោត្តម សីហនុ ជាប្រមុខរដ្ឋធម្មតា នៅសម័យប្រជុំសភាជាតិពិសេសនៅថ្ងៃទី២៥ដល់២៧ ខែមេសា ប៉ុន្តែបានបញ្ជាក់ថាមេដឹកនាំទាំងនោះនឹងមិនក្លាយជាតួអង្គជំនួសឲ្យជនបរទេសណាមួយឡើយ ៖

> *យុទ្ធសាស្ត្រយូរអង្វែងរបស់ប្រទេសកម្ពុជាយើង គឺដើម្បីបន្តគោលនយោបាយឯករាជ្យ សន្តិភាព អព្យាក្រឹត្យ និងមិនចូលបក្សសម្ព័ន្ធ ។ ពិតប្រាកដណាស់ ប្រជាជនរបស់យើង នឹងមិនអនុញ្ញាតឲ្យប្រទេសណាមួយបង្កើតមូលដ្ឋានយោធានៅក្នុងប្រទេសកម្ពុជា ហើយជំទាស់ដាច់ខាតទៅនឹងការជ្រៀតជ្រែករបស់បរទេសក្នុងកិច្ចការផ្ទៃក្នុងរបស់ប្រទេសកម្ពុជា ។*

ការហាមឃាត់មូលដ្ឋានបរទេស គឺជាការព្រមានដល់ប្រទេសវៀតណាមដែលមានទាហានប្រហែលពីរម៉ឺននាក់នៅលើទឹកដីប្រទេសកម្ពុជា ប៉ុន្តែជាការព្រមានដល់ការជ្រៀតជ្រែកផ្ទៃក្នុង ដែលធ្វើឡើងដោយប្រទេសចិនផងដែរ ។ ទីក្រុងប៉េកាំង បានព្រួសារមួយនេះ ។ អត្ថបទកាសែត ស៊ិនហ័រ ដែលចុះនៅថ្ងៃទី១៣ ខែឧសភា បាននិយាយដដែលអំពីព័ត៌មាននោះដោយត្រង់ៗគ្មានលម្អៀង ហើយសេនាប្រមុខចិន លោក យេ ចេននីយ៉ីង បាននិយាយថា ប្រទេសចិននឹងគាំទ្រដាច់ខាតដល់ការតស៊ូរបស់ប្រជាជនកម្ពុជាដើម្បីការពារឯករាជ្យជាតិ និងអធិបតេយ្យភាពជាតិរបស់ប្រជាជនកម្ពុជា ។ ខ្មែរក្រហមបានទទួលស្គាល់តម្រូវការសម្រាប់ជំនួយបរទេស ជាពិសេសពីប្រទេសចិន ។ នៅថ្ងៃទី១៩ ខែមេសា ទន្ទឹមពេលដែលទាហានខ្មែរក្រហមជម្លៀសប្រជាជនចេញពីក្រុងភ្នំពេញ អៀង សារី បានធ្វើដំណើរទៅកាន់ទីក្រុងប៉េកាំង ហើយបានចរចាជាមួយចិនលើកិច្ចព្រមព្រៀងផ្តល់អាវុធ១៣.៣០០តោន ហើយចែកចាយតាមរយៈកំពង់ផែសមុទ្រកំពង់សោម ជាជាងតាមផ្លូវគោកកាត់តាមប្រទេសវៀតណាម ។ បួនថ្ងៃក្រោយមក អៀង សារី បានត្រឡប់មកដល់ទីក្រុងភ្នំពេញ ជាមួយនឹងមន្ត្រីចិន និងអ្នកជំនាញមួយក្រុម ដោយមកជាមួយនូវឧបករណ៍ទំនាក់ទំនង និងឧបករណ៍សំខាន់ផ្សេងទៀតសម្រាប់បង្កើតរដ្ឋាភិបាលថ្មី ។ នៅដើមខែឧសភា ប៉ុល ពត ត្រូវបានរាយការណ៍ថាបានធ្វើដំណើរដោយសម្ងាត់ទៅទីក្រុងប៉េកាំងនិងបានព្រមព្រៀងលើជំនួយសេដ្ឋកិច្ច ជំនួយផ្នែកបច្ចេកទេស និងការបណ្តុះបណ្តាលផ្នែកយោធាសម្រាប់គាំទ្រទស្សនៈចិនស្តីពី «ចក្រវាឡពា» និងការគាំទ្រទីក្រុងប៉េកាំងប្រឆាំងទៅនឹងទីក្រុងម៉ូស្គូ ដែលជាការបញ្ជាក់ខាងដើមថា ទំនាក់ទំនងនោះ នឹងតម្រូវឲ្យមានការជួយគ្នាទៅវិញទៅមក ។

នៅដើមខែឧសភា ស្ថានទូតចិន បានបើកឡើងវិញ ប៉ុន្តែសក្ខីកម្មនៅតុលាការខ្មែរក្រហម ដែលគាំទ្រដោយអង្គការសហប្រជាជាតិ ដែលស្គាល់ជាផ្លូវការថាអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានបញ្ជាក់ថា របបកម្ពុជាប្រជាធិបតេយ្យបានចាត់ទុកការមកដល់របស់គណៈប្រតិភូចិនថាជារឿងគួរឲ្យសង្ស័យ ។ ក្នុងខែមិថុនា ឆ្នាំ២០១២ អតីតកម្មាភិបាលខ្មែរក្រហម ខឹម ងន បានផ្តល់សក្ខីកម្មថា ភ្លាមៗបន្ទាប់ពីជ័យជម្នះរបស់ខ្មែរក្រហម គាត់ និងកម្មាភិបាលប្រាំនាក់បានឈរជើងនៅស្ថានទូតចិន ហើយត្រូវបានចាត់តាំងឲ្យអមដំណើរភ្ញៀវ ។ គាត់បានពន្យល់ថា យើងមិនត្រូវបានអនុញ្ញាតឲ្យនិយាយទៅកាន់ភ្ញៀវអំពីរឿងនយោបាយ ហើយយើងមិនអាចធ្វើដំណើរដោយសេរីនោះឡើយ ។ កម្មាភិបាលជាច្រើនត្រូវបានបង្រៀនឲ្យមានការប្រុងប្រយ័ត្នស្គាល់ខ្មាំងស៊ីរូងផ្ទៃក្នុង និយាយបន្តិចបន្តួចទៅកាន់មន្ត្រីចិន និងរាយការណ៍អំពីគ្នាទៅវិញទៅមក ។ កំហុសឆ្គងណាមួយ នឹងត្រូវបញ្ជូនទៅសមរភូមិក្រោយឬត្រូវអប់រំដែលមានន័យថា ត្រូវធ្វើពលកម្មនៅតាមវាលស្រែរយៈពេលយូរ ប្រសិនបើកំហុសនោះមិនអាក្រក់ហួសហេតុនោះ ។ សក្ខីកម្មរបស់ ខឹម ងន ផ្តល់នូវភាពដែលអាចជឿជាក់បានលើរបាយការណ៍របស់មន្ត្រីចិនផ្សេងទៀត ដែលមានវត្តមានក្នុងរបបកម្ពុជាប្រជាធិបតេយ្យដែលការទទួលបានព័ត៌មានស្តីពីអំពើឃោរឃៅមានចំនួនតិចតួចបំផុត ហើយការទទួលបានព័ត៌មានទាំងនោះផ្អែកលើពាក្យចចាមអារ៉ាម និងរបាយការណ៍ដែលទទួលបានមកពីសមភាគីកម្ពុជា ។

## សញ្ញាបញ្ហា

ថ្វីបើមានការដាក់កំហិតលើមន្ត្រីចិន វាច្បាស់ដែលថា ការផ្លាស់ប្តូរគោលនយោបាយត្រូវបានធ្វើឡើង ។ គណៈប្រតិភូចិនដែលមកដល់បានយល់ឃើញថា ទីក្រុងភ្នំពេញស្ទើរតែជាវាលរហោឋាន ហើយមេដឹកនាំរបបកម្ពុជាប្រជាធិបតេយ្យបានកម្ទេចរូបិយប័ណ្ណដែលប្រទេសចិនបានបោះពុម្ពឲ្យ ។ ឥរិយាបទរបស់របបកម្ពុជាប្រជាធិបតេយ្យ បានធ្វើឲ្យប្រទេសចិនមានវិបត្តិការទូតនៅពេលដែលកងកម្លាំងប្រដាប់អាវុធខ្មែរក្រហម បានរឹបអូសយកនាវាដឹកទំនិញដែលគ្មានបំពាក់អាវុធឈ្មោះម៉ាយ៉ាហ្គេនៅក្នុងដែនទឹកអន្តរ

ជាតិនាពាក់កណ្ដាលខែឧសភា ដែលជាគ្រោះថ្នាក់មួយដែលជំរុញឲ្យប្រទេសចិនប្រយ័ត្នប្រយែងចំពោះការការពារសម្ព័ន្ធមិត្តថ្មីរបស់ខ្លួន និងការជៀសផុតពីជម្លោះជាមួយសហរដ្ឋអាមេរិក ។

ជាជាងការជំរុញឲ្យខ្មែរក្រហមកែប្រែគោលនយោបាយ ចិនបានប្រញាប់គាំទ្រសម្ព័ន្ធភាពរបស់ខ្លួន ដោយបញ្ជូននាវាយោធាទៅកំពង់សោម ភ្លាមបន្ទាប់ពីឧបហេតុរបស់នាវាម៉ាយ៉ាហ្គេ ។ យោងទៅតាមអតីតកម្មាភិបាលរបបកម្ពុជាប្រជាធិបតេយ្យ គេង លី ជំនួយផ្នែកសេដ្ឋកិច្ចបានចាប់ផ្ដើមហូរចូលស្រុកខ្មែរ ដូចជាស្រូវ អង្ករ ប្រេងសាំង និងផលិតផលដទៃទៀត ។ នាវាចិនដែលផ្ទុកទំនិញចាប់ពីពីរសែនទៅបួនសែនតោន បានចាប់ផ្ដើមមកដល់ជារៀងរាល់ខែជាមួយនឹងជំនួយ ។ ការដឹកជញ្ជូនដំបូង រួមមាន អង្ករ និងទំនិញ ហើយប្រទេសចិនត្រូវបានរាយការណ៍ថា បានចាប់ផ្ដើមផ្គត់ផ្គង់អាវុធផង ។ មេដឹកនាំចិនបានមើលឃើញការគាំទ្រប្រទេសកម្ពុជា ថាជារបបដ៏សំខាន់ប្រឆាំងទៅនឹងទំនាក់ទំនងជាមួយនឹងប្រទេសវៀតណាមដែលជាអតីតសម្ព័ន្ធមិត្ត ដែលបានងាកទៅរកទីក្រុងម៉ូស្គូអំឡុងពេលសង្គ្រាមនៅឥណ្ឌូចិនលើកទី២ អស់រយៈពេលជាច្រើនឆ្នាំ និងហានិភ័យនៃអនុត្តរភាពរបស់វៀតណាមក្នុងឥណ្ឌូចិន ។

ម៉ៅ សេទុង បង្ហាញការព្រួយបារម្ភអំពីគោលនយោបាយខ្មែរក្រហម ។ នៅក្នុងអង្គប្រជុំក្នុងទីក្រុងប៉េកាំង នៅខែមិថុនា ម៉ៅ សេទុង បានព្រមាន ប៉ុល ពត ថា “អ្នកមិនគួរចម្លងបទពិសោធន៍ប្រទេសចិន ហើយគួរតែគិតអំពីខ្លួនឯង» ។ យោងទៅតាម ម៉ាក្ស ទ្រីស្ដីរបស់ ម៉ៅ សេទុង គឺជាការចង្អុលបង្ហាញលើចំណាត់ការ ប៉ុន្តែមិនមែនជាលទ្ធិនោះឡើយ ។ ប៉ុន្តែ គាត់បានភ្ជាប់ការទូន្មានជាមួយនឹងការស្ដីបន្ទោសដោយនិយាយថា “អ្នកបានសម្រេចជោគជ័យលើអ្វីដែលយើងទទួលបរាជ័យ» ។ ម៉ៅ សេទុង បានសន្យាផ្ដល់ជំនួយយោធា និងសេដ្ឋកិច្ចមានតម្លៃមួយពាន់លានដុល្លារ រួមមានការផ្ដល់ជំនួយ២០លានដុល្លារភ្លាមៗ ដែលជាកញ្ចប់ជំនួយធំបំផុតក្នុងប្រវត្តិសាស្ត្រប្រទេសចិន ។

មានការលើកឡើងស្រដៀងគ្នា នៅខែសីហា នៅពេលដែល




កម្មាភិបាលខ្មែរក្រហមនិងកប៉ាល់ដឹកទំនិញរបស់ចិននៅពីខាងក្រោយដែលចូលមកសំចតនៅកំពង់ផែកំពង់សោម

របាយការណ៍អំពីការសម្លាប់នៅក្នុងប្រទេសកម្ពុជាបានកើនឡើងទ្វេដង ។ ជូ អេនឡាយ បានដាស់តឿនមេដឹកនាំរបបកម្ពុជាប្រជាធិបតេយ្យ ខៀវ សំផន និងអៀង ធីរិទ្ធ ថា

> អ្នកត្រូវតែប្រយ័ត្នប្រយែង ពីព្រោះនៅលើកំណាត់ផ្លូវទៅរកកុម្មុយនីស្ត មានជំហានគ្រោះថ្នាក់ជាច្រើន ។ ប្រសិនបើអ្នកមិនបានគិតលើវិធីសាស្ត្រឲ្យបានគ្រប់ជ្រុងជ្រោយ បន្ទាប់មកអ្នកនឹងនាំយកមហន្តរាយដល់ប្រជាជនកម្ពុជា ។ កុម្មុយនីស្ត គួរតែជាដូចការដូដែលពោរពេញទៅដោយស្វ័យតភាព និងសេរីភាពដែលអ្នកឲ្យអ្នកដទៃ ។

ការព្រមានរបស់ ជូ អេនឡាយ មិនមុតស្រួចនោះឡើយ ដោយសារការប្តេជ្ញារបស់ចិនក្នុងការមិនជ្រៀតជ្រែក ប៉ុន្តែវាមានឥទ្ធិពលតិចតួចបំផុត ។ យោងទៅតាមសម្តេចព្រះ នរោត្តម សីហនុ ដែលបានចូលរួមអង្គប្រជុំនោះ ខៀវ សំផន និង អៀង ធីរិទ្ធ បានឆ្លើយតបដោយញញឹម ។ ម៉ៅ សេទុង បានព្រមាន ខៀវ សំផន និង អៀង ធីរិទ្ធ អំពីគ្រោះថ្នាក់នៃសង្រ្គាមផ្ទៃក្នុងដែលជាពាក្យសម្រាលសម្រាប់គោលនយោបាយរបស់កម្ពុជាប្រជាធិបតេយ្យក្នុងការបន្ទាបតម្លៃសម្តេចព្រះ នរោត្តម សីហនុ តាមរយៈការបណ្តេញអតីតទាហាន លន់ នល់ ដែលបានផ្តាច់ខ្លួនមកចូលរួមបដិវត្តន៍ ហើយបានសម្លាប់ ឬចាប់ដាក់គុកកម្មាភិបាលដែលគាំទ្រវៀតណាម ។ ណុត ជឹម ជំនួយការសារព័ត៌មានរបស់សម្តេចព្រះ នរោត្តម សីហនុ បានអះអាងថា ចិនមានការព្រួយបារម្ភ ។ ចិនបាននិយាយថា ខ្មែរក្រហមដើរលឿនពេក ខ្មែរក្រហមមិនបានគាំទ្រចិនដែលជាជនប្រាកដនិយមនៅពេលដែលធ្វើបដិវត្តន៍ឡើយ ។

ចិនបានធានានូវការធ្វើសម្បទានគោលនយោបាយមេដឹកនាំកម្ពុជាប្រជាធិបតេយ្យ ប៉ុន្តែផ្តោតលើការងារការបរទេស ។ នៅខែសីហា ខៀវ សំផន និងតំណាងរបស់សាធារណរដ្ឋប្រជាមានិតចិនបានចុះហត្ថលេខាលើសេចក្តីថ្លែងការណ៍រួមដែលឆ្លុះបញ្ចាំងគោលនយោបាយអន្តរជាតិរបស់ប្រទេសចិនទាំងស្រុង ដែលជាការនិយាយសំដៅទៅរកការគាំទ្ររបស់ខ្មែរក្រហមលើគោលការណ៍



អៀង សារី (កណ្តាល) និង ឡុង នរិន្ទ កម្មាភិបាលនៅក្រសួងការបរទេសនៃរបបខ្មែរក្រហម កំពុងពិភាក្សាជាមួយ ជូ អេនឡាយ (ឆ្វេង) នៅទីក្រុងប៉េកាំង

មជ្ឈិមនៃគោលនយោបាយការបរទេសរបស់សាធារណរដ្ឋប្រជាមានិតចិន ។ ខ្មែរក្រហមបានយល់ស្របក្នុងការប្រើចំណាត់ការគោលនយោបាយការបរទេសក្នុងការប្រឆាំងទៅនឹងឥទ្ធិពលរបស់វៀតណាមដូចជាការបន្តការផ្សះផ្សាជាមួយនឹងប្រទេសថៃ និងការបើកគោលនយោបាយទំនាក់ទំនងជាមួយនឹងទីក្រុងវ៉ាស៊ីងតោន ។ សូម្បីតែកិច្ចការងារបរទេសមន្ត្រីរបបកម្ពុជាប្រជាធិបតេយ្យ បន្តអះអាងអំពីឯករាជ្យ ការប្រកាន់យកគោលនយោបាយប្រឆាំងជនចក្រពត្តិ ប៉ុន្តែបដិសេធមិនទទួលស្គាល់ការប្រកួតប្រជែងជាមួយនឹងអំណាចកុម្មុយនីស្ត ។

កិច្ចខិតខំប្រឹងប្រែងរបស់ចិនដើម្បីជំរុញឲ្យមានការដាក់កំហិតក្នុងរបបកម្ពុជាប្រជាធិបតេយ្យមិនបានទទួលជោគជ័យឡើយ ។ សាធារណរដ្ឋប្រជាមានិតចិនបានបញ្ចុះបញ្ចូលមេដឹកនាំរបបកម្ពុជាប្រជាធិបតេយ្យឲ្យអនុញ្ញាតឲ្យសម្តេចព្រះ នរោត្តម សីហនុ យាងមកប្រទេសកម្ពុជាវិញ ដោយសង្ឃឹមថា ព្រះអង្គនឹងមានឥទ្ធិពលកែប្រែបង្កើនភាពស្របច្បាប់របស់របបកម្ពុជាប្រជាធិបតេយ្យក្នុងកម្រិតអន្តរជាតិ និងបង្កើនឥទ្ធិពលរបស់ប្រទេសចិន លើការកម្ទេចក្រុមគាំទ្រទីក្រុងហាណូយ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ដោយត្រឡប់មកវិញក្នុងខែកញ្ញា សម្តេចព្រះ នរោត្តម សីហនុ បានបដិសេធទៅនឹងគោលនយោបាយឃោរឃៅរបស់ខ្មែរក្រហម ប៉ុន្តែបានអះអាងថា «ខ្ញុំត្រូវលះបង់ខ្លួនឯងដើម្បីប្រទេសចិននិងឯកឧត្តម ជូ អេនឡាយ ដែលបានជួយប្រទេសកម្ពុជា និងរូបខ្ញុំយ៉ាងច្រើន» ។ ការមកដល់របស់ព្រះអង្គបានជះឥទ្ធិពលតិចតួចដោយសារខ្មែរក្រហមបានឃុំឃាំងព្រះអង្គនៅក្នុងវាំង ហើយមិនបានផ្តល់តួនាទីសំខាន់ណាមួយក្នុងជួររដ្ឋាភិបាលឡើយ ។ ផ្ទុយទៅវិញ អំណាចនៅក្នុងគណៈអចិន្ត្រៃយ៍របស់បក្សកុម្មុយនីស្តកម្ពុជាថ្មីបានប្រគល់ឲ្យ ប៉ុល ពត, នួន ជា និងអ្នកផ្សេងទៀតរួមមាន ខៀវ សំផន, អៀង សារី និង អៀង ធីរិទ្ធ ។

ដោយប្រឈមមុខទៅនឹងការប្រឆាំងរបស់ខ្មែរក្រហម ប្រទេសចិនបានបន្តបញ្ជូនជំនួយ ។ ភ្លាមៗបន្ទាប់ពីសេចក្តីថ្លែងការណ៍រួមនៅខែសីហា ក្រុមជំនាញមកពីក្រសួងការពារជាតិនៃសាធារណរដ្ឋប្រជាមានិតចិនបានមកប្រទេសកម្ពុជាដើម្បីស្ទាបស្ទង់អំពីតម្រូវការក្នុងការការពាររបបកម្ពុជាប្រជាធិបតេយ្យ ។ ក្នុងខែតុលា អនុប្រធានបក្សចិន លោក វាង សានរុង បានធ្វើដំណើរទៅទីក្រុងភ្នំពេញ ហើយបានប្រកាសផែនការព្រៀងស្តីពីជំនួយផ្នែកយោធា ។ ពាណិជ្ជកម្មរបស់ចិនបានកើនឡើង ហើយអតីតមន្ត្រីរបបកម្ពុជាប្រជាធិបតេយ្យ ដែលធ្វើការនៅខេត្តកំពង់សោម ប៉ាន់ស្មានថា ច្រើនជាង៨០ភាគរយនៃការនាំចូលទំនិញមកកាន់ប្រទេសកម្ពុជា ពីប្រទេសចិននៅចន្លោះឆ្នាំ១៩៧៥ ដល់១៩៧៦ ។ អតីតកម្មាភិបាលនៅក្រសួងពាណិជ្ជកម្មរបស់កម្ពុជាប្រជាធិបតេយ្យបានរាយការណ៍ថា របបកម្ពុជាប្រជាធិបតេយ្យបានបញ្ជូនទំនិញជាស្រូវ អង្ករផលិតផលជាគ្រាប់ធញ្ញជាតិ និងសម្ភារដទៃទៅប្រទេសចិនជាថ្នូរទៅនឹងគ្រឿងចក្រ ។

មកត្រឹមពេលឡើងកាន់អំណាចក្នុងឆ្នាំ១៩៧៥ ទំនាក់ទំនងរវាងប្រទេសចិននិងរបបកម្ពុជាប្រជាធិបតេយ្យត្រូវបានផ្លាស់ប្តូរ មេដឹកនាំរបបកម្ពុជាប្រជាធិបតេយ្យនឹងទទួលយកជំនួយរបស់ចិន និងការបង្ហាត់បង្ហាញផ្នែកបច្ចេកទេស ប៉ុន្តែបានការពារសេរីភាពគោលនយោបាយរបស់ខ្លួនយ៉ាងម៉ឺងម៉ាត់ ។ ប្រទេសចិនបានជំរុញឲ្យមានការកែសម្រួលជំនួយដែលលើសចំនួនដល់ខ្មែរក្រហម ប៉ុន្តែមិនគំរាមកាត់បន្ថយជំនួយនោះឡើយ ។ លោក រូបើត រ៉ូស លើកឡើងពីចំណាប់អារម្មណ៍របស់ប្រទេសចិនលើការប្រៀបធៀបកម្លាំងរបស់ប្រទេសកម្ពុជាទៅនឹងសម្ព័ន្ធមិត្តសូវៀត-វៀតណាម បានធ្វើឲ្យមានការទាស់ចិត្តនិងការភ្ញាក់ផ្អើលដល់ប្រទេសចិនចំពោះអំពើឃោរឃៅដែលបានបង្កឡើងដោយខ្មែរក្រហម ។ ទង្វើរបស់ប្រទេសចិនបានបង្ហាញថា អាទិភាពទីក្រុងប៉េកាំង គឺត្រូវការពារសម្ព័ន្ធមិត្ត ដែលជាវិធីសាស្ត្រមួយកែប្រែភាពទន់ខ្សោយរបបកម្ពុជាប្រជាធិបតេយ្យឲ្យទៅជារបបមួយដែលមានឥទ្ធិពលនិងជាវិធីសាស្ត្រមួយដែលលុបបំបាត់ចោលការមិនស្របរបស់ប្រទេសចិន ។

## ការគាំទ្រដោយឥតលក្ខខណ្ឌ

នៅខែកុម្ភៈ ឆ្នាំ១៩៧៦ វាង សានរុង បានត្រឡប់ទៅទីក្រុងភ្នំពេញ ហើយបានសម្រេចកិច្ចព្រមព្រៀងជំនួយយោធា ដែល ប៉ុល ពត បានចាប់ផ្តើមចរចារជាមួយនឹងលោក តេង ស៊ីវភីង កាលពីខែឧសភា ឆ្នាំ១៩៧៥ ។ យោងតាមឯកសារមួយដែលបានបង្ហាញនៅតុលាការឆ្នាំ១៩៧៩ លោក វាង បានប្រាប់រដ្ឋមន្ត្រីការពារជាតិនៃរបបកម្ពុជាប្រជាធិបតេយ្យ សុន សេន ថា ចិន

គ្រោងនឹងផ្តល់អ្នកប្រឹក្សាផ្នែកយោធាចំនួន៣២០នាក់ សម្ភារដើម្បីតម្លើងរ៉ាដា កាំភ្លើងធំ និងអាកាសយានដ្ឋាន យោធា កប៉ាល់អមបួន និងកប៉ាល់ចម្បាំង សម្ភារសម្រាប់កងនាវាធំ កាំភ្លើងធំសម្រាប់កងវរសេនាធំទៀត ។ លោក វាង បាននិយាយដែរថា ប្រទេសចិននឹងទទួលខុសត្រូវចំពោះការសាងសង់មូលដ្ឋាននាវា អាកាសយានដ្ឋាន ឃ្លាំងផ្ទុកគ្រាប់ និងការបង្កើនសម្បទាផ្លូវដុលអាវុធ ។ ជំនួយរបស់សាធារណរដ្ឋប្រជាមានិតចិននឹងត្រូវផ្តល់ដោយឥតលក្ខខណ្ឌ៖

*វាស្រេចលើរដ្ឋាភិបាលកម្ពុជាក្នុងការសម្រេចចិត្តថាតើជំនួយផ្នែកយោធារបស់ប្រទេសចិន និងការផ្គត់ផ្គង់ត្រូវធ្វើឡើងនិងប្រើប្រាស់ដោយរបៀបណា ។ ប្រទេសចិននឹងមិនជ្រៀតជ្រែក មិនដាក់លក្ខខណ្ឌនិងមិនទាមទារសិទ្ធិពិសេសណាមួយឡើយ ។*

ក្នុងខែកុម្ភៈ ឆ្នាំ២០១២ ដោយផ្តល់សក្ខីកម្មនៅពេលជំនុំជម្រះនៅក្នុងតុលាការខ្មែរក្រហម អតីតអនុលេខាបក្សកុម្មុយនីស្តកម្ពុជា នួន ជា បានសង្កត់ធ្ងន់លើជំនួយចិនដោយឥតលក្ខខណ្ឌ ។ ជនជាប់ចោទ នួន ជា បាននិយាយថា ប្រទេសចិនបានផ្តល់អាវុធធុនស្រាលឲ្យយើង ប៉ុន្តែមិនដែលលក់អាវុធឲ្យរបបកម្ពុជាប្រជាធិបតេយ្យនោះឡើយ ។ គាត់បានបន្ថែមថា «មិនមានជំនួយផ្នែកនយោបាយនោះឡើយ មានតែជំនួយផ្នែកបច្ចេកទេស តែប៉ុណ្ណោះ ដែលផ្តល់ដោយសាធារណរដ្ឋប្រជាមានិតចិន ដូចជា ជួយជួសជុលផ្លូវដែក ។ បើតាមខ្ញុំដឹង ជំនួយមកពីចិន ដូចជា ជំនួយផ្នែកយោធាសម្លៀកបំពាក់ ឬវាយនភ័ណ្ឌត្រូវបានផ្តល់ដោយឥតលក្ខខណ្ឌ» ។ ដូច្នេះហើយ សក្ខីកម្មរបស់ នួន ជា ដូចទៅនឹងការប្រកាសរបស់ប្រទេសចិនជាផ្លូវការ ទោះបីជាការលើកឡើងទាំងពីរអាចជាការបំផ្លើស ដែលជំនួយនោះគ្មានលក្ខខណ្ឌ ។

ជំនួយដោយឥតលក្ខខណ្ឌមិនបានធ្វើឲ្យសាធារណរដ្ឋប្រជាមានិតចិនរួចពីការសង្ស័យនោះឡើយ ។ ក្នុងឆ្នាំ១៩៧៦ រដ្ឋធម្មនុញ្ញរបស់របបកម្ពុជាប្រជាធិបតេយ្យថ្មីបានលើកឡើងថា របបកម្ពុជា


កម្មាភិបាលខ្មែរក្រហមនិងជំនាញការចិនក្នុងរបបខ្មែរក្រហម

ប្រជាធិបតេយ្យ នឹងតស៊ូប្រឆាំងទៅនឹងការជ្រៀតជ្រែករបស់ប្រទេសដទៃក្នុងកិច្ចការផ្ទៃក្នុងរបស់ខ្លួនរួមមានការធ្វើអន្តរាគមន៍ផ្នែកយោធា នយោបាយ វប្បធម៌ សេដ្ឋកិច្ច សង្គម ការទូត និងមនុស្សធម៌ ។ ឡូវ៉ែង ពិក ដែលជាប្រពន្ធសញ្ជាតិបារាំងរបស់កម្មាភិបាលខ្មែរក្រហមមួយរូបបានចងចាំថា បន្ទាប់ពីការប្រកាសការស្លាប់របស់ ជូ អេនឡាយ តាមវិទ្យុក្រុងភ្នំពេញនៅខែមករា ឆ្នាំ១៩៧៦ កម្មាភិបាលខ្មែរក្រហមបានចេញសេចក្តីក្រើនរំឭកថា «យើងត្រូវតែប្រយ័ត្នប្រយែងនឹងប្រទេសចិន ពិតប្រាកដណាស់ យើងបានជំពាក់គុណប្រទេសចិនយ៉ាងច្រើន ហើយប្រទេសចិនគឺជាប្រទេសដ៏អស្ចារ្យមួយ ប៉ុន្តែប្រទេសនោះចង់កែប្រែយើងឲ្យទៅជាប្រទេសរណបរបស់ខ្លួនដែរ» ។

តួនាទីរបស់សម្តេចព្រះ នរោត្តម សីហនុ នៅតែជាបញ្ហានៃភាពតានតឹង ។ ព្រះអង្គបានខឹងសម្បារទៅនឹងការដាក់កំហិតសេរីភាពនេះ ។ របាយការណ៍នៃអង្គប្រជុំគណៈអចិន្ត្រៃយ៍របស់របបកម្ពុជាប្រជាធិបតេយ្យនាពាក់កណ្តាលខែមីនា ឆ្នាំ១៩៧៦ បានបង្ហាញថា មេដឹកនាំខ្មែរក្រហមបានខិតខំគ្រប់គ្រងហានិភ័យ ។ គណៈអចិន្ត្រៃយ៍បានសន្និដ្ឋានថា «ប្រសិនបើព្រះអង្គលាលែងពីតំណែង យើងនឹងមិនអនុញ្ញាតឲ្យព្រះអង្គចាកចេញពីប្រទេសឡើយ ។ ការចាកចេញរបស់ព្រះអង្គនឹងបង្កស្ថានភាពស្មុគស្មាញដល់ប្រទេសចិន» ហើយក៏បានសម្រេចចិត្តថានឹងឃុំឃាំងព្រះអង្គនៅក្នុងវាំង ។ នោះគឺជាអ្វីដែលបានកើតឡើង ប៉ុន្តែប្រទេសចិនមិនបានជំទាស់នោះឡើយ ប្រហែលជាដោយសារការប្រឆាំងផ្ទៃក្នុងរបស់ខ្លួននិងការងើបឡើងនៃក្រុមពួកទាំងបួននាក់នៅដើមខែមេសាផង ។

បដិវត្តន៍ក្រុមពួកទាំងបួននាក់ ដែលបានបន្សុទ្ធ តេង ស៊ីវភីង ហើយបានធ្វើឲ្យមានភាពរីកវររយៈពេលប្រាំមួយខែមុនពេលដែល ម៉ៅ សេទុង ស្លាប់នៅខែកញ្ញា ហើយការត្រឡប់មកសាជាថ្មីរបស់ តេង ស៊ីវភីង នៅខែតុលា គឺកាន់តែព្រមទទួលយកគោលនយោបាយរបបកម្ពុជាប្រជាធិបតេយ្យ ។ ក្រុមពួកទាំងបួននាក់បានប្រកាន់យកមាគ៌ាតឹងតែងចំពោះប្រទេសវៀតណាម ដោយទាមទារថា លេខាបក្ស ឡេ យន់ គួរតែប្រកាស «ការធ្វើអនុត្តរភាព» របស់សូវៀត ដែលធ្វើឲ្យក្រុងហាណូយមានទំនោរទៅរកក្រុងម៉ូស្គូ ហើយបង្កើនការពឹងផ្អែករបស់ប្រទេសចិនលើប្រទេសកម្ពុជា ។

នៅខែឧសភា ថ្វីបើមានភាពភ័យខ្លាចចំពោះការកើនឡើងក្រុមគាំទ្រក្រុងហាណូយក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ចិនបានយល់ស្របសាងសង់រោងចក្រផលិតអាវុធថ្មីមួយដ៏សម្ងាត់ក្បែរក្រុងភ្នំពេញ ។ នៅខែមិថុនា របាយការណ៍របស់បក្សកុម្មុយនីស្តកម្ពុជាជូនចំពោះមេដឹកនាំយោធា បានរាយការណ៍អំពីការសន្យារបស់មន្ត្រីស្ថានទូតចិន ដែលថា ប្រទេសចិននឹងដឹកជញ្ជូនសម្ភារយោធាប្រហែល ១.០០០តោន ទៅខេត្តកំពង់សោមនៅចុងខែមិថុនា ឬដើមខែកក្កដា រួមមានរថក្រោះម៉្លៃគ្រឿង រថពាសដែកខ្នាតតូចដប់គ្រឿង រថយន្តយោធា គ្រាប់កាំភ្លើងរាប់សែន ឧបករណ៍បញ្ជូនព័ត៌មាន ឧបករណ៍សាងសង់ និងឧបករណ៍ដទៃទៀត ។

មេដឹកនាំរបបកម្ពុជាប្រជាធិបតេយ្យ បានបន្តស្វាគមន៍ជំនួយរបស់ប្រទេសចិន ប៉ុន្តែបន្តភ័យខ្លាចចំពោះការពឹងផ្អែកលើប្រទេសចិន ។ នៅក្នុងកិច្ចប្រជុំបក្សនៅខែមិថុនា ឆ្នាំ១៩៧៦ មន្ត្រីជាន់ខ្ពស់បក្សកុម្មុយនីស្តកម្ពុជាបាននិយាយថា «ប្រសិនបើយើងរឹងមាំនិងមិនផ្តោះទៅមុខលឿននោះទេ សត្រូវខាងក្រៅនឹងរង់ចាំកម្ទេចយើង ។ ប្រទេសទាំងអស់ចង់បានប្រទេសតូចធ្វើជាអ្នកបម្រើរបស់ខ្លួន» ។ នៅខែកក្កដា មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា បានអនុម័តផែនការបួនឆ្នាំដើម្បីចង្អុលបង្ហាញពីគោលនយោបាយជាតិហើយបានបញ្ជាក់អំពីតម្រូវការដល់មិត្តបរទេសដើម្បីជួយនិងគាំទ្រខ្លួន ប៉ុន្តែបានបន្ថែមថា៖

*នេះគឺជាជំនួយរបស់ប្រទេសចិនមួយចំនួន ប៉ុន្តែមិនមានអ្វីច្រើននោះឡើយបើប្រៀបធៀបប្រទេសដទៃ ។ នេះគឺជាគោលនយោបាយរបស់បក្សយើង ។ ប្រសិនបើយើងស្នើសុំជំនួយ ពិតប្រាកដណាស់ យើងនឹងទទួលបានមួយចំនួន ប៉ុន្តែប្រការនេះនឹងធ្វើឲ្យប៉ះពាល់ដល់មាគ៌ាគោលនយោបាយរបស់យើង ។ វាមិនងាយក្នុងការស្នើសុំប្រជាជនរុស្ស៊ីនោះឡើយ ។ ប្រទេសវៀតណាមនឹងស្នើសុំប្រជាជនរុស្ស៊ី ។ យើងមិនធ្វើតាមវៀតណាមឡើយ ។ ប្រសិនបើយើងស្នើសុំជំនួយតិចតួចឬច្រើនពីសូវៀត នោះនឹងមានលក្ខខណ្ឌនយោបាយណាមួយមកលើយើងជាមិនខានដោយជៀសមិនផុត*

ឡើយ ។

សូម្បីតែនៅក្នុងអំឡុងពេលការបង្អត់អាហារទ្រង់ទ្រាយធំក្នុងឆ្នាំ១៩៧៧ របបកម្ពុជាប្រជាធិបតេយ្យបានពន្យល់អំពីការស្ទាក់ស្ទើររបស់ខ្លួនដើម្បីទទួលយកជំនួយស្បៀងអាហារបរទេសដូចខាងក្រោមៈ

*អង្គការ មិនចង់ពុះអ្វីមួយអំពីជំនួយបរទេស ដោយសារគោលការណ៍មូលដ្ឋានរបស់យើងគឺជាអ្នកកំណត់ជោគវាសនារបស់យើង ហើយត្រូវផ្អែកលើភាពខ្លាំង និងធនធានរបស់យើងឡើយ ។ ប្រសិនបើយើងរំដោះប្រទេសយើង ហើយតើហេតុអ្វីបានជាយើងបាត់បង់ឯករាជ្យ និងសេចក្តីថ្លៃថ្នូរ? ពិតប្រាកដណាស់ ប្រទេសយើងមិនមានឯករាជ្យអស់ពេលជាច្រើនសតវត្សរ៍រួចហើយ ដោយសារយើងសុំទៅនឹងការពឹងផ្អែកលើអ្នកដទៃ ។ យើងត្រូវតែដឹងថាបរទេសមិនដែលផ្តល់អ្វីមួយដោយឥតប្រយោជន៍នោះទេ ។ ប្រសិនបើយើងមានឯករាជ្យ យើងនឹងមិនចរចាសេរីភាពរបស់យើងជាមួយនឹងជំនួយនោះឡើយ ។*

ពេលខ្លះ មន្ត្រីចិនបានខកចិត្តដោយសារការបដិសេធរបស់ខ្មែរក្រហមមិនទទួលយកជំនួយ និងដំបូន្មាន ។ នៅពេលដែលមន្ត្រីចិន លោក ហ្វាង យ៉ី ធ្វើដំណើរទៅភ្នំពេញនៅខែធ្នូឆ្នាំ១៩៧៦ គាត់បានអះអាងថា ខ្មែរក្រហមបានលើកស្ទួយហួសហេតុលើការពឹងផ្អែកលើខ្លួនឯង ដោយកត់សម្គាល់ថា របបកម្ពុជាប្រជាធិបតេយ្យមិនបានប្រើប្រាស់ជំនួយស្បៀងដែលមានតម្លៃ២០លានដុល្លារដែលសាធារណរដ្ឋប្រជាមានិតចិនបានផ្តល់ឲ្យនៅឆ្នាំ១៩៧៥នោះឡើយ ។ មន្ត្រីចិនបានជឿថា ខ្មែរក្រហមបានអនុវត្តគោលនយោបាយកសិកម្ម និងការពឹងផ្អែកលើខ្លួនឯងហួសហេតុ ។

ទោះបីជាយ៉ាងណាក៏ដោយ ជាទូទៅ ចិនបានដើរតួនាទីតាមរយៈការគ្រប់គ្រងដោយមិនជ្រៀតជ្រែក ដោយសារបទពិសោធន៍នៃការរងគ្រោះរបស់ខ្លួន ។ សូភី រីឆាតសាន់ លើកឡើងជាហេតុផលថា គោលការណ៍សហសន្តិវិជ្ជមានទាំងប្រាំយ៉ាងរបស់ប្រទេសចិនដែលកត់សម្គាល់លើអធិបតេយ្យភាព បូរណភាពទឹកដី និងការមិនជ្រៀតជ្រែក បានធ្វើឲ្យក្រុងប៉េកាំងប្រព្រឹត្តដាក់របបថ្មីដូចទៅនឹងរបបដទៃទៀត ហើយបានដាន់ឈ្លី សូម្បីតែបន្ទាប់ពីការស្តែងឲ្យឃើញនូវអំពើយង់ឃ្នង និងការគ្រប់គ្រងមិនបានល្អលើចំណូលដុល ។ ការប្រកាន់យកបទដ្ឋាននេះ គឺជាបញ្ហាមួយដែលហួសពីគោលការណ៍ ។ ការប្រកាន់យកបទដ្ឋាននេះបានជួយប្រទេសចិនកសាងឥទ្ធិពលក្នុងការកសាងប្រទេសដែលការពារអធិបតេយ្យភាពរបស់ខ្លួនជាវិធីសាស្ត្រមួយបន្តផ្តល់ផលប្រយោជន៍ដល់សាធារណរដ្ឋប្រជាមានិតចិនរាពេលសព្វថ្ងៃ ។


សុន សេន (អាវខ្មៅពាក់វ៉ែនតា) កំពុងត្រួតពិនិត្យកាំភ្លើងធំជាមួយថ្នាក់ដឹកនាំចិនក្នុងអំឡុងដំណើរទស្សនកិច្ចនៅប្រទេសកម្ពុជា

**(នៅមានត)**

**ចន ឆរឆីអារី**

# រស់ ផាត អតីតលេខាស្រុកសេរីសោភ័ណ្ឌ



រស់ ផាត (ស្តាំ) និងប្រពន្ធទីមួយឈ្មោះ ផល និងកូនស្រីក្នុងឆ្នាំ១៩៧៧

នេះគឺជារូបថតរបស់ រស់ ផាត និងប្រពន្ធរបស់គាត់ឈ្មោះ ផល ព្រមទាំងកូនស្រីរបស់គាត់ ដែលមានអាយុប្រមាណមួយឆ្នាំ ។ រស់ ផាត គឺជាអតីតលេខាស្រុកសេរីសោភ័ណ្ឌ តំបន់៥ ភូមិភាគពាយ័ព្យក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ចំណែក ផល គឺជាអតីតលេខាឃុំទឹកថ្លា ស្រុកសេរីសោភ័ណ្ឌ ។ ផាត ទើបតែស្លាប់ថ្មីៗនេះប៉ុណ្ណោះ គឺនៅថ្ងៃទី១២ ខែឧសភា ឆ្នាំ២០១៣ កន្លងទៅដោយជំងឺ ។ រូបថតមួយសន្លឹកនេះបានព្យួរនៅលើជញ្ជាំងផ្ទះរបស់ ផាត និងប្រពន្ធទីពីររបស់គាត់ឈ្មោះ ប្រុញ ទុំ អាយុ៥៨ឆ្នាំ នៅស្រុកភ្នំព្រឹក ខេត្តបាត់ដំបង ។ រូបថតនោះថតក្នុងឆ្នាំ១៩៧៧ ។

ទុំគឺជាអតីតនីសារបស់ផល ដែលជាប្រពន្ធទីមួយរបស់ផាត ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ទុំ បានរៀបរាប់ថា ផាត មានស្រុកកំណើតនៅឃុំសំឡាញ ស្រុកអង្គជ័យ ខេត្តកំពត ។ ក្នុងឆ្នាំ១៩៧០ ផាត បានស្ម័គ្រចិត្តចូលបម្រើបដិវត្តន៍ខ្មែរក្រហមនៅស្រុកត្រាំកក់ ខេត្តតាកែវ ។ ក្នុងឆ្នាំ១៩៧៤ ផាត រងរបួសត្រូវភ្នែកពេលគាត់កំពុងប្រយុទ្ធជាមួយទាហាន លន់ នល់ ក្នុងសមរភូមិធ្វើឲ្យភ្នែករបស់គាត់ខ្វាក់ជារៀងរហូតមក ។ ក្រោយខ្មែរក្រហមទទួលជ័យជម្នះក្នុងខែមេសា ឆ្នាំ១៩៧៥ ផាត ត្រូវបានចាត់តាំងទៅធ្វើការក្នុងអង្គភាពពិការនៅភូមិភាគនិរតី ហើយក្នុងឆ្នាំ១៩៧៦ គាត់បានរៀបការជាមួយ ផល (នៅក្នុងរូបថត) ។ ក្នុងឆ្នាំ១៩៧៧ តាម៉ុក បានបញ្ជូន ផាត និង ផល ទៅភូមិភាគពាយ័ព្យ ហើយតែងតាំង ផាត ជាលេខាស្រុកសេរីសោភណ្ឌ ក្នុងតំបន់៥ ចំណែកឯ ផល វិញ ត្រូវបានតែងតាំងជាលេខាឃុំទឹកថ្លាក្នុងស្រុកសេរីសោភ័ណ្ឌ ។

ទុំ បានបញ្ជាក់ទៀតថា ថ្ងៃមួយក្នុងឆ្នាំ១៩៧៧ គណៈប្រតិភូចិនមួយក្រុមបានមកធ្វើទស្សនកិច្ចតំបន់៥ ហើយបានថតរូបជាច្រើនប៉ុស្តិ៍ តែជាអកុសល រូបថតស្ទើរតែទាំងអស់បានបាត់បង់អស់ លើកលែងតែរូបថតមួយសន្លឹកនេះប៉ុណ្ណោះ ។

ផល ហើយនិងកូនស្រីបានស្លាប់នៅក្នុងព្រៃជិតព្រំដែនថៃដោយជំងឺគ្រុនចាញ់ក្នុងឆ្នាំ១៩៧៩ ពេលគាត់រត់គេចពីទាហានវៀតណាម ។ ក្រោយមកក្នុងឆ្នាំ១៩៨០ ផាត បានរៀបការជាមួយទុំ ។ ផាត និង ទុំ មានកូនស្រីបីនាក់ និងកូនប្រុសបួននាក់ ។



ប្រុញ ទុំ

**ឡុង ដានី**

# សុខចិត្តយកប្តីដើម្បីគេចពីការសម្លាប់

ឋិតក្នុងសម្លៀកបំពាក់សំពត់សម្ពុយ និងអាវយឺតកម្មូល បែរមុខសម្លឹងមើលសាលសវនាការខ្មែរក្រហម លិន ធា អង្គុយដាក់ដៃចុះក្រោមហាក់បីដូចជាប្រុងប្រៀបរង់ចាំអ្វីមួយ ។ ជាមួយទឹកមុខស្រងូតស្រងាត់ ធា ចង់និយាយពីបទពិសោធន៍ដែលគាត់បានឆ្លងកាត់ក្នុងរបបខ្មែរក្រហម ដែលស្ទើរតែឆក់យកជីវិតគាត់ទៅហើយ ។

ធា មានអាយុ៥៦ឆ្នាំ ហើយប្រកបរបរធ្វើស្រែចម្ការ នៅក្រុងត្បែងមានជ័យ ខេត្តព្រះវិហារ ។ គាត់ជាកូនទីបួន ក្នុងចំណោមបងប្អូនប្រាំនាក់ (ប្រុសពីរ ស្រីបី) ដែលមានឪពុកម្តាយប្រកបមុខរបរធ្វើស្រែ ។


លិន ធា

ធា បាននិយាយរៀបរាប់ថា កាលពីជំនាន់សាធារណរដ្ឋខ្មែររបស់ លន់ នល់ មានការទម្លាក់គ្រាប់បែកជាច្រើននៅភូមិស្រុករបស់គាត់ ។ កាលនោះ គាត់មានអាយុប្រហែលដប់ឆ្នាំប៉ុណ្ណោះ និងរស់នៅស្រុកជាំក្សាន្ត ខេត្តព្រះវិហារ ។ ក្រោយមានភាពច្របូកច្របល់នៅថ្ងៃរដ្ឋប្រហារទម្លាក់សម្តេចព្រះនរោត្តម សីហនុ នៅខែមីនា ឆ្នាំ១៩៧០ ធ្វើឲ្យសាច់ញាតិបងប្អូនរបស់គាត់ភៀសខ្លួនទៅប្រទេសថៃ ។ តែគ្រួសាររបស់គាត់ ជាពិសេស ឪពុករបស់គាត់មិនចាកចេញទេ គឺស៊ូក្រាញរស់នៅក្នុងភូមិស្រុក ហើយម៉្យាងបារម្ភខ្លាចចោរលួចទ្រព្យសម្បត្តិ ។ បន្តិចក្រោយមក គ្រួសារគាត់បានរត់មករស់នៅឃុំប្រមេរ ស្រុកត្បែងមានជ័យ ខេត្តព្រះវិហារវិញ ។

ក្នុងអំឡុងនៃការទម្លាក់គ្រាប់បែក ធា ចាំថា គាត់ និងគ្រួសារបានរត់ចូលពួនក្នុងលេណដ្ឋានដើម្បីគេចពីអំបែងគ្រាប់ ។ ក្រោយមក គាត់បានបំបែកចេញពីគ្រួសារទៅធ្វើការក្នុងចល័តនារី ។

នៅក្នុងកងនារីចល័ត គាត់ត្រូវបានចាត់តាំងឲ្យធ្វើការងារពីមួយកន្លែងទៅមួយកន្លែងទៀតដោយគ្មានស្រាកស្រាន្ត ។ ចំណែកឯឪពុករបស់គាត់ ត្រូវបានចាត់តាំងឲ្យធ្វើការងារចងសំណាញ់ហើយម្តាយត្បាញកន្ទេល ។ ប្រធានសហករណ៍ឈ្មោះ តាបុង គឺជាអ្នកចាត់តាំងការងារដល់ប្រជាជនទាំងមូល ។ គាត់បន្តថា តាបុង ជាមនុស្សកំណាច មិនសូវបេះអត់ឱនឲ្យនរណាទេ ។ ដោយសារគាត់ជាមនុស្សមកពីស្រុកភូមិដទៃនោះ គាត់បានអនុវត្តគោលការណ៍សហករណ៍យ៉ាងម៉ឺងម៉ាត់ ។

ក្រោយមក គាត់ត្រូវបានចាត់តាំងឲ្យទៅធ្វើការលើកទំនប់នៅឆែបរយៈពេលពីរខែ ។ គាត់រៀបរាប់ថា “ការងារនៅឆែប លំបាកត្រង់ថា ទាំងអស់គ្នាមិនមានពេលឈប់សម្រាកទេ ។ កងនារីរបស់គាត់ត្រូវលើកទំនប់ទាំងយប់ទាំងថ្ងៃ ហើយទទួលបានតែបបររាវៗត្រឹមតែមួយចានប៉ុណ្ណោះក្នុងមួយពេល ។ ការងារលំបាកខ្លាំងតែ “មិនមាននរណាម្នាក់ហ៊ានងើបឡើងតវ៉ានឹងការហូបចុកទេ” ។ បន្ទាប់ពីបញ្ចប់ការងារលើកទំនប់នៅឆែប កងនារីចល័តរបស់គាត់ដែលមានសមាជិកប្រហែល៣០ ទៅ៤០នាក់ ត្រូវបានចាត់តាំងឲ្យមកស្ទូងស្រូវនៅក្នុងភូមិវិញ ។ កងនារីនោះត្រូវស្ទូងស្រូវទាំងថ្ងៃទាំងយប់ ។ គាត់បន្តថា “កម្មាភិបាលខ្មែរក្រហមបានដោតចន្ទុះ១០ដើមក្នុងស្រែមួយឲ្យកងនារីស្ទូង ហើយនៅពេលដែលស្ទូងរួចកម្មាភិបាលនោះដកចន្ទុះទៅដោតនៅស្រែផ្សេងដើម្បីឲ្យកងផ្សេងទៀតស្ទូងបន្ត ។ ដោយសារតែការនឿយហត់ កងនារីមួយចំនួន

បានឆ្មៀតទៅសម្រាកក្រោមដើមឈើ ។

ថ្ងៃបន្ទាប់ ឈ្លបពីរបីនាក់បានហៅកងនារីទាំងនោះទៅរៀនសូត្រជាច្រើនលើកច្រើនសា ។ ខ្លួនគាត់ផ្ទាល់ក៏ធ្លាប់កម្មាភិបាលយកទៅរៀនសូត្រដែរ តែសំណាងល្អគ្រាន់តែជាការព្រមានលើកទីមួយប៉ុណ្ណោះ ។ ធ្វើការនៅទីនោះអស់រយៈកាលយូរ ទើបគាត់ត្រូវបានប្រធានកងអនុញ្ញាតឲ្យមកលេងផ្ទះម្តង ។ គ្រាមួយ ពេលទៅដល់ផ្ទះ ឪពុករបស់គាត់បានយកដើមល្ហុងមកចិញ្ច្រាំ រួចហើយស្ងោរពូតទឹកចេញដាក់បបរជាមួយចុងអង្ករ ដែលគាត់សុំពីសហករណ៍ ។

គាត់បានបន្ថែមថា មានថ្ងៃមួយនោះ ប្រធានភូមិឈ្មោះ ដេត ចាត់តាំងមនុស្សចំនួន១៥នាក់ (ប្រុសប្រាំនាក់ និងស្រីដប់នាក់) ដែលក្នុងចំណោមនោះមានគាត់ម្នាក់ដែរឲ្យទៅជីកក្តួចដើម្បីធ្វើម្ហូបសម្រាប់សមាជិកក្នុងសហករណ៍ ។ ក្រោយពីចូលព្រៃជីកក្តួចអស់រយៈពេលដប់ថ្ងៃទើបក្រុមរបស់ ធា ត្រឡប់មកចូលក្នុងភូមិវិញ ។ ជាការតបស្នងទៅនឹងការខិតខំប្រឹងប្រែង ដេត លើកទឹកចិត្តឲ្យអង្ករពីរកំប៉ុងដល់ក្រុមរបស់គាត់ទាំងមូល ។ មេភូមិរូបនោះនិយាយថា «នេះអង្ករសម្រាប់មិត្តយកទៅបបរហូបឲ្យឆ្អែតម្តងបំណាច់ដែលមិត្តទាំងអស់គ្នាខំជីកក្តួចឲ្យសហករណ៍» ។

ថ្ងៃមួយ គាត់ត្រូវបានបង្ខំឲ្យរៀបការ តែដំបូងគាត់បានបដិសេធយ៉ាងដាច់អហង្ការ ព្រោះគ្រានោះគាត់មានវ័យ១៦ឆ្នាំប៉ុណ្ណោះ ។ គាត់មិនបានដឹងថាអ្វីជាស្នេហានោះទេ ។ គាត់បានបដិសេធម្តងជាពីរដង ។ ដោយសារតែគាត់បដិសេធញឹកញាប់ពេក កម្មាភិបាលខ្មែរក្រហមបានបើកអង្គប្រជុំ នៅពេលយប់ហើយបានហៅមនុស្សស្រីនិងប្រុសឡើងប្តេជ្ញា ។ កម្មាភិបាលក៏ឲ្យគាត់ប្តេជ្ញានៅពេលនោះដែរថារៀបការ ឬក៏អត់ ។ ពេលនោះគាត់នៅតែនិយាយថាមិនព្រមយកប្តីដដែល ។ កម្មាភិបាលម្នាក់បាននិយាយថា «បើមិនយកប្តីមានតែវាយចោល» និងនិយាយគំរាមទៀតថា «តើមិត្តព្រមយកប្តី ឬស្រឡាញ់អន្ទង់នេះ?» ។ ដោយខ្លាចកម្មាភិបាលសម្លាប់ចោល គាត់ក៏យល់ស្របរៀបការដោយពោលថា «ឲ្យគាត់រៀបការជាមួយឆ្កែឬឆ្មាក៏គាត់សុខចិត្តដែរ ឲ្យតែអង្គការរៀបចំ» ។

ថ្ងៃបន្ទាប់ ពិធីមង្គលការក៏ចូលមកដល់ ។ គាត់មិនដែលស្គាល់និងឃើញមុខប្តីរបស់ខ្លួនទាល់តែសោះ ។ ដល់ថ្ងៃរៀបការទើបគាត់ស្គាល់មុខប្តីរបស់គាត់ ដោយពេលនោះប្តីគាត់កំពុងតែដេកឈឺក្នុងភូមិ ហើយត្រូវមករៀបការទាំងខ្លួនឈឺទៀត ។ ប្តីរបស់គាត់គឺជាគ្រូពេទ្យ ។ នៅវេលាម៉ោងប្រហែលប្រាំល្ងាច ពិធីរៀបការរបស់គាត់ក៏បានរៀបចំឡើង ។ ថ្ងៃនោះមានគ្រួសារបីគូត្រូវរៀបការនៅពេលដំណាលគ្នា ។ ក្នុងពិធីនោះមានកាប់គោមួយក្បាល និងមាននំបញ្ចុក នំក្រូច និងនំផ្សេងទៀតផង ។ ក្រៅពីនោះ មានការរាំវែកនៅពេលយប់ទៀតផង ។ នៅក្នុងពិធីរៀបការដែលរៀបចំឡើង ដោយខ្មែរក្រហមនោះ មេភូមិឈ្មោះ ដេត សួរគាត់និងប្តីថាតើ «ស្រលាញ់ពិតប្រាកដមែនឬទេ» ។ ធា និងប្តីឆ្លើយព្រមគ្នាថា «ស្រលាញ់» ។

ទោះបីជាបានរៀបការជាមួយគ្នាក៏ដោយ ក៏ជីវិតរបស់គាត់ និងប្តីមិនបានរួមរស់នៅជិតស្និទ្ធគ្នានោះទេ ។ គាត់និងប្តីត្រូវរស់នៅបែកគ្នានៅក្នុងសហករណ៍រៀងៗខ្លួន និងនៅតែបន្តធ្វើការងារដដែល ។ គាត់នៅប្រូតស្រូវ រីឯប្តីគាត់ធ្វើជាគ្រូពេទ្យ ។ អ្នកទាំងពីរត្រូវនៅបែកគ្នា សូម្បីតែពេលឈឺ ក៏ប្តីរបស់គាត់មិនត្រូវបានអនុញ្ញាតឲ្យមកសួរសុខទុក្ខគាត់ដែរ ។ គាត់ត្រូវរស់នៅទីកន្លែងឆ្ងាយពីប្តី ។ គាត់បាននិយាយថា «ខ្ញុំនិងប្តីទទួលដំណឹងអំពីសុខទុក្ខគ្នាទៅវិញទៅមករយៈអ្នកភូមិ» ។ មួយខែបន្ទាប់ពីគាត់ផ្តល់កំណើតកូនទីមួយ ប្តីរបស់គាត់បានមកសួរសុខទុក្ខគាត់ម្តង ។ ជាអកុសល កូនរបស់គាត់មិនបានរស់រានមានជីវិតទេដោយសារតែគ្មានអ្នកមើលថែ ។ គាត់បន្តថា «ជំនាន់នោះមិនមានពេទ្យព្យាបាលត្រឹមត្រូវទេ ជំងឺណាក៏ដោយក៏ត្រូវផឹកថ្នាំអាចម៍ទន្សាយដែរ ។ ដូច្នេះហើយបានជាកូនគាត់មិនរស់» ។

នៅចុងឆ្នាំ១៩៧៨ ពេលដែលវៀតណាមវាយចូលមក កម្មាភិបាលខ្មែរក្រហមបានបំផុសថា ទាហានវៀតណាមនឹងមកវះពោះញាត់ស្មៅបើសិនជាវៀតណាមចាប់បាននរណាម្នាក់ ។ ព្ធដូច្នេះ អ្នកភូមិទាំងអស់បានរត់ចូលព្រៃមិនហ៊ានចូលភូមិទេ ។ ប្តីរបស់គាត់បានលបចូលមកក្នុងភូមិដើម្បីអង្កេតមើលវៀតណាម ហើយសង្កេតឃើញថា វៀតណាមមិនសម្លាប់មនុស្សទេ ។ ដោយឃើញសភាពការណ៍ដូចនេះ ប្រជាជនដទៃទៀតដែលរស់នៅក្នុងព្រៃបាននាំគ្នាត្រឡប់មករស់នៅក្នុងភូមិវិញ ។ ក្រុមគ្រួសាររបស់គាត់បានរស់នៅជួបជុំគ្នារហូតដល់សព្វថ្ងៃ ។ **ភួង ច័ន្ទប្រណិត**

# អាយុប្រាំឆ្នាំនៅថ្ងៃ១៧មេសា

អង្គុយនៅលើកៅអីនៅក្នុងបរិវេណគុកោសល្យខេត្តកំពត ជាមួយសម្លៀកបំពាក់អាវពណ៌សឆ្នូតខ្មៅ អ៊ុក ប៉ូឡូ រៀបរាប់ថា គាត់រស់នៅស្រុកអង្គរជ័យ ខេត្តកំពត ។ គាត់មានឪពុកឈ្មោះ អ៊ុក ហឹ ជាកសិករ និងម្តាយឈ្មោះ កែវ រិន ជាកសិករ ។ គាត់មានបងប្អូនចំនួនប្រាំពីរនាក់ ស្រីបួនប្រុសបីនាក់ ហើយគាត់មានអាយុត្រឹមតែប្រាំឆ្នាំ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ។

ប៉ូឡូ បន្តថា ក្រុមគ្រួសាររបស់គាត់ត្រូវបានខ្មែរក្រហមជម្លៀសឲ្យទៅរស់នៅឆ្ងាយពីភូមិកំណើតរបស់គាត់ ។ មុនពេលជម្លៀស ក្រុមគ្រួសាររបស់គាត់បានប្រមែរប្រមូលរៀបចំប្រដាប់ប្រដារប្រើប្រាស់មួយចំនួនមានដូចជា មុង ខ្នើយ ចាន ឆ្នាំង អង្ករ និងកង់ ព្រមទាំងសម្លៀកបំពាក់បន្តិចបន្តួច ។ ខណៈនោះ ឪពុករបស់គាត់ក៏បាន ប្រាប់កូនៗឲ្យរៀបចំឥវ៉ាន់ប្រញាប់ដើម្បីកុំខ្មែរក្រហមមកប្រាប់ម្តងទៀតព្រោះឪពុកគាត់បារម្ភខ្លាចខ្មែរក្រហមធ្វើបាប ។ គ្រួសាររបស់គាត់បានទៅរស់នៅសហករណ៍មួយដែលនៅទីនោះអង្គការ ប្រមូលទ្រព្យសម្បត្តិទាំងអស់មកដាក់ជារបស់រួម ។

សហករណ៍នោះ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់មេឃុំឈ្មោះ តា ស៊ីន (អ្នកភូមិរស់នៅស្រុកអង្គរជ័យ) ដែលបានបង្ខំឲ្យឪពុកម្តាយគាត់ធ្វើការគ្មានពេលសម្រាកឡើយ ។ តាស៊ីន បាននិយាយទៅកាន់ប្រជាជនថ្មីដែលរស់នៅក្នុងមូលដ្ឋានស្រុកអង្គរជ័យថា «បើសិនអង្គការដាក់ផែនការ ហើយសមមិត្តមិនព្រមធ្វើតាមបញ្ជាទេ នោះអង្គការនឹងយកទៅព្រៃជាមិនខាន» ។

មួយអាទិត្យបានកន្លងផុតទៅ ប្រធានសហករណ៍មានការសង្ស័យឪពុករបស់គាត់ ដោយចោទថា «ក្បត់ជាមួយនឹងអង្គការ» រួចក៏ផ្លាស់ឪពុកគាត់ឲ្យទៅរស់នៅស្រុកបុរីជលសារ ខេត្តតាកែវវិញ ។ មកដល់ខេត្តតាកែវ ឪពុករបស់ ប៉ូឡូ ត្រូវបានខ្មែរក្រហមបង្ខំឲ្យធ្វើស្រែទាំងយប់ទាំងថ្ងៃ ។ ប៉ុន្តែមិនយូរប៉ុន្មាន ឪពុករបស់គាត់ក៏បានផ្លាស់មករស់នៅជាមួយយុវជនកងចល័តរបស់ភូមិកំពង់អំពិលវិញ ដោយនៅទីនោះត្រូវបានអង្គការបង្ខំលើកទំនប់និងរែកដី ។ ខណៈនោះដែរ ប្រជាជនដែលនៅក្នុងកងជាមួយឪពុករបស់គាត់ត្រូវបានអង្គការហៅទៅរៀនសូត្រ និងបានបាត់ខ្លួនជាច្រើន ដែលធ្វើឲ្យឪពុកគាត់ភិតភ័យយ៉ាងខ្លាំង ព្រោះគិតថាមានថ្ងៃណាមួយនឹងប៉ះចំលើរូបគាត់មិនខាន ។ ដូច្នេះហើយទើប ឪពុកគាត់ខិតខំធ្វើការផាររតម្រូវចិត្តអង្គការ ទោះបីជាគាត់ស្ទេកស្ទាំងអស់កម្លាំងយ៉ាងណាក៏ដោយ ក៏គាត់នៅតែខិតខំប្រឹងធ្វើការឲ្យទាល់តែហើយតាមផែនការដែរ ។

រហូតមកដល់ឆ្នាំ១៩៧៦ ម្តាយរបស់គាត់ត្រូវបានអង្គការចាត់តាំងឲ្យទៅដាំបន្លែនៅស្រុកអង្គរជ័យ ដោយត្រូវបែកចេញពីឪពុករបស់គាត់ជាច្រើនខែ ។ ចំណែក គាត់ដែលស្ថិតនៅវ័យកុមារត្រូវអង្គការចាត់តាំងឲ្យរើសអាចម៍គោក្នុងមួយថ្ងៃឲ្យបានចំនួនប្រាំគីឡូ ដូចជាកុមារទូទៅដែរ ។ ក្រោយមក អង្គការបានមកប្រកាសតាមកងថា «ចាស់ៗ និងកុមារត្រូវទៅបេះសណ្តែកដី និងទៅដាំដំឡូងវិញ ។ ដោយសារតែធ្វើការហួសកម្លាំង និងគ្មានអាហារបរិភោគគ្រប់គ្រាន់ ពេលត្រឡប់មកពីសហករណ៍នៅពេលរសៀលគាត់ក៏សម្រេចចិត្តលួចយកសណ្តែកដីលាក់នៅក្នុងកន្សែងដៃដែលម្តាយគាត់ប្រគល់ឲ្យមុនពេលបែកគ្នា ។ ក្រោយមក គាត់ និងកុមារនៅក្នុងកងបាននាំគ្នាលួចបង្កាត់ភ្លើងដើម្បីស្ងោរសណ្តែកដីនៅក្នុងព្រៃស្ងាត់មួយកន្លែង ប៉ុន្តែជាអកុសល អង្គការដឹង ហើយចាប់វាយចំនួនប្រាំរំពាត់ផ្តៅម្នាក់ និងបានឲ្យបេ្តជ្ញាថាលែងលួចសណ្តែកដីរបស់អង្គការទៀត ។ ចាប់តាំងពីថ្ងៃនោះមក គាត់លែងហ៊ានលួចរបស់អង្គការព្រោះខ្លាចអង្គការចាប់យកទៅដាក់នៅមន្ទីរគាមាន់ដែលជាកន្លែងសម្លាប់ ។

នៅក្នុងឆ្នាំ១៩៧៧ អ៊ំប្រុសរបស់ ប៉ូឡូ ឈ្មោះ កែវ ប្រាក់ ជាគ្រូបង្រៀនត្រូវបានអង្គការបញ្ជាឲ្យទៅដឹកក្របីទៅធ្វើស្រែ រួចក៏ចាប់ខ្លួនអ៊ំរបស់គាត់យកទៅនៅមន្ទីរគាមាន់ក្នុងអង្គរជ័យដោយចោទថា «ជាខ្មាំងរបស់អង្គការ» ។ មុនពេលអង្គការចាប់ខ្លួន ប៉ូឡូ បានឃើញអ៊ំរបស់គាត់ដឹកក្របី ដើរកាត់មុខផ្ទះ ហើយបានសំពះ

លាម្តាយគាត់ «ដោយនិយាយខ្សិបៗថា ម៉ែ! បន្តិចទៀត អង្គការឲ្យដឹកក្របីទៅឯស្រែហើយ មិនដឹងថ្ងៃណាវិលមកវិញទេ ម៉ែ!» ។ ពេលឮសម្តីនោះភ្លាម ម្តាយគាត់មានអារម្មណ៍ក្តុកក្តួល ប៉ុន្តែមិនដឹងធ្វើយ៉ាងណាដើម្បីជួយកូនបាន ។ ចាប់តាំងពីនោះអ៊ីរបស់គាត់បានបាត់ខ្លួនរហូត ។

ក្នុងឆ្នាំ១៩៧៩ នៅពេលកងទ័ពរបស់វៀតណាមបានចូលមករំដោះ ប្រជាជនដែលរស់នៅក្នុងភូមិមានការខឹងសម្បារជាមួយនឹង ឡេ, ហុង និង ម៉ន យ៉ាងខ្លាំង ព្រោះអ្នកទាំងនោះជាអតីតកងឈ្លបក្នុងសម័យខ្មែរក្រហមដែលតែងតែបញ្ជាឲ្យយកមនុស្សទៅសម្លាប់ជារៀងរាល់ថ្ងៃ ។ ដោយសារមូលហេតុនេះហើយទើបប្រជាជននាំគ្នាចាប់ខ្លួនអ្នកទាំងបីយកទៅសម្លាប់ចោលនៅភូមិត្រពាំង ។ ចំណែកម្តាយរបស់គាត់ បានរង់ចាំឪពុករបស់គាត់ដើម្បីធ្វើដំណើរពីផ្លូវជាតិលេខ៣ ឆ្លងទៅខេត្តតាកែវវិញ ។

នៅពេលមកដល់ស្រុកកំណើតវិញ ផ្ទះសម្បែងរបស់ ប៉ូឡូ ត្រូវបានខ្មែរក្រហមដុតបំផ្លាញចោលទាំងអស់ ។ ឪពុកម្តាយគាត់បានសង់កូនខ្ទមតូចមួយសម្រាប់ស្នាក់អាស្រ័យបណ្តោះអាសន្ន ។ ឪពុកម្តាយគាត់ប្រកបមុខរបរធ្វើស្រែ ហើយក្រោយមកក៏បានសាងសង់ផ្ទះមួយខ្នងប្រក់ក្បឿង ។ ចំណែក ប៉ូឡូ បានចូលរៀននៅសាលាបឋមសិក្សាវត្តត្រពាំងចក ស្រុកអង្គរជ័យ ខេត្តកំពត ។

នៅក្នុងឆ្នាំ១៩៨៨ ប៉ូឡូ បានជាប់សញ្ញាប័ត្របាក់ឌុប រួចក៏ដាក់ពាក្យប្រលងធ្វើគ្រូប្រវត្តិវិទ្យា និងភូមិវិទ្យា នៅភូមិភាគតាកែវ ។ សព្វថ្ងៃ ប៉ូឡូ រស់នៅជាមួយក្រុមគ្រួសារ ដោយប្រកបមុខរបរធ្វើជាគ្រូបង្រៀននៅខេត្តកំពត ។

**ស៊ិន សុធីតា**

# ខ្សែភាពយន្តឯកសាររឿង «ក្បង់ទឹកទន្លេ»

«ក្បង់ទឹកទន្លេ» គឺជាខ្សែភាពយន្តឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលទទួលបានការគាំទ្រ និងទិដ្ឋាការពីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ។ មកដល់ពេលនេះ ខ្សែភាពយន្ត «ក្បង់ទឹកទន្លេ» ទទួលបានពានរង្វាន់លំដាប់ពិភពលោកចំនួន១២ហើយ ។ «ក្បង់ទឹកទន្លេ» បង្ហាញនូវដំណើរជីវិតមួយដ៏វិសេសវិសាល និងមិនធ្លាប់មានពីមុនមក ដែលផ្តើមចេញពីតំបន់ជនបទ ចុងកាត់មាត់ញក ព្រៃភ្នំ និងភូមិនេសាទនៅលើផ្ទៃទឹករបស់តួអង្គទាំងបី ។ ខ្សែភាពយន្តនេះបានចាក់បញ្ចាំងនៅសារមន្ទីរសិល្បៈទំនើប សហរដ្ឋអាមេរិក ចាប់ពីថ្ងៃទី១២ ដល់ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៣ និងប្រទេសអូទ្រីស ប៊ែលហ្ស៊ិក អាឡឺម៉ង់ កូរ៉េខាងត្បូង អ៊ីតាលី និងប្រទេសអង់គ្លេស ។ ខ្សែភាពយន្តឯកសារនេះ ក៏គ្រោងនឹងដាក់បញ្ចាំងតាមសាកលវិទ្យាល័យ និងភូមិចំនួន៦០ ទូទាំងប្រទេសកម្ពុជាដើម្បីបើកឲ្យមានការពិភាក្សាស្តីពីការផ្លាស់ប្តូរបរិស្ថាន ដើម្បីស្វែងរកដំណោះស្រាយ ។

ខ្សែភាពយន្តនេះក៏មានចាក់បញ្ចាំងជូនទស្សនារៀងរាល់ថ្ងៃសុក្រនៅមជ្ឈមណ្ឌលឯកសារកម្ពុជា ។

ព័ត៌មានបន្ថែមសូមទាក់ទង កញ្ញា សា ហ្វាទីលី តាមរយៈទូរស័ព្ទលេខៈ ០១២ ៥១១ ៩១៤ ។

អ៊ីម៉ែល : *truthfatily.s@dccam.org* គេហទំព័រ : *www.ariverchangescourse.com*





# ជនជាតិកាវ៉ែត និងជីវភាពរស់នៅ

នៅត្រើយខាងកើតទន្លេសេសាន្ត ចម្ងាយប្រាំគីឡូម៉ែត្រពីទីរួមស្រុកសៀមប៉ាង និងប្រមាណ១០០គីឡូម៉ែត្រពីទីរួមខេត្តស្ទឹងត្រែង ភូមិទាកទាមគឺជាភូមិរបស់ជនជាតិកាវ៉ែត ។ ភូមិទាកទាមគឺជាភូមិមួយក្នុងចំណោមភូមិទាំងប្រាំមួយរបស់ឃុំសន្តិភាព រួមមាន ភូមិគីរីបាស់លើ ភូមិអូរចាយ ភូមិគីរីវង្សាលើ ភូមិគីរីវង្សាក្រោម និងភូមិបាស់ក្រោម ។ ភូមិទាកទាម ជាភូមិដែលមានជនជាតិភាគតិចកាវ៉ែតរស់នៅច្រើនជាងគេ ដែលមានចំនួនរហូតទៅដល់ប៉ែតសិបប្រាំបួនគ្រួសារ ។ ប្រជាជនភាគច្រើនកាន់សាសនាព្រាហ្មណ៍ និងប្រកបរបរធ្វើស្រែចម្ការ ។


ជីង លិក

ជីង លិក ជាជនជាតិកាវ៉ែត អាយុ៥០ឆ្នាំ មានស្រុកកំណើតនៅភូមិទាកទាមនេះតែម្តងបាន រៀបរាប់ថា ពីមុនតំបន់នេះសម្បូរទៅដោយភ្នំ និងមានជនជាតិភាគតិចដទៃទៀតរស់នៅជាច្រើនទៀត ។ អ្នកទាំងនោះចូលចិត្តរស់នៅតំបន់ភ្នំព្រោះងាយស្រួលដាំដំណាំ ធ្វើចម្ការ និងបរបាញ់សត្វដែលជាទម្លាប់តាំងពីបុរាណមក ។ ការរស់នៅរបស់ជនជាតិកាវ៉ែត តាមដែល លិក រៀបរាប់គឺមានការសាមគ្គីគ្នាណាស់ មិនសូវមានជម្លោះជាមួយនឹងគ្នាទេ ។ លិក និយាយថា “ប្រសិនបើពេលណាមានជម្លោះណាមួយកើតឡើង អ្នកទាំងអស់គ្នាតែងតែទៅរកចាស់ទុំនៅក្នុងភូមិជាអ្នកកាត់ក្តីនិងដោះស្រាយឲ្យ ។ បើរកឃើញអ្នកណាម្នាក់ជាអ្នកខុស អ្នកនោះ ត្រូវពិន័យដោយយកស្រាឬសាច់សត្វមកបង់ ។ បច្ចុប្បន្ន ការស្លៀកពាក់របស់ជនជាតិកាវ៉ែតមានលក្ខណៈជាខ្មែរច្រើន ខុសពីមុនប៉ុន្តែនៅតែគោរពនិងកាន់សាសនាព្រាហ្មណ៍ដដែល” ។ ជនជាតិ កាវ៉ែតតែងមានជំនឿយ៉ាងមុតមាំទៅលើការសែនព្រេនអារក្ស អ្នកតាដែលខ្លួនគិតថាជាម្ចាស់ទឹក ម្ចាស់ដី ដែលឃុំគ្រងថែរក្សា ។ ជាក់ស្តែង មុនពេលនិងក្រោយពេលដែលជនជាតិកាវ៉ែតបង្កបង្កើនផលនិងប្រមូលផល ជនជាតិកាវ៉ែតតែងតែធ្វើបុណ្យសែនព្រេន កាប់ជ្រូក កាប់ក្របីដើម្បីសែនរំឭកដល់អារក្សអ្នកតា ដូចជា ព្រះ ភ្លើង ព្រះដំឡូង ជាដើម ដែលជាប្រពៃណីតាំងពីដើមរៀងមក ។

បើនិយាយពីប្រពៃណីរៀបអាពាហ៍ពិពាហ៍វិញ ជនជាតិកាវ៉ែត មានការខុសប្លែកបន្តិចពីជាតិសាសន៍ដទៃត្រង់ថា ជនជាតិកាវ៉ែតអនុញ្ញាតឲ្យកូនចៅរបស់ខ្លួនរៀបការ នៅពេលដែលអ្នកទាំងនោះរស់នៅជាមួយគ្នាបានកូនមួយសិន ហើយពិធីរៀបមង្គលការទៀតសោតមិនមានបង្កាប់អ្វីធំដុំនោះទេ ដោយមានការចូលរួមពីសំណាក់អ្នកភូមិទាំងអស់ដោយអ្នកខ្លះចូលជាស្រា អ្នកខ្លះចូលជាមាន់ ទា ត្រី សាច់ឬម្ហូបផ្សេងៗដែលខ្លួនមាន ។ ចំពោះការសិក្សាក្មេងៗជនជាតិកាវ៉ែតនៅភូមិទាកទាមនេះសិក្សាជាភាសាខ្មែរផង និងជាភាសាកាវ៉ែតផង ។ ទោះជាយ៉ាងណា លិក បានបន្តទៀតថា ជនជាតិកាវ៉ែតនៅតែរក្សាភាសា ប្រពៃណីទំនៀមទំលាប់របស់


ប្តីប្រពន្ធជនជាតិកាវ៉ែតដែលទើបរៀបការ (រូបអង្គុយជួរកណ្តាល)

ជនជាតិខ្លួនខ្លះដោយមិនចង់ឲ្យបាត់បង់អត្តសញ្ញាណរបស់ជនជាតិកាវ៉ែតទាំងស្រុងនោះទេ ។

ក្នុងអំឡុងឆ្នាំ១៩៧០ ក្រោយពេលរដ្ឋប្រហារទម្លាក់សម្តេចព្រះនរោត្តម សីហនុ ខ្មែរក្រហមបានកាន់កាប់តំបន់ភូមិទាកទាមរួចទៅហើយ ។ ក្រោយមក ខ្មែរក្រហមបានភៀសជាតិកាវ៉ែតទាំងអស់ឡើងលើភ្នំ ។ កាលនោះ លិក គឺជាយុវជនម្នាក់ក្នុងចំណោមយុវជនជនជាតិកាវ៉ែតជាច្រើនដែលខ្មែរក្រហមចាប់យកមកហ្វឹកហាត់ឲ្យចេះប្រើអាវុធផ្សេងៗ ដើម្បីត្រៀមខ្លួនធ្វើជាយោធាប្រយុទ្ធនឹងទាហាន លន់ នល់ ។ លិក បានរៀបរាប់ថា ហេតុផលដែលខ្មែរក្រហមយកបងប្អូនជនជាតិភាគតិចធ្វើជាយោធាប្តូរវីរសារព្រោះអ្នកទាំងនោះមានចិត្តស្មោះត្រង់និងដាច់ខាត ហើយក៏មិនខ្លាចឧបសគ្គដែលមានចំពោះមុខ និងជាពិសេសគឺស្គាល់ពីភូមិសាស្ត្រនៅក្នុងព្រៃច្បាស់លាស់ ។ ក្រោយទទួលបានជ័យជម្នះ ខ្មែរក្រហមក៏បានបង្ខំជនជាតិកាវ៉ែតឲ្យធ្វើការងារជាទម្ងន់ដែរ ដោយត្រូវចាត់ឲ្យធ្វើការងារក្នុងសហករណ៍ហូបបាយរួម ជីកប្រឡាយ និងលើកទំនប់ជាដើម ។ លិក ត្រូវអង្គការចាត់តាំងឲ្យឈរជើងការពារនៅព្រំដែនឡាវដែលពេលនោះមាន វ៉ង ជាអ្នកគ្រប់គ្រងតំបន់នោះ ។ លិក បានរំឭកថា ការហូបចុកនៅពេលនោះគឺមានការលំបាកខ្លាំង ហើយនៅអំឡុងឆ្នាំ១៩៧៦-៧៧ ជនជាតិកាវ៉ែតភាគច្រើនដែលតស៊ូជាមួយខ្មែរក្រហមតាំងពីជំនាន់សង្គ្រាមត្រូវខ្មែរក្រហមសម្លាប់ដោយចោទថាមានទំនាក់ទំនងជាមួយវៀតណាម ព្រោះជំនាន់សង្គ្រាមវៀតណាម-អាមេរិក ជនជាតិកាវ៉ែតត្រូវកងទ័ពវៀតណាមពឹងឲ្យជួយក្នុងការធ្វើសង្គ្រាមដោយជួយដឹកជញ្ជូនស្បៀង គ្រាប់ និងជាអ្នកនាំផ្លូវដើរក្នុងព្រៃដោយសារតែអ្នកទាំងនោះស្គាល់ទីតាំងភូមិសាស្ត្រច្បាស់លាស់ ។ ក្រោយមក សង្គ្រាមខ្មែរក្រហមជាមួយនឹង លន់ នល់ ខ្មែរក្រហមក៏យកជនជាតិកាវ៉ែត ជាអ្នកនាំផ្លូវដែរ ។

ពេលវៀតណាមវាយចូលក្នុងឆ្នាំ១៩៧៩ ដោយមានភាពភ័យខ្លាច ជនជាតិកាវ៉ែតទាំងអស់បានភៀសខ្លួនទៅរស់នៅក្នុងទឹកដីឡាវ ។ បីឆ្នាំក្រោយមក រដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជាបានហៅជនជាតិកាវ៉ែតទាំងអស់ត្រឡប់មករស់នៅទឹកដី



ទំនៀមទម្លាប់ជនជាតិកាវ៉ែត អង្គុយបឺតស្រាពាង នៅក្នុងពិធីរៀបការ

កំណើតវិញ ដោយបានបែងចែកដីឲ្យកសាងលំនៅដ្ឋានឡើងវិញ ។ សម្ដីងទៅរកម្ដាយដែលមិនសូវចេះនិយាយភាសាខ្មែរ លិក បន្តថា សង្គ្រាម ក៏ដូចជារបបខ្មែរក្រហមពិតជាធ្វើឲ្យជីវិតប្រជាជនកាវែតមានការលំបាកខ្លាំងសម្រាប់ការកសាងសហគមន៍ទាំងមូលឡើងវិញ ។ លិក បានបាត់បង់ឪពុកនិងប្អូនប្រុសជាទីស្រឡាញ់របស់ខ្លួន ។ គាត់ត្រូវរស់នៅតែពីរនាក់ម្ដាយនិងកូនដោយប្រកបរបរធ្វើស្រែចម្ការដើម្បីជីវភាពរស់នៅ ។ ជាមួយនឹងដំណើរការកាត់ទោសមេដឹកនាំខ្មែរក្រហមដែលកំពុងតែប្រព្រឹត្តទៅសព្វថ្ងៃនេះ ទោះបីជាមិនបានដឹងគ្រប់ជ្រុងជ្រោយក៏ដោយ តែ លិក បានដឹងព័ត៌មានខ្លះតាមរយៈប្រព័ន្ធផ្សព្វផ្សាយនានាដូចជា ទូរទស្សន៍ វិទ្យុ និងតាមបណ្ដាអង្គការមួយចំនួនដែលធ្វើការផ្សព្វផ្សាយពីបញ្ហានេះ ។ ជាទស្សនៈរបស់ លិក ផ្ទាល់ គាត់យល់ថា គាត់មិនចង់ឲ្យមានការកាត់ទោសបន្តទៀតទេ បើតាមផ្លូវសាសនា លិក ចង់ឲ្យមេដឹកនាំទាំងនោះស្លាប់ទៅតាមកម្មផលដែលបានប្រព្រឹត្ត ។ លិក មិនចង់ឲ្យមានការចងពៀរនឹងគ្នា ព្រោះតែមានការសងសឹកមិនចេះចប់ មិនចេះហើយនេះធ្វើឲ្យកើតមានសង្គ្រាម ។

ទោះបីបច្ចុប្បន្នការរស់នៅរបស់ជនជាតិកាវែតមានការផ្លាស់ប្ដូរបន្តិចក៏ដោយ តែអារម្មណ៍របស់អ្នកទាំងអស់គ្នានៅតែមានសេចក្ដីខ្លាចរអាចំពោះអ្នកចំណូលស្រុកថ្មីដែលមិនមែនជាជនជាតិកាវែត ដោយខ្លាចអ្នកទាំងនោះធ្វើបាបជនជាតិខ្លួន ដោយហេតុផលថា ជនជាតិកាវែតជាមនុស្សទៀងត្រង់ មិនចេះបង្កជម្លោះ ឬបៀតបៀននរណាម្នាក់ឡើយ ។ លិក បានបន្តទៀតថា រាល់អំពើចោរកម្មដែលកើតឡើងនៅភូមិឃុំដែលគាត់រស់នៅគឺមិនមែនអ្នកនៅក្នុងភូមិទេ តែជាអ្នកមកពីតំបន់ក្រៅ ។

ជាមួយនឹងជីវិតដែលស្ទើរតែពឹងផ្អែកទាំងស្រុងទៅលើធម្មជាតិ លិក ក៏ដូចជាជនជាតិកាវែតឯទៀតដែរ សំណូមពរដល់រាជរដ្ឋាភិបាល ចាំបាច់ត្រូវចាត់វិធានការការពារព្រៃឈើព្រោះសម្រាប់ជនជាតិកាវែត ព្រៃឈើគឺជាជីវិតមួយផ្នែកដែលមានសារសំខាន់ណាស់សម្រាប់ការរស់នៅព្រោះការរស់នៅគឺអាស្រ័យនឹងការធ្វើស្រែចម្ការ និងបរបាញ់តែប៉ុណ្ណោះ ។ **អ៊ុន សុជាទី**



ដឹង លិក និងម្ដាយ ក្នុងពេលសម្ភាសជាមួយ អ៊ុន សុជាវ បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា

# ហេតុអ្វីខ្មែរក្រហមជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ?

នៅថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០១៣ នួន ជា បានថ្លែងថា មូលហេតុដែលថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជាសម្រេចជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញកាលពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ព្រោះខ្លាចមានការទម្លាក់គ្រាប់បែករបស់សហរដ្ឋអាមេរិកមកលើប្រជាជននៅក្នុងទីក្រុងបន្ទាប់ពីរបប លន់ នល់ ត្រូវបានផ្តួលរំលំ ។ នួន ជា បានបន្តទៀតថា ហេតុផលមួយទៀតគឺដើម្បីឲ្យប្រជាជននៅក្នុងទីក្រុងចូលរួមបង្កបង្កើនផលនៅតាមជនបទ ។ ពិតប្រាកដណាស់ ដើមបណ្តឹងរដ្ឋប្បវេណីនិងសាក្សីជាច្រើនរូបបានផ្តល់សក្ខីកម្មដូចៗគ្នានៅចំពោះមុខតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមថា បន្ទាប់ពីយោធាខ្មែរក្រហមចូលកាន់កាប់ទីក្រុងភ្នំពេញភ្លាមខ្មែរក្រហមបានប្រកាសឲ្យប្រជាជនចេញពីទីក្រុងដោយផ្តល់ហេតុផលថាដើម្បីគេចពីការទម្លាក់គ្រាប់បែករបស់យោធាអាមេរិកនិងរៀបចំទីក្រុងឲ្យមានរបៀបរៀបរយ ហើយបីថ្ងៃក្រោយទើបអនុញ្ញាតឲ្យចូលទីក្រុងភ្នំពេញវិញ ។

តើមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាពិតជាមានការភ័យខ្លាចថា មានការទម្លាក់គ្រាប់បែកពីសំណាក់សហរដ្ឋអាមេរិក ដូចបានប្រកាសនៅក្នុងអំឡុងពេលជម្លៀសប្រជាជនរាប់លាននាក់ចេញពីទីក្រុងមែនដែរឬទេ? ប្រជាជនដែលបានរត់ចូលស្ថានទូតបារាំង អ្នកជំងឺកំពុងសម្រាកក្នុងមន្ទីរពេទ្យជាច្រើនត្រូវបានបង្ខំឲ្យចាកចេញដោយគ្មានការសណ្តោសប្រណី ។

បើរំឭកទៅដល់សក្ខីកម្មរបស់ នួន ជា ក្នុងសវនាការកាលពីថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១១ បានបង្ហាញឲ្យឃើញថា ថ្នាក់



ប្រជាជនកម្ពុជាត្រូវបានជម្លៀសដោយខ្មែរក្រហមនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥

ដឹកនាំបក្សកុម្មុយនីស្តកម្ពុជាបានដឹងយ៉ាងច្បាស់ថា សភាសហរដ្ឋអាមេរិកបានអនុម័តច្បាប់មួយ ដោយហាមឃាត់រដ្ឋាភិបាលរបស់ខ្លួនដែលដឹកនាំដោយប្រធានាធិបតី រីឆាត និចសុន ឲ្យបញ្ចប់ការទម្លាក់គ្រាប់បែកមកលើប្រទេសកម្ពុជាក្នុងឆ្នាំ១៩៧៣ ។ គណៈកម្មាធិការអចិន្ត្រៃយ៍បក្សកុម្មុយនីស្តកម្ពុជាបានវិភាគឃើញថា បើគ្មានជំនួយយោធាផ្នែកកងទ័ពជើងអាកាសរបស់សហរដ្ឋអាមេរិកនោះចលនាតស៊ូរបស់ខ្លួននឹងទទួលបានជ័យជម្នះក្នុងពេលឆាប់ៗជាក់ជាមិនខានព្រោះទាហានរបស់ លន់ នល់ កាន់តែចុះខ្សោយទៅៗជាលំដាប់ ។ ច្បាស់ជាងនេះទៀតក្នុងសវនាការថ្ងៃដដែលនោះ នួនជាបានបញ្ជាក់ថា នៅក្នុងកិច្ចប្រជុំពាក់កណ្តាលឆ្នាំ១៩៧៤ (កិច្ចប្រជុំរួមរវាងគណៈមជ្ឈិម និងគណៈអចិន្ត្រៃយ៍របស់បក្សកុម្មុយនីស្តកម្ពុជា ដែលបានសម្រេចជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញនិងតាមទីរួមខេត្ត) អង្គប្រជុំបានឯកភាពគ្នាថា *«បើបក្សកុម្មុយនីស្តកម្ពុជាដឹកនាំចលានាតស៊ូរំដោះជាតិ រំដោះប្រជាជនបានគឺយើងសម្រេចបានភារកិច្ចធ្វើ (បដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យ) បានមួយចំនួនសំខាន់ហើយ គឺយើងបានដោះស្រាយទំនាស់បដិបក្ខ គឺទំនាស់ស្លាប់រស់ជាមួយសហរដ្ឋអាមេរិក និងរបប លន់ នល់ បានជាដំបូង ។ សហរដ្ឋអាមេរិកមិននៅជាគូអង្គបដិបក្ខទៀតទេ»* ។

ដូច្នេះ តើអ្វីជាហេតុផលពិតប្រាកដនៃការសម្រេចជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ?

សេចក្តីសម្រេចជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញគឺពុំមែនជារឿងដែលកើតឡើងភ្លាមៗ ឬដោយចៃដន្យឡើយ ។ តាមរយៈសក្ខីកម្មរបស់ នួន ជា សេចក្តីសម្រេចនេះត្រូវបានអនុម័តជាឯកច្ឆន្ទនៅក្នុងកិច្ចប្រជុំរួមរវាងគណៈមជ្ឈិម និងគណៈអចិន្ត្រៃយ៍នៃបក្សកុម្មុយនីស្តកម្ពុជា (ហៅកាត់ថា អង្គប្រជុំ) ក្នុងឆ្នាំ១៩៧៤ ។ ថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជាបានសម្រេចជាឯកច្ឆន្ទថា *«ក្នុងករណីរំដោះបានទីក្រុងភ្នំពេញ នោះត្រូវជម្លៀសប្រជាជនចេញពីក្រុងភ្នំពេញ និងទីរួមខេត្តជាបណ្តោះអាសន្ន ដើម្បីពិនិត្យតាមដានសភាពការណ៍មួយរយៈសិន ជាពិសេសសកម្មភាពរបស់វៀតណាម»* ។ ហេតុផលទីមួយ ថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជាវិភាគឃើញថា នៅពេលរំដោះបានទីក្រុងភ្នំពេញ ទាហាន លន់ នល់ មួយចំនួននឹងសម្ងំលាក់ខ្លួននៅក្នុងទីក្រុង ដែលអាចបង្កការរំខាន ឬវាយឆ្មក់មកលើកម្លាំងទ័ព និងប្រជាជនរបស់ខ្លួន ។ ហេតុផលទីពីរ ពាក់ព័ន្ធនឹងការពិនិត្យតាមដានសកម្មភាពរបស់វៀតណាម ថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជា មានការព្រួយបារម្ភថា វៀតណាមអាចនឹងវាយដណ្តើមកាន់កាប់ទីក្រុងភ្នំពេញ បន្ទាប់ពីវៀតណាមខាងជើងរំដោះបានវៀតណាមខាងត្បូង ។ ថ្នាក់ដឹកនាំខ្មែរក្រហមបានវិភាគថា បន្ទាប់ពីចលនាតស៊ូរំដោះជាតិ រំដោះប្រជាជនទទួលបានជោគជ័យ វៀតណាមនឹងក្លាយទៅជាគូបដិបក្ខ (ទំនាស់ស្លាប់រស់) របស់ខ្លួនគឺពុំមែនសហរដ្ឋអាមេរិកទៀតឡើយ ។

ហេតុផលមួយទៀតនៃការជម្លៀស



យោធាខ្មែរក្រហមចូលទីក្រុងភ្នំពេញ

ប្រជាជនឲ្យចេញពីទីក្រុងភ្នំពេញ គឺដើម្បីអនុវត្តផែនការពង្រីកសហករណ៍នៅតាមមូលដ្ឋាន។ តាមរយៈសេចក្តីសម្រេចនៅក្នុងកិច្ចប្រជុំពាក់កណ្តាលឆ្នាំ១៩៧៤បានបង្ហាញថា បន្ទាប់ពីវាយដណ្តើមកាន់កាប់បានទីក្រុងភ្នំពេញ នោះបក្សកុម្មុយនីស្តកម្ពុជានឹងជម្លៀសប្រជាជនទៅតាមភូមិភាគនីមួយៗ ដែលភូមិភាគទាំងនោះត្រូវបានណែនាំឲ្យត្រៀមខ្លួនរួចជាស្រេចក្នុងការទទួលយកកម្លាំងបន្ថែមដើម្បីបង្កបង្កើនផល។ ក្នុងកិច្ចប្រជុំនោះ ថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជាបានណែនាំដល់កម្មាភិបាលដែលបានចូលរួមប្រជុំទាំងអស់ឲ្យទៅពិភាក្សាជាមួយគណៈភូមិភាគ គណៈតំបន់ គណៈស្រុក អំពីលទ្ធភាពក្នុងការទទួលយកប្រជាជនដែលនឹងត្រូវជម្លៀសចេញពីទីក្រុងភ្នំពេញ។

ហេតុផលខាងលើនេះ មានភាពស៊ីសង្វាក់គ្នាយ៉ាងខ្លាំងទៅនឹងបទខុទ្ទេសនាមរបស់ថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជាដែលត្រូវបានចុះផ្សាយក្នុងទស្សនាវដ្តីទង់បដិវត្ត។ យោងតាមទស្សនាវដ្តីទង់បដិវត្ត លេខពិសេសបោះពុម្ពផ្សាយសម្រាប់ខែធ្នូ-មករា ឆ្នាំ១៩៧៦-១៩៧៧ (ចុះផ្សាយបទខុទ្ទេសនាមរបស់ថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជា ដែលបានធ្វើនៅថ្ងៃទី១៧ ខែមករា ឆ្នាំ១៩៧៧ ក្នុងឱកាសថ្ងៃបុណ្យរំឭកខួបលើកទី៩នៃកំណើតកងទ័ពបដិវត្តន៍កម្ពុជា) បានបង្ហាញថា ការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញគឺជាការអនុវត្ត "មាគ៌ាពង្រឹងប្រជាជនពីខ្មាំង" ដែលបក្សកុម្មុយនីស្តកម្ពុជាធ្លាប់បានអនុវត្តកន្លងមក។ ក្នុងបទខុទ្ទេសនាមនោះបានលើកឡើងថា "...មាគ៌ាយើងគឺដណ្តើមប្រជាជន១នាក់ក៏យក ២នាក់ក៏យក ១រយនាក់ក៏យក ១ពាន់នាក់ក៏យក រហូតដល់ដណ្តើមប្រជាជនពីទីក្រុងភ្នំពេញទៀត..."។ បក្សកុម្មុយនីស្តកម្ពុជាយល់ឃើញថា ប្រសិនបើខ្មាំងមានប្រជាជន ខ្មាំងនឹងមានយោធានិងសេដ្ឋកិច្ច។ ផ្ទុយទៅវិញប្រសិនបើខ្មាំងពុំមានប្រជាជនទេ ខ្មាំងក៏ពុំមានយោធា និងសេដ្ឋកិច្ចដែរ។ ថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជាលើកយកបទពិសោធន៍យ៉ាងល្អពាក់ព័ន្ធនឹងការជម្លៀសយកប្រជាជនចេញពីទីក្រុងឧត្តុង្គក្លាម១ បន្ទាប់ពីវាយឈ្នះទាហាន លន់ នល់ ក្នុងអំឡុងឆ្នាំ១៩៧៤ ដោយបានលើកឡើងថា "ឧទាហរណ៍ៈ យើងរំដោះឧត្តុង្គក្នុងឆ្នាំ១៩៧៤។ យើងដកយកប្រជាជនទាំងអស់។ ដល់វាដណ្តើមវិញ វាគ្មានកម្លាំង។ គ្មានកម្លាំងប្រជាជនគ្មានកម្លាំងសេដ្ឋកិច្ច គ្មានកម្លាំងយោធា"។

គួរបញ្ជាក់ថា ខ្លឹមសារនៃមាគ៌ាពង្រឹងប្រជាជនពីខ្មាំង ដែលថា "...មាគ៌ាយើង គឺដណ្តើមប្រជាជន ១នាក់ក៏យក ២នាក់ក៏យក ១រយនាក់ក៏យក ១ពាន់នាក់ក៏យក រហូតដល់ដណ្តើមប្រជាជនពីទីក្រុងភ្នំពេញទៀត..." ត្រូវបានចៅក្រម ហ្សង់ម៉ាក ឡាវែង ដកស្រង់មកសួរ នួន ជា នៅក្នុងសវនាការថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១២។ នួន ជា បានពន្យល់ថា "គោលការណ៍សង្គ្រាមឈ្លប ប្រជាជននៅខាងណាខាងហ្នឹងឈ្នះ។ យើងត្រូវពង្រឹងប្រជាជនពីខ្មាំង។ ដូច្នេះ ប្រជាជននៅខាងយើង ឧបត្ថម្ភយើង ប្រជាជននៅខាងខ្មាំង ឧបត្ថម្ភខ្មាំង។ដូច្នេះត្រូវប្រមូលប្រជាជនឲ្យបានច្រើនជាអតិបរមាពង្រឹងប្រជាជនពីខ្មាំង"។

សរុបសេចក្តីមក យោងតាមសក្ខីកម្មរបស់ នួន ជា នៅថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១១ បានបង្ហាញថា ការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញគឺត្រូវបានសម្រេចតាំងពីពាក់កណ្តាលឆ្នាំ១៩៧៤ មកម៉្លេះ ហើយនៅតាមភូមិភាគនីមួយៗត្រូវបានណែនាំរួចជាស្រេចក្នុងការទទួលយកប្រជាជនទាំងនោះ។ មានហេតុផលពីរយ៉ាងដែលនាំឲ្យមានការសម្រេចនេះ ៖ ទី១) គឺដើម្បីជៀសវាងមិនឲ្យទាហាន លន់ នល់ នៅសម្ងំលាក់ខ្លួនក្នុងទីក្រុងដែលអាចបង្កការរំខាន ឬវាយឆ្មក់មកលើកម្លាំងរបស់ខ្លួន និងដើម្បីពិនិត្យមើលសកម្មភាពរបស់វៀតណាម ដោយសារមានការព្រួយបារម្ភថា វៀតណាមអាចនឹងវាយដណ្តើមកាន់កាប់ទីក្រុងភ្នំពេញបន្ទាប់ពីវៀតណាមខាងជើងរំដោះបានវៀតណាមខាងត្បូង។ ទី២) គឺដើម្បីពង្រឹង និងពង្រីកសហករណ៍បង្កបង្កើនផលនៅតាមមូលដ្ឋាន ដែលថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជាបានសម្រេចនៅក្នុងកិច្ចប្រជុំពាក់កណ្តាលឆ្នាំ១៩៧៤។

បន្ថែមលើនេះទៀត យោងតាមបទខុទ្ទេសនាមរបស់ថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជាដែលត្រូវបានចុះផ្សាយក្នុងទស្សនាវដ្តីទង់បដិវត្តលេខពិសេសនោះ ការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញគឺជាការអនុវត្តមាគ៌ាយុទ្ធសាស្ត្រក្នុងការដណ្តើមយកកម្លាំងប្រជាជនពីខ្មាំង ឬនិយាយម្យ៉ាងទៀតថា គឺដើម្បីការពារមិនឲ្យមានការដណ្តើមយកប្រជាជនវិញក្នុងករណីមានខ្មាំងវាយចូលកាន់កាប់ទីក្រុងភ្នំពេញ។ **ចាន ប្រាថ្នា**

# វគ្គបណ្តុះបណ្តាលគ្រូបង្រៀនស្តីអំពីវិធីសាស្ត្របង្រៀនប្រវត្តិសាស្ត្រ
# នៅសាលាគរុកោសល្











# ស្ត្រកម្ពុជាប្រជាធិបតេយ្យពីថ្ងៃទី១៧ ដល់២២ ខែសីហា ឆ្នាំ២០១៣ ភូមិភាគខេត្តតាកែវ









# ការអត់ឃ្លាន និងឧក្រិដ្ឋកម្មសង្រ្គាម

## សំឡេងយុត្តិធម៌ : អំពើប្រល័យពូជសាសន៍ និងការអត់ឃ្លាននៅក្នុងរបបខ្មែរក្រហម

***កម្មវិធីវិទ្យុសហគមន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា (វគ្គទី៦)***

*វគ្គទី៦ នេះផ្តោតសំខាន់ទៅលើច្បាប់ឧក្រិដ្ឋកម្មសង្រ្គាមផ្សេងៗ និងស្វែងយល់ថាតើច្បាប់ឧក្រិដ្ឋកម្មសង្រ្គាមអាចអនុវត្តចំពោះការអត់ឃ្លានដែលបានកើតឡើងនៅក្នុងប្រទេសកម្ពុជា និងប្រទេសដទៃទៀតដែរឬទេ ។ នៅក្នុងវគ្គនេះ យើងនឹងធ្វើការបកស្រាយពីពាក្យឧក្រិដ្ឋកម្មសង្រ្គាម ដោយលើកយកឧទាហរណ៍នៃឧក្រិដ្ឋកម្មសង្រ្គាមមួយចំនួនដែលអាចជាប់ទាក់ទងទៅនឹងលក្ខខណ្ឌនៃការអត់ឃ្លាន មកពិភាក្សា ។*

### តើឧក្រិដ្ឋកម្មសង្រ្គាមជាអ្វី?

*ឧក្រិដ្ឋកម្មសង្រ្គាម គឺជាការរំលោភបំពានធ្ងន់ធ្ងរទៅលើច្បាប់សង្រ្គាម ដែលមានឈ្មោះជាផ្លូវការថា "ច្បាប់មនុស្សធម៌អន្តរជាតិ" ។ ច្បាប់ឧក្រិដ្ឋកម្មសង្រ្គាម ត្រូវបានបង្កើតឡើងក្នុងគោលបំណង ដើម្បីកាត់បន្ថយការបំផ្លិចបំផ្លាញទ្រព្យសម្បត្តិស៊ីវិល និងប្រជាជនដែលមិនបានចូលរួមធ្វើសង្រ្គាម ក្នុងអំឡុងពេលដែលមានសង្រ្គាម ។ លុះត្រាតែមានតែការរំលោភបំពានធ្ងន់ធ្ងរទៅលើច្បាប់មនុស្សធម៌តែប៉ុណ្ណោះ ទើបអាចចាត់ទុកជាឧក្រិដ្ឋកម្មសង្រ្គាមបាន ។ ច្បាប់មនុស្សធម៌ គឺជាផ្នែកចាស់មួយនៃច្បាប់អន្តរជាតិ និងច្បាប់សង្រ្គាមថ្មី ដែលបានចែងនៅក្នុងសន្ធិសញ្ញាអន្តរជាតិកាលពីដើមទសវត្សរ៍ឆ្នាំ១៩០០ ហើយអាចមុននឹងទៅទៀត ។*

*ដូចគ្នាទៅនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែរ ឧក្រិដ្ឋកម្មសង្រ្គាមត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយ ដើម្បីកាត់ទោសជន*



*កងយោធាខ្មែរក្រហមនៅក្នុងសមរភូមិប្រយុទ្ធ ឬកំពុងហ្វឹកហាត់*

ល្មើស បន្ទាប់ពីសង្គ្រាមលោកលើកទី២ត្រូវបានបញ្ចប់ ។ ច្បាប់ឧក្រិដ្ឋកម្មសង្គ្រាមសំខាន់ៗភាគច្រើន នៅតែអាចយកមកអនុវត្តបានរហូតដល់សព្វថ្ងៃ ។ ច្បាប់ទាំងនោះ យោងទៅលើឯកសារច្បាប់មនុស្សធម៌អន្តរជាតិចំនួនបួន រួមមាន "អនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩" និងពិធីសារចំនួនពីរផ្សេងទៀតនៃអនុសញ្ញាឆ្នាំ១៩៧៧ ។ "ការរំលោភបំពានធ្ងន់ធ្ងរ" ទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ គឺជាឧក្រិដ្ឋកម្មសង្គ្រាម ។ ឧក្រិដ្ឋកម្មសង្គ្រាម ក៏អាចបង្កើតឡើងជាផ្នែកមួយនៃច្បាប់ ទំនៀមទម្លាប់អន្តរជាតិសាធារណទូទៅ ឬអាចបង្កើតឡើងតាមរយៈអនុសញ្ញា ឬសន្ធិសញ្ញាផ្សេងៗ ។

ជាសរុប យើងអាចនិយាយបានថា ច្បាប់ឧក្រិដ្ឋកម្មសង្គ្រាមសំដៅទៅលើទង្វើទាំងឡាយណាដែលប្រព្រឹត្តឡើងក្នុងអំឡុងពេលមានជម្លោះប្រដាប់អាវុធ ហើយទង្វើទាំងនោះបានរំលោភបំពានទៅលើច្បាប់ដែលពាក់ព័ន្ធទៅនឹងការការពារជនទាំងឡាយដែលមិនបានចូលរួមក្នុងការធ្វើសង្គ្រាម ដូចជា ប្រជាជនស៊ីវិល ទាហានដែលរងរបួស និងជនឈ្លើយសឹក ព្រមទាំងក្រុមដែលទទួលបានការការពារ ។

## តើច្បាប់ឧក្រិដ្ឋកម្មសង្គ្រាមអាចអនុវត្តបាននៅពេលណា?

ច្បាប់ឧក្រិដ្ឋកម្មសង្គ្រាម អាចអនុវត្តបាននៅពេលដែលមានជម្លោះប្រដាប់អាវុធកើតឡើង ។ ជាមួយគ្នានេះដែរ ច្បាប់ឧក្រិដ្ឋកម្មសង្គ្រាមមួយចំនួនអាចអនុវត្តបានចំពោះតែជម្លោះប្រដាប់អាវុធ អន្តរជាតិតែប៉ុណ្ណោះ ។ នេះមានន័យថា ច្បាប់ឧក្រិដ្ឋកម្មសង្គ្រាម មិនអាចអនុវត្តចំពោះជម្លោះប្រដាប់អាវុធមួយចំនួន ដូចជា សង្គ្រាមស៊ីវិល ដែលភាគីជម្លោះជាក្រុមដែលរស់នៅក្នុងប្រទេសតែមួយ ។ លើសពីនេះទៅទៀត គ្រប់ឧក្រិដ្ឋកម្មសង្គ្រាមទាំងអស់ត្រូវតែមានការប្រើប្រាស់អាវុធ ។ នេះមានន័យថា បទល្មើសទាំងឡាយណាដែលកើតមានឡើងនៅក្នុងអំឡុងពេលសង្គ្រាម តែមិនមានពាក់ព័ន្ធទៅនឹងជម្លោះប្រដាប់អាវុធ បទល្មើសនោះមិនត្រូវបានចាត់ចូលទៅក្នុងឧក្រិដ្ឋកម្មសង្គ្រាមនោះទេ ។ ជាឧទាហរណ៍ ប្រសិនបើមានជនណាម្នាក់សម្លាប់ប្រជាជនស៊ីវិល ព្រោះតែហេតុផលផ្ទាល់ខ្លួន បទល្មើសនោះមិនត្រូវបានចាត់ចូលទៅក្នុងឧក្រិដ្ឋកម្មសង្គ្រាមនោះឡើយ បើទោះបើជាបទល្មើសនោះកើតឡើងក្នុងអំឡុងពេលសង្គ្រាមក៏ដោយ ។

ដូចដែលបានរៀបរាប់ខាងលើឧក្រិដ្ឋកម្មសង្គ្រាមកើតឡើងប្រឆាំងនឹងក្រុមមនុស្សដែលទទួលបានការការពារ ពោលគឺអ្នកដែលមិនបានចូលរួមនៅក្នុងសង្គ្រាម ដូចជា ប្រជាជនស៊ីវិល អ្នកធ្វើការផ្នែកសប្បុរសធម៌ ទាហានដែលរងរបួសមិនអាចចូលរួមប្រយុទ្ធបាន និងជនឈ្លើយសឹក ។ ដោយសារតែច្បាប់ឧក្រិដ្ឋកម្មសង្គ្រាមភាគច្រើនត្រូវបានបង្កើតឡើងនៅខណៈពេលដែលមានសង្គ្រាមរវាងប្រទេសមួយ និងប្រទេសមួយទៀត ហើយកងកម្លាំងបរទេសបានធ្វើការរំលោភបំពានដល់ប្រជាជនស៊ីវិលនៃប្រទេសដទៃក្នុងអំឡុងនៃសង្គ្រាម ។ ច្បាប់ឧក្រិដ្ឋកម្មសង្គ្រាមមួយចំនួនត្រូវបានស្រង់ចេញពីអនុសញ្ញាទីក្រុងហ្សឺណែវសម្រាប់អនុវត្តចំពោះប្រជាជនស៊ីវិលនៃប្រទេសមួយដែលស្ថិតក្រោមការគ្រប់គ្រងរបស់ជនបរទេស ។ ច្បាប់ឧក្រិដ្ឋកម្មសង្គ្រាម មិនត្រូវបានយកមកប្រើប្រាស់សម្រាប់ការពារជនស៊ីវិលទាំងឡាយណាដែលត្រូវបានធ្វើទុក្ខបុកម្នេញដោយរដ្ឋាភិបាលរបស់ខ្លួននៅក្នុងអំឡុងពេលមានសង្គ្រាមឡើយ ។

## ឧក្រិដ្ឋកម្មសង្គ្រាមនៅក្នុងតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម និងការអត់ឃ្លាន

ដោយផ្អែកលើច្បាប់ឧក្រិដ្ឋកម្មសង្គ្រាមថ្មី ឧក្រិដ្ឋកម្មសង្គ្រាមគឺជាឧក្រិដ្ឋកម្មមួយដែលបាន "ប្រើប្រាស់ការបង្អត់អាហារប្រជាជនស៊ីវិលដោយចេតនា ជាមធ្យោបាយក្នុងការធ្វើសង្គ្រាម ។ ការបង្អត់អាហារនេះធ្វើឡើងក្នុងគោលបំណងមិនឲ្យប្រជាជនស៊ីវិលអាចមានលទ្ធភាពរស់បាន រួមមាន ការបង្អាក់ការផ្តល់ជំនួយមនុស្សធម៌ដូចដែលមានចែងក្នុងអនុសញ្ញាទីក្រុងហ្សឺណែវ" ក្នុងអំឡុងពេលមានជម្លោះប្រដាប់អាវុធអន្តរជាតិ ។ ឧក្រិដ្ឋកម្មនេះ ត្រូវបានដកស្រង់ចេញពីពិធីសារមួយក្នុងចំណោមពិធីសារឆ្នាំ១៩៧៧ នៃអនុសញ្ញាទីក្រុងហ្សឺណែវ និង ត្រូវបានប្រើប្រាស់នៅតុលាការព្រហ្មទណ្ឌអន្តរជាតិ ។ ឧក្រិដ្ឋកម្មនេះ បានលើកឡើងពីការប៉ុនប៉ងកាត់ផ្តាច់ជំនួយស្បៀងអាហារទៅដល់ប្រជាជនស៊ីវិលរបស់គូជម្លោះ និងការរារាំងដល់ការផ្តល់ជំនួយរបស់អន្តរជាតិ ពីសំណាក់កងយោធា នៅក្នុងអំឡុងពេលមានជម្លោះប្រដាប់អាវុធ ។ ផ្ទុយទៅវិញឧក្រិដ្ឋកម្មសង្គ្រាម មិនអាចចោទប្រកាន់បានចំពោះទង្វើរបស់រដ្ឋាភិបាលមួយ ដែលបង្កឲ្យប្រជាជនស៊ីវិលខ្លួនឯងជួបប្រទះគ្រោះ

អត់ឃ្លាននោះទេ ។

វាជាការរំលោភបំពានមួយទៅលើបទដ្ឋាននៃការទទួលបានការកាត់ទោសដោយស្មើភាពគ្នាចំពោះមុខច្បាប់ ប្រសិនបើតុលាការមួយកាត់ទោសជនល្មើសណាម្នាក់ពីបទឧក្រិដ្ឋមួយដែលបានកើតឡើងមុនពេលច្បាប់សម្រាប់កាត់ទោសបទឧក្រិដ្ឋនោះមិនទាន់បានបង្កើត ។ ដូច្នេះ នៅក្នុងតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម មានតែបទឧក្រិដ្ឋកម្មសង្គ្រាមមួយចំនួនប៉ុណ្ណោះត្រូវបានលើកឡើង ។ ជាងនេះទៅទៀត បទឧក្រិដ្ឋកម្មសង្គ្រាមទាំងនោះត្រូវបានស្គាល់ថា ជាការរំលោភបំពានធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ។ បទល្មើសនៃការប្រើប្រាស់ការបង្អត់អាហារជាមធ្យោបាយមួយក្នុងការធ្វើសង្គ្រាម មិនបានលើកឡើងនៅក្នុងតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ។ ប៉ុន្តែ ឧក្រិដ្ឋមួយចំនួនផ្សេងទៀត ដែលបានលើកឡើងនៅក្នុងតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម មានការពាក់ព័ន្ធទៅនឹងការអត់ឃ្លាន និងគ្រោះទុរ្ភិក្សដែរ ។ ចំពោះឧក្រិដ្ឋកម្មមួយចំនួនទៀត ដែលមានរៀបរាប់ដូចខាងក្រោម បើយើងក្រឡេកមើលមួយភ្លែត ហាក់ដូចជាមានការពាក់ព័ន្ធនឹងការអត់ឃ្លានដែលបានកើតឡើងក្នុងរបបខ្មែរក្រហម ៖

◆ ការសម្លាប់ដោយចេតនា

◆ ការធ្វើទារុណកម្ម ឬការធ្វើទុក្ខបុកម្នេញ

◆ ការបង្កឲ្យមានការឈឺចាប់ ឬរបួសធ្ងន់ធ្ងរទៅលើរូបកាយ ឬសុខភាព ដោយចេតនា

◆ ការនិរទេស ឬផ្លាស់ប្តូរកន្លែងរស់នៅ ឬការឃុំឃាំងប្រជាជនស៊ីវិលដោយខុសច្បាប់ ។

ជាទូទៅ ប្រសិនបើមានការដាក់បង្ខំនូវលក្ខខណ្ឌរស់នៅចំពោះប្រជាជនស៊ីវិល ឬក្រុមដែលទទួលបានការការពារឲ្យរស់នៅក្នុងភាពអត់ឃ្លានដោយចេតនា ក្នុងគោលបំណងបង្កឲ្យជនទាំងនោះស្លាប់ ទង្វើនោះអាចចោទប្រកាន់ថាជាការសម្លាប់ដោយចេតនា ។ ស្រដៀងគ្នានឹងនេះដែរ ប្រសិនបើជនស៊ីវិល ឬក្រុមដែលទទួលបានការការពារ ទទួលរងការធ្វើទុក្ខបុកម្នេញដោយចេតនាតាមរយៈការមិនផ្តល់ចំណីអាហារ ឧទាហរណ៍ ការធ្វើទារុណកម្មទៅលើឈ្លើយសឹកដោយការឃុំឃាំង និងមិនផ្តល់អាហារ ទង្វើនោះអាចចោទប្រកាន់ថាជាការធ្វើទារុណកម្ម ឬក៏ការធ្វើទុក្ខបុកម្នេញ ។ ចំណែកឯនិយមន័យនៃការបង្កឲ្យមានការឈឺចាប់ ឬរបួសដោយចេតនា ហាក់ដូចជាពុំមានលក្ខណៈច្បាស់លាស់នោះទេ ។ ប៉ុន្តែ យើងអាចយកមកប្រើប្រាស់បាន ដោយផ្តោតទៅលើស្ថានភាពមួយដែលការផ្តល់អាហារដល់ក្រុម ដែលទទួលបានការការពារត្រូវបានកាត់បន្ថយដោយចេតនា ឬក្រុមនោះត្រូវបានដាក់ឲ្យរស់នៅក្នុងស្ថានភាពទុរ្ភិក្សក្នុងគោលបំណងបង្កឲ្យមានការឈឺចាប់ ។ លើសពីនេះទៅទៀត ស្ថានភាពនៃការអត់ឃ្លាន អាចកើតមានឡើង ឬកាន់តែអាក្រក់ឡើងនៅពេលដែលប្រជាជនរងគ្រោះត្រូវបានក្រុមប្រដាប់អាវុធរារាំងមិនឲ្យផ្លាស់ទីដោយសេរី ទៅតំបន់ណាដែលសម្បូរផលិតផលស្បៀងអាហារ ឬតំបន់ដែលមានការចែកចាយអាហារ ដូចជា ជំរំជនភៀសខ្លួន ជាដើម ។



កងយោធាខ្មែរក្រហមនៅក្នុងសមរភូមិប្រយុទ្ធ ឬកំពុងហ្វឹកហាត់

ខក្រិដ្ឋកម្មដែលបានរៀបរាប់ខាងលើ ពុំមានបទខក្រិដ្ឋណាមួយដែលសក្តិសម ដើម្បីធ្វើការចោទប្រកាន់ចំពោះការអត់ឃ្លានដែលបានកើតឡើងនៅក្នុងរបបខ្មែរក្រហមនោះទេ ។

ជាក់ស្តែង ជនរងគ្រោះដោយសារការអត់ឃ្លាននៅក្នុងរបបខ្មែរក្រហម មិនមែនជាក្រុមដែលទទួលបានការការពារក្រោមច្បាប់នៃអនុសញ្ញាទីក្រុងហ្សឺណែវទេ ។ មិនតែប៉ុណ្ណោះ ការអត់ឃ្លានដែលបានកើតឡើងនៅពេលនោះមិនមានការពាក់ព័ន្ធទៅនឹងជម្លោះប្រដាប់អាវុធជាមួយប្រទេសវៀតណាមនោះទេ ដោយសារតែៈ

ទីមួយ ៈ ខ្មែរក្រហមដែលឡើងមកកាន់អំណាចនៅប្រទេសកម្ពុជា មិនមែនជាជនបរទេសនោះទេ ។ ប៉ុន្តែ ខ្មែរក្រហមជារដ្ឋាភិបាលផ្លូវការរបស់កម្ពុជា ។ នេះមានន័យថា ជនរងគ្រោះដោយការអត់ឃ្លាននៅក្នុងរបបខ្មែរក្រហមមិនមែនជាក្រុមនៃជនដែលទទួលបានការការពារនោះទេ ។

ទីពី ៈ តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមបានទទួលស្គាល់ថា នៅក្នុងរបបខ្មែរក្រហម ភាពតានតឹង និងការប្រយុទ្ធគ្នាតាមបណ្តោយព្រំដែនខ្មែរ-វៀតណាម ពិតជាបានកើតឡើងមែន ហើយជម្លោះនេះត្រូវបានតុលាការទទួលស្គាល់ថាជាជម្លោះប្រដាប់អាវុធអន្តរជាតិ ដែលអាចចាត់ទុកថាជា ខក្រិដ្ឋកម្មសង្គ្រាម ។ តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមអាចចោទប្រកាន់ខក្រិដ្ឋកម្មនេះ ពីបទរំលោភបំពានដ៏ធ្ងន់ធ្ងរនៃខក្រិដ្ឋកម្មសង្គ្រាម ។ ប៉ុន្តែយើងមិនអាចបង្ហាញថាបទចោទប្រកាន់នីមួយៗមានការពាក់ព័ន្ធនឹងជម្លោះប្រដាប់អាវុធជាមួយប្រទេសវៀតណាមនោះទេ ។ ការអត់ឃ្លានក្នុងរបបខ្មែរក្រហមហាក់ដូចជាមិនមានការពាក់ព័ន្ធទៅនឹងជម្លោះប្រដាប់អាវុធនោះទេ ដោយសារតែការអត់ឃ្លាន ដែលបានកើតឡើងនោះ បានបង្កឡើងដោយគោលនយោបាយរបស់រដ្ឋាភិបាលខ្មែរក្រហម ។ ជាងនេះទៅទៀត ជម្លោះប្រដាប់អាវុធជាមួយប្រទេសវៀតណាម មិនបានធ្វើឲ្យទិន្នផលដំណាំរបស់កម្ពុជាធ្លាក់ចុះនោះទេ ។ ជាក់ស្តែង ភូមិភាគដែលរងគ្រោះដោយសារការអត់ឃ្លានខ្លាំងជាងគេនៅក្នុងរបបខ្មែរក្រហមគឺភូមិភាគពាយ័ព្យ និងតំបន់មួយចំនួនទៀត ដែលនៅឆ្ងាយពីតំបន់ដែលមានជម្លោះប្រដាប់អាវុធជាមួយប្រទេសវៀតណាម ។ នេះសបញ្ជាក់ឲ្យឃើញថា ជម្លោះប្រដាប់អាវុធជាមួយប្រទេសវៀតណាម មិនបានបង្កឲ្យមានកង្វះខាតស្បៀងអាហារសម្រាប់ប្រជាជនស៊ីវិលនោះទេ ។

ជាសរុប ការអត់ឃ្លាន តែងតែកើតមានឡើងស្របពេលនឹងជម្លោះប្រដាប់អាវុធ និងសង្គ្រាម ។ ជាច្រើនសតវត្សរ៍កន្លងមកហើយ ច្បាប់មនុស្សធម៌បានបញ្ចូលចំណុចជាច្រើន ដើម្បីកាត់បន្ថយការបំផ្លាញចំពោះជនដែលមិនបានចូលរួមនៅក្នុងសង្គ្រាម ដែលក្នុងនោះរួមមាន ការដាក់ទោសចំពោះការប្រើប្រាស់ការបង្អត់អាហារជាយុទ្ធសាស្ត្រមួយក្នុងការធ្វើសង្គ្រាម ។ ជាក់ស្តែង គ្រោះអត់ឃ្លានដែលបានកើតឡើងនៅតំបន់ដាហ្វ័រ *(Darfur)* នៃប្រទេសស៊ូដង់ *(Sudan)* ឬ ប្រទេសសូម៉ាលី *(Somalia)* អាចចាត់ជាខក្រិដ្ឋកម្មសង្គ្រាមបានដោយយោងទៅតាមច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ។ ទោះជាយ៉ាងណាក៏ដោយ ការរំលោភបំពានធ្ងន់ធ្ងរចំពោះច្បាប់មនុស្សធម៌ អាចមានការពិបាកក្នុងការបង្ហាញថាជាខក្រិដ្ឋកម្មសង្គ្រាម បើយោងតាមបរិបទនៃការអត់ឃ្លានសម័យបច្ចុប្បន្ន ។ ថ្វីបើមានការពិបាកក្នុងការបង្ហាញខក្រិដ្ឋកម្មសង្គ្រាម នៅតែបន្តជាប់ទាក់ទងទៅនឹងករណីនៃការអត់ឃ្លានដដែល ឧទាហរណ៍ដូចជាការដកហូតស្បៀងអាហាររបស់ប្រជាជនស៊ីវិល ដោយប្រើកងយោធា ការបំផ្លាញផលិតកម្មស្បៀងអាហារ ឬការរំលោភបំពានធ្ងន់ធ្ងរទៅលើសិទ្ធិទទួលបានអាហាររបស់ជនស៊ីវិលនៅក្នុងទឹកដីដែលខ្លួនគ្រប់គ្រង ។ បទខក្រិដ្ឋកម្មសង្គ្រាមដែលបានរៀបរាប់ទាំងនេះ មិនបានឆ្លុះបញ្ចាំងពីការអត់ឃ្លាន ដែលបានកើតឡើងនៅក្នុងរបបខ្មែរក្រហមនោះទេ ហើយការអត់ឃ្លានដែលបានកើតឡើងនោះ មិនមានការជាប់ពាក់ព័ន្ធទៅនឹងជម្លោះប្រដាប់អាវុធជាមួយប្រទេសវៀតណាមនោះទេ ។ ផ្ទុយទៅវិញ វាគឺជាលទ្ធផលដែលកើតចេញពីគោលនយោបាយរបស់ខ្មែរក្រហម ។

លើសពីនេះទៅទៀត ដូចដែលយើងបានពិភាក្សាក្នុងវគ្គទី៥រួចមកហើយ ខក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ទំនងជាអាចយកមកអនុវត្តបានចំពោះករណីដែលរដ្ឋាភិបាលមួយធ្វើការរំលោភបំពានទៅលើប្រជាជនខ្លួនឯង ។ ដូច្នេះយើងអាចសន្និដ្ឋានបានថា ខក្រិដ្ឋកម្មសង្គ្រាមដែលមានការទាក់ទងនឹងការអត់ឃ្លាន ជាលទ្ធផលនៃជម្លោះប្រដាប់អាវុធ មិនអាចយកមកចោទប្រកាន់ចំពោះការអត់ឃ្លានដែលបានកើតឡើងក្នុងរបបខ្មែរក្រហមទេ ។

**រ៉ែនឌល ជីហ្វាល់កូ, ម៉ែន ពិចិត្រ និង លន់ ដាលីន**

# ថ្នាក់រៀននៅទួលស្លែង

មជ្ឈមណ្ឌលឯកសារកម្ពុជាបានបង្កើតថ្នាក់រៀនសាធារណៈមួយនៅសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ។ ថ្នាក់រៀននេះត្រូវបានបង្កើតឡើងក្នុងខែវិច្ឆិកា ឆ្នាំ២០១១ ដោយមានកិច្ចសហការរវាងមជ្ឈមណ្ឌលឯកសារកម្ពុជា និងក្រសួងវប្បធម៌ វិចិត្រសិល្បៈ ។ សារមន្ទីរទួលស្លែងគឺជាអតីតសាលារៀនដ៏ទំនើបមួយដែលបានសង់ឡើងជាលើកដំបូងនៅក្នុងឆ្នាំ១៩៦២ ។ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ខ្មែរក្រហមបានប្រែក្លាយសាលារៀននេះទៅជាគុកដ៏សម្ងាត់បំផុតមួយក្នុងចំណោមគុកចំនួន១៩៦ទូទាំងប្រទេស ។ អ្នកទោសភាគច្រើនដែលត្រូវបញ្ជូនទៅទួលស្លែងគឺជាកម្មាភិបាលខ្មែរក្រហមដែលត្រូវបានចោទប្រកាន់ពីបទប្រព្រឹត្តអំពើក្បត់ជាតិដូចជា ការសហការជាមួយរដ្ឋាភិបាលបរទេស ឬធ្វើជាអ្នកស៊ើបការណ៍ឲ្យសេ.អ៊ី.អា ឬ កា.ហ្សេ.បេ ជាដើម ។



ចាប់តាំងពីការប្រែក្លាយពីកន្លែងរៀនសូត្រមួយទៅជាកន្លែងដ៏គួរឲ្យរន្ធត់ និងមហន្តរាយមួយ ទួលស្លែងមិនដែលទទួលបានមុខងាររបស់ខ្លួនដូចកាលពីដើមវិញឡើយ ។ ទោះជាយ៉ាងនេះក្តី នៅពេលអនាគត ដើម្បីទាមទារមកវិញនូវកេរដំណែលអប់រំដែលមានលក្ខណៈវិជ្ជមានរបស់ទួលស្លែង និងដើម្បីបន្ថែមសមាសភាពអប់រំមួយទៅក្នុងសារមន្ទីរនេះ ថ្នាក់រៀននេះត្រូវបានបង្កើតឡើងដើម្បីផ្តល់ការបង្រៀន និងការពិភាក្សាដោយឥតគិតថ្លៃអំពីប្រវត្តិសាស្ត្ររបបខ្មែរក្រហម និងប្រធានបទដែលជាប់ទាក់ទងដូចជា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ថ្នាក់រៀននេះក៏ជាវេទិកាសាធារណៈមួយសម្រាប់ឲ្យអ្នកមកទស្សនា និងអ្នកដែលនៅរស់រានមានជីវិតចែករំលែកព័ត៌មានគ្នាក្នុងការថែរក្សារយៈកាលនៃប្រវត្តិសាស្ត្រកម្ពុជាដ៏មានសារសំខាន់មួយទុកឲ្យអ្នកជំនាន់ក្រោយបានរៀនសូត្រ ។

បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ដែលមានសញ្ញាបត្រមកពីបរទេស និងបានទទួលវិញ្ញាបនបត្រពីក្រសួងអប់រំ យុវជន និងកីឡា ផ្នែកការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-៧៩) ព្រមទាំងមានការចូលរួមពីអ្នកជំនាញជាតិនិងអន្តរជាតិដែលមានជំនាញលើប្រវត្តិសាស្ត្រប្រទេសកម្ពុជា និងអ្នកដែលនៅរស់រានមានជីវិតពីមន្ទីរស-២១ នឹងបង្រៀននៅថ្នាក់រៀននេះ ។ ព័ត៌មានទាក់ទងនឹងថ្នាក់រៀននេះ សូមទាក់ទង ស៊ុំរិ សាវីណា តាមរយៈទូរស័ព្ទលេខៈ ០២៣ ២១១ ៨៧៥ ឬអ៊ីម៉ែល : truthsavina.s@dccam.org

**◆ ទីកន្លែង : អាគារ "ក" ជាន់លើ ◆ ពេលវេលា : ច័ន្ទ ២-៣រសៀល, ពុធ ៩-១០ព្រឹក, សុក្រ ២-៣រសៀល**

# ការបោះឆ្នោត និងសាលាក្តីខ្មែរក្រហម

*តើការបោះឆ្នោតមានន័យយ៉ាងដូចម្តេចសម្រាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងអតីតខ្មែរក្រហម?*

នៅពេលដែលខ្ញុំកំពុងសរសេរអត្ថបទនេះ ខ្ញុំនៅតែមិនទាន់ច្បាស់នៅឡើយថាតើនរណានឹងបន្តដឹកនាំប្រទេសកម្ពុជាដោយសារទាំងគណបក្សប្រជាជនកម្ពុជារបស់សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន និងគណបក្សសង្គ្រោះជាតិរបស់លោក សម រង្ស៊ី នៅតែអះអាងពីជ័យជម្នះក្នុងការបោះឆ្នោតកាលពីថ្ងៃទី២៨ ខែកក្កដា រៀងៗខ្លួន ។ លទ្ធផលនៃការប្រឈមមុខដាក់គ្នានេះទំនងជានឹងជះឥទ្ធិពលយ៉ាងសំខាន់ដល់អនាគតនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

គណបក្សសង្គ្រោះជាតិមិនមានចំណាត់ការស៊ីសង្វាក់គ្នាទេទៅនឹងអតីតកាលរបស់ប្រទេសកម្ពុជា និងរបបកម្ពុជាប្រជាធិបតេយ្យ ។ ម្យ៉ាង គណបក្សសង្គ្រោះជាតិមានគោលនយោបាយជាយូរមកហើយថា អតីតកម្មាភិបាលខ្មែរក្រហមមួយចំនួនដែលបច្ចុប្បន្នកំពុងកាន់ដំណែងក្នុងរដ្ឋាភិបាលគួរតែត្រូវបានយកទៅជំនុំជម្រះ ។ ប៉ុន្តែម្យ៉ាងវិញទៀត ប្រធានស្តីទីគណបក្សសង្គ្រោះជាតិ លោក កឹម សុខា ដែលត្រូវបានថតជាសំឡេងដោយបានអះអាងថា អំពើឃោរឃៅដែលបានប្រព្រឹត្តឡើងនៅមន្ទីរស-២១ ត្រូវបានរៀបចំឡើងជាឆាកដោយវៀតណាម ។ ក្រោយមក លោក កឹម សុខា បានច្រានចោលបទអត្ថាធិប្បាយបែបនេះដោយបកស្រាយថា បទអត្ថាធិប្បាយនោះត្រូវបានប្រឌិតឡើង និងក្រឡៃខុសពីពាក្យសម្តីពិតប្រាកដរបស់គាត់ ហើយគាត់បានបកស្រាយវិញថា ខ្មែរក្រហមបានរៀបចំគុកទួលស្លែង ជាឆាកល្ខោន មិនមែនវៀតណាមជាអ្នករៀបចំនោះឡើយ ។

យើងអាចប្រមើលមើលឃើញថា ការកើនឡើងនៃអំណាចរបស់គណបក្សសង្គ្រោះជាតិ នឹងនាំទៅរកការកើនឡើងនៃការគាំទ្រតុលាការ ប្រសិនបើគណបក្សសង្គ្រោះជាតិទទួលជ័យជម្នះ ឬកើនកៅអីនៅរដ្ឋសភាជាតិ ។

ផ្ទុយទៅវិញ ប៉ុន្មានឆ្នាំថ្មីៗនេះ គណបក្សប្រជាជនកម្ពុជារបស់នាយករដ្ឋមន្ត្រី ហ៊ុន សែន ចង់ឲ្យតុលាការបញ្ចប់សំណុំរឿងរបស់ខ្លួនដោយមិនចោទប្រកាន់នរណាបន្ថែមទៀតឡើយ ។ ក្នុងឆ្នាំ២០១០ នាយករដ្ឋមន្ត្រី ហ៊ុន សែន បានប្រាប់អគ្គលេខាធិការអង្គការសហប្រជាជាតិ បាន គីមូន ថា គាត់រំពឹងថា សំណុំរឿង ០០២នឹងក្លាយជាសំណុំរឿងចុងក្រោយដែលត្រូវបានជំនុំជម្រះនៅតុលាការ ។ ដូច្នេះហើយ លទ្ធផលនៃការបោះឆ្នោតនាពេលបច្ចុប្បន្ន ទំនងជានឹងជះឥទ្ធិពលយ៉ាងសំខាន់ដល់ជំហររបស់រដ្ឋាភិបាលលើសំណុំរឿង០០៣និង០០៤ ។

វាមិនមែនគ្រាន់តែជាជំហររបស់រដ្ឋាភិបាលមួយមុខនោះទេដែលការបោះឆ្នោតនឹងក្លាយជាចំណោទបញ្ហានោះ ប៉ុន្តែសហគមន៍អន្តរជាតិក៏ជាចំណោទបញ្ហាមួយដែរ ដែលជាម្ចាស់ជំនួយដ៏សំខាន់ដែលអាចធ្វើឲ្យកិច្ចដំណើរការតុលាការបន្តទៅទៀតបាន ។ ការមិនគាំទ្ររបស់ម្ចាស់ជំនួយគឺជាបញ្ហាយ៉ាងសំខាន់សម្រាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ខណៈដែលជំនួយថវិការបស់អន្តរជាតិនៅតែជាបញ្ហាគន្លឹះដល់ការគាំទ្របុគ្គលិកទាំងផ្នែកជាតិ និងអន្តរជាតិ ។ ប្រការនេះមានន័យថា ប្រសិនបើរដ្ឋាភិបាលកម្ពុជាបាត់បង់ជំនួយពីសហគមន៍អន្តរជាតិ តុលាការអាចប្រឈមមុខទៅនឹងការបន្តនិរន្តរភាពរបស់ខ្លួនកាន់តែខ្លាំងជាងមុន ។ មុនការបោះឆ្នោតប្រព្រឹត្តឡើង សមាជិកសភាជាតិអាមេរិកបានសង្កត់ធ្ងន់លើសារសំខាន់នៃការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅក្នុងប្រទេសកម្ពុជា និងលទ្ធភាពនៃលក្ខខណ្ឌដែលឆ្លើយតបទៅនឹងជំនួយនាពេលអនាគត ។ ចាប់តាំងពីពេលនោះមក សហរដ្ឋអាមេរិកបានអំពាវនាវឲ្យមានការស៊ើបអង្កេតលើភាពមិនប្រក្រតីក្នុងការបោះឆ្នោត ។

ប្រសិនបើគណបក្សប្រជាជនកម្ពុជាបន្តព្រងើយកន្តើយនឹងការអំពាវនាវ ហើយបដិសេធមិនស៊ើបអង្កេតលើការចោទប្រកាន់ពីភាពមិនប្រក្រតីដែលមានទម្រង់ជាប្រព័ន្ធក្នុងអំឡុងការបោះឆ្នោត កម្ពុជានឹងក្លាយជាប្រទេសដែលមិនសូវមានចំណាប់អារម្មណ៍សម្រាប់ម្ចាស់ជំនួយអន្តរជាតិដែលនឹងធ្វើឲ្យមានការប៉ះពាល់ដល់ជំនួយថវិការបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ **សែមិន គ្រូស័រ**

# ពាក្យចចាមអារ៉ាម និង ការឮគេថា អាចបង្កឱ្យមានជម្លោះ

ទោះបីជាមាន "ពាក្យចចាមអារ៉ាម និងការឮគេថាដែលជាការនិយាយតគ្នា" អំពីអស្ថិរភាព សង្គមនៅប្រទេសកម្ពុជាក៏ដោយ ក៏គណៈកម្មការជាតិរៀបចំការបោះឆ្នោតសម្រេចនិងបន្តកិច្ចដំណើរការរបស់ខ្លួនដោយធ្វើការប្រកាសលទ្ធផលបឋមផ្លូវការនៃការបោះឆ្នោតកាលពីថ្ងៃចន្ទ ទី១២ ខែសីហាកន្លងទៅ ។ ខ្លួនខ្ញុំផ្ទាល់មានក្តីបារម្ភយ៉ាងខ្លាំងថា ពាក្យចចាមអារ៉ាម និងការឮគេថាដែលជាការនិយាយតគ្នាអាចបញ្ឆេះជម្លោះដែលប្រជាជនកម្ពុជាធ្លាប់បានភ័យខ្លាចពីមុនមកហើយកាលពីអំឡុង និងក្រោយព្រឹត្តិការណ៍បោះឆ្នោតកាលពីថ្ងៃទី២៨ ខែកក្កដាកន្លងទៅ ។ ពាក្យចចាមអារ៉ាម និងការឮគេថា ដែលជាការនិយាយតគ្នានេះ ហាក់បីដូចជាមានន័យប្រហាក់ប្រហែលគ្នានៅក្នុងភាសាខ្មែរ តែតាមផ្លូវច្បាប់ ពាក្យទាំងពីរនេះមានការបកស្រាយខុសគ្នា ។

តាមវចននុក្រម អកហ្វដ ពាក្យ "ចចាមអារ៉ាម" មានន័យថា "...ការផ្សព្វផ្សាយរឿងរ៉ាវ ឬហេតុការណ៍អ្វីមួយដែលជារឿងមិនពិត ឬការពិតប្រកបដោយភាពមន្ទិលសង្ស័យនៅឡើយ" ។ ជាធម្មតាពាក្យ "ចចាមអារ៉ាម" កើតចេញពីការនិយាយតគ្នាពីមាត់មួយទៅមាត់មួយដោយគ្មានប្រភពណាច្បាស់លាស់ឡើយ ដោយបម្រើគោលបំណងអ្វីមួយរបស់បុគ្គលឬក្រុមណាមួយ ។ ពាក្យនេះក៏មានអត្ថន័យប្រហាក់ប្រហែលទៅនឹងពាក្យ "ការឮគេថាដែលជាការនិយាយតគ្នាដែរ" ។ វចនានុក្រមច្បាប់បកស្រាយអត្ថន័យនៃពាក្យ "ការឮគេថាដែលជាការនិយាយតគ្នា" ថា "សក្ខីកម្មអ្វីមួយដែលត្រូវបានរៀបរាប់ដោយសាក្សីណាម្នាក់ដែលសាក្សីនោះមិនបានដឹងហេតុការណ៍នោះដោយផ្ទាល់ទេ តែដឹងនិងឮតាមអ្នកផ្សេងទៀតនិយាយឬក៏រឿងរ៉ាវនោះពឹងលើមនុស្សមួយផ្សេងទៀតជា



ក្រុមយុវជនគណបក្សសង្គ្រោះជាតិចូលរួមឃោសនាសម្រាប់ការបោះឆ្នោតជាតិ អាណត្តិទី៥ ដែលបានប្រព្រឹត្តទៅនៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៣ កន្លងទៅ

ជាងសាក្សីម្នាក់នោះផ្ទាល់” ។ ពាក្យទាំងពីរនេះរៀបរាប់ពីរបៀបដែលព័ត៌មានអាចរាលដាលដោយគ្មានប្រភព និងការបញ្ជាក់ច្បាស់លាស់ប៉ុន្តែ “ការឮគេថាដែលជាការនិយាយតគ្នា” អាចត្រូវបានបញ្ជាក់តាមផ្លូវច្បាប់ តាមរយៈតាមការផ្ទៀងផ្ទាត់ជាមួយឯកសារ ឬសក្ខីកម្ម ជាពិសេសនៅក្នុងតុលាការ ។

វាសឹងតែជារឿងធម្មតា ដែលសង្គមកម្ពុជារស់នៅជាមួយនឹងហេតុការណ៍មិនពិតដែលទីបញ្ចប់ភាពស្មោះត្រង់របស់ប្រជាជន និងប្រទេសជាតិរបស់ខ្លួនឋិតនៅក្នុងភាពគ្រោះថ្នាក់ ។ ថ្មីៗនេះពាក្យចចាមអារ៉ាមអំពីជម្លោះកំពុងតែសាយភាយក្រោយពីលទ្ធផលនៃការបោះឆ្នោតត្រូវបានប្រកាស ។

ក្នុងអំឡុងថ្ងៃបោះឆ្នោត ពាក្យចចាមអារ៉ាមមួយបានសាយភាយទូទាំងរាជធានីភ្នំពេញថា មានការចល័តទ័ពដែលជាសញ្ញាថាសង្គ្រាមនឹងអាចផ្ទុះឡើង ។ មួយសន្ទុះក្រោយមកទើបលេចឮព័ត៌មានថាមានកូដកម្មមួយ នៅស្ទឹងមានជ័យដែលរថយន្តពីរគ្រឿងរបស់កងរាជអាវុធហត្ថ ត្រូវបានដុតបំផ្លាញដោយក្រុមកូដករ ។ ជាមួយគ្នានោះដែរ ពាក្យនិយាយពីមាត់មួយទៅមាត់មួយធ្វើឲ្យប្រជាជនមានភាពភ័យស្លន់ស្លោ តក់ស្លុត និងប្រញាប់ប្រញាល់ទិញអង្ករប្រេងសាំង និងរបស់របរផ្សេងៗទៀតទុកដើម្បីបង្ការពេលមានជម្លោះ ។

ពីរបីថ្ងៃក្រោយថ្ងៃការបោះឆ្នោត គណបក្សសង្គ្រោះជាតិដឹកនាំដោយ សម រង្ស៊ី បានគំរាមថា នឹងធ្វើមហាបាតុកម្មទូទាំងប្រទេស ចំណែកឯគណបក្សប្រជាជនកម្ពុជាឯណោះវិញបានបង្កើនកម្លាំងនិងវត្តមានកងប្រដាប់អាវុធក្នុងរាជធានីភ្នំពេញដើម្បីរក្សាសន្តិសុខនិងសណ្តាប់ធ្នាប់សង្គម ។ ពេលមានសកម្មភាពបែបនេះពាក្យចចាមអារ៉ាមកាន់តែរីកសាយភាយថែមទៀតថា ផ្លូវខ្លះក្បែរវិមានឯករាជ្យ ត្រូវបានបិទមិនឲ្យមានចរាចរណ៍ឆ្លងកាត់ ដែលប្រជាជនមើលឃើញថា ភាពវឹកវរនឹងកើតមានឡើង ។ អំឡុងពេលនេះ ការចល័តកងប្រដាប់អាវុធចូលក្នុងរាជធានីភ្នំពេញបានបង្កឲ្យមានភាពវឹកវរថែមមួយកម្រិតទៀតទូទាំងប្រទេស ។ ពាក្យចចាមអារ៉ាមឬការឮគេថាដែលជាការនិយាយតគ្នាអំពីជម្លោះលេចឡើងកាន់តែច្បាស់ប្រសិនបើគណបក្សសង្គ្រោះជាតិបន្តមានគម្រោងធ្វើបាតុកម្មដែលអាចនឹងបង្កឲ្យមានអំពើហិង្សា ដោយប្រការណាមួយនោះ ។ ប្រសិនបើហេតុការណ៍នេះកើតឡើងពិតប្រាកដមែន ឈាមខ្មែរប្រាកដជាហូរទៀតជាមិនខាន ដែលប្រការនេះ ប្រជាជនកម្ពុជាលែងត្រូវការទៀតហើយ ។

ក្រោយពីលទ្ធផលឆ្នោតដំបូងការបឋមលើកទីមួយត្រូវបានប្រកាសកាលពីថ្ងៃច័ន្ទ ទី១២ ខែសីហា កន្លងទៅ មានការលេចឮពាក្យចចាមអារ៉ាមជាច្រើននៅទូទាំងប្រទេស ។ អ្នកគាំទ្រប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិបានបញ្ចេញមតិនិងប្រតិកម្មផ្សេងៗជាច្រើនរួមទាំងភាពសុទិដ្ឋិនិយមផង និងក្តីបារម្ភផង ។ និស្សិតឆ្នាំទីបួនម្នាក់ឈ្មោះ រ៉េន ចាន់រិទ្ធ អាយុ២៨ឆ្នាំ និងជាអ្នកគាំទ្ររបស់គណបក្ស សង្គ្រោះជាតិបានព្រឹត្តិមានថា មនុស្សម្នាមានការខកចិត្តជាខ្លាំងទៅនឹងលទ្ធផលឆ្នោតដែលបានប្រកាសដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ជាពិសេសក្នុងស្រទាប់យុវជន ដែលមានការខកចិត្តជាខ្លាំង មិនត្រឹមតែប្រធានគណបក្សសង្គ្រោះជាតិ លោក សម រង្ស៊ី ប៉ុណ្ណោះទេ ។ មានពាក្យចចាមអារ៉ាមទៀតថា អ្នកគាំទ្រគណបក្សសង្គ្រោះជាតិមិនចង់ឲ្យលោក សម រង្ស៊ី ចូលរួមបែងចែកអំណាចជាមួយគណបក្សកាន់អំណាចទេ ។ ការតវ៉ាទ្រង់ទ្រាយធំដែលជាមធ្យោបាយដ៏ពេញចិត្តបំផុតគឺការទាមទារឲ្យមានអង្គភាពឯករាជ្យមួយដើម្បីដោះស្រាយបញ្ហាមិនប្រក្រតីទាំងឡាយដែលបានកើតឡើងក្នុងអំឡុងពេលនៃការបោះឆ្នោត ។ យុវនារីម្នាក់ឈ្មោះ លីនដា អាយុ១៩ឆ្នាំ រស់នៅទីក្រុងភ្នំពេញ បាននិយាយថា គាត់ឮពាក្យចចាមអារ៉ាមថានឹងមានជម្លោះប្រដាប់អាវុធនៅរាជធានីភ្នំពេញ ។ ថ្លៃអាហារចាប់ផ្តើមឡើងថ្លៃខ្លាំង ។ ក្នុងនាមជាអ្នកគាំទ្រម្នាក់របស់គណបក្សប្រជាជនកម្ពុជា លីនដា មានក្តីបារម្ភថា បាតុកម្មទ្រង់ទ្រាយធំនឹងបង្កឲ្យមានការរាំងស្ទះដល់ការអភិវឌ្ឍជាតិ ។ ខុសពី ចាន់រិទ្ធ លីនដា មានក្តីសុទិដ្ឋិនិយមថា គណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិនឹងដោះស្រាយជម្លោះជាមួយគ្នាដោយសន្តិវិធី ។

សំណួរគឺថា តើវិធានការបែបណាដែលប្រជាជនកម្ពុជាគួរតែចាត់ដើម្បីទប់ស្កាត់ពាក្យចចាមអារ៉ាមដែលអាចបង្កឲ្យមានភាពអសណ្តាប់ធ្នាប់នៅក្នុងសង្គម? ចម្លើយគឺសាមញ្ញបំផុត ។ ប្រជាជន កម្ពុជាត្រូវតែធ្វើជាអ្នកត្រួតត្រាពាក្យចចាមអារ៉ាម និងការឮគេថា ដែលជាការនិយាយតគ្នា ជាជាងទុកឲ្យពាក្យចចាម

អាវ៉ាមនោះគ្រប់ដណ្ដប់យើងវិញ ។ បើធ្វើដូច្នេះបានអ្នកនយោបាយនឹងមិនអាចប្រើប្រាស់ប្រជាជនបានឡើយ ។ ក្នុងនាមជាម្ចាស់នៃរដ្ឋមួយដែលមានបូរណភាពដែនដីត្រឹមត្រូវ ប្រជាជនកម្ពុជាបានអនុវត្តសិទ្ធិរបស់ខ្លួនរួចទៅហើយតាមរយៈការបោះឆ្នោតឲ្យគណបក្សនយោបាយដែលខ្លួនពេញចិត្ត ។ ទង្វើបែបនេះសបញ្ជាក់ពីកាតព្វកិច្ចល្អរបស់ពលរដ្ឋ ដូច្នេះវាជារឿងមិនសក្ដិសមទាល់តែសោះ ដែលគណបក្សនយោបាយណាមួយយកប្រជាជនឲ្យប្រឈមមុខទៅនឹងស្ថានភាពវឹកវរបែបនេះទៀតនោះ ។ ការអនុវត្តតាមបែបប្រជាធិបតេយ្យរបស់ប្រជាជនកម្ពុជាបានបង្ហាញនូវការជឿទាស់ទៅនឹងគំរូនៅប្រទេសមួយចំនួននៅអាហ្វ្រិកខាងជើងដែលប្រជាជនបានបង្កើតបដិវត្តន៍បះបោរទៅនឹងរបបណាមួយដែលខ្លួនមិនពេញចិត្ត ។ ប្រជាជនកម្ពុជាបានប្រើប្រាស់ប្រជាធិបតេយ្យតាមរយៈការបោះឆ្នោតជាជាងការបះបោរ ។

គណបក្សប្រជាជនកម្ពុជាគួរតែបញ្ឈប់ការប្រើប្រាស់កងកម្លាំងប្រដាប់អាវុធ ដើម្បីបង្ក្រាបពលរដ្ឋរបស់ខ្លួនតទៅទៀត ចំណែកឯគណបក្សសង្គ្រោះជាតិឯណោះវិញគួរតែឈប់ប្រើប្រាស់ប្រជាជនរបស់ខ្លួន ជាពិសេសយុវជន ឲ្យចូលរួមធ្វើមហាបាតុកម្មដែលបង្កឲ្យមានអស្ថិរភាពនៅក្នុងប្រទេស ។ គណបក្សទាំងពីរគួរតែដោះស្រាយបញ្ហាដោយវិធីសមស្របណាមួយដែលអាចទទួលយកបានទាំងសងខាង ដោយមិនបង្កឲ្យមានជម្លោះណាមួយកើតឡើង ។ ការប្រើប្រាស់ជម្លោះមកដោះស្រាយ និងនាំប្រទេសជាតិឲ្យធ្លាក់ទៅក្នុងវណ្ដៅអវិចី ឬធ្លាក់ទៅក្នុងសម័យមួយដែលអស្ថិរភាពនៅក្នុងសង្គមនិងកើតឡើងម្ដងទៀត ក្រោយពីប្រទេសយើងបានពើបប្រទះនូវជម្លោះផ្ទៃក្នុង សង្គ្រាមស៊ីវិល និងអំពើប្រល័យពូជសាសន៍អស់រយៈពេលជាយូរមកហើយ ។

គណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិគួរតែសិក្សាពីគោលនយោបាយរបស់ខ្លួន ក្នុងន័យថា នឹងអាចបម្រើដល់ប្រយោជន៍ប្រជាជន និងមាតុភូមិជាទីស្រលាញ់របស់យើងទាំងអស់គ្នា ។ ប្រជាជនកម្ពុជាគ្រប់ស្រទាប់វណ្ណៈទាំងអស់គួរតែចាំក្នុងចិត្តថា ខ្លួនគឺជាម្ចាស់នៃប្រទេស ហើយមិនគួរត្រូវទទួលរងក្នុងស្ថានភាពណាមួយ ដោយការញុះញង់ពីសំណាក់គណបក្សនយោបាយណាមួយទេ រួមទាំងគណបក្សកំពុងកាន់អំណាច និងគណបក្សជំទាស់ផងដែរ ។

អតីតប្រធានាធិបតីសហរដ្ឋអាមេរិក ចន កេណ្ណឺឌី បាននិយាយថា "សូមកុំសួរថាតើប្រទេសរបស់អ្នកអាចជួយអ្វីខ្លះដល់អ្នក តែសូមសួរខ្លួនឯងវិញថា តើអ្នកអាចជួយអ្វីខ្លះដល់ប្រទេសរបស់អ្នក" ។ ពាក្យនេះប្រហែលជាសក្ដិសមទៅនឹងបរិបទកម្ពុជាសព្វថ្ងៃណាស់ ដែលគណបក្សទាំងពីរគួរតែគិតរួមគ្នាដើម្បីអភិវឌ្ឍប្រទេស និងដឹកនាំប្រទេសឆ្ពោះទៅរកវឌ្ឍនភាពដើម្បីប្រកួតប្រជែងជាមួយបណ្ដាប្រទេសផ្សេងទៀតនៅអាស៊ីអាគ្នេយ៍ និងអារ្យប្រទេសនានាលើលោក ។ គណបក្សដែលកំពុងតែប្រកួតប្រជែងគ្នាគួរតែរៀនពីវិធីដោះស្រាយដោយសន្តិវិធីប្រសើរជាង ចំណែកឯកងទ័ព និងប្រជាជន ជាពិសេសយុវជន មិនគួរធ្វើឲ្យពាក្យចចាមអារ៉ាម និងការព្រុតគេថា ដែលជាការនិយាយតគ្នា នាំប្រទេសជាតិឲ្យធ្លាក់ក្នុងភាពចលាចលទេ ។ **លី សុខឃាង**

## ស្ដាប់រឿងរ៉ាវប្រវត្តិសាស្ត្រតាមវិទ្យុ

មជ្ឈមណ្ឌលឯកសារកម្ពុជាមានកម្មវិធី "សំឡេងអំពើប្រល័យពូជសាសន៍ៈ យុត្តិធម៌ និងការអត់ឃ្មាន" ដែលចាក់ផ្សាយតាមស្ថានីយ៍វិទ្យុដូចខាងក្រោមរៀងរាល់ថ្ងៃអាទិត្យ ។

ប្រិយមិត្តដែលរស់នៅរាជធានីភ្នំពេញ និងនៅខេត្តអាចស្ដាប់កម្មវិធីវិទ្យុសហគមន៍របស់យើងខ្ញុំតាមរយៈ ៖

◆ វិទ្យុជាតិកម្ពុជា FM 105.75 MHz រាជធានីភ្នំពេញ វេលាម៉ោង១ រសៀល និងម៉ោង៧និង៣០ នាទីល្ងាច ។

◆ វិទ្យុខេត្តកំពត FM 93.25 MHz វេលាម៉ោង៧ព្រឹក និងម៉ោង៧ល្ងាច ។

◆ វិទ្យុខេត្តព្រះវិហារ FM 99 MHz វេលាម៉ោង៧:៣០ ព្រឹក និងម៉ោង៤រសៀល ។

◆ វិទ្យុខេត្តបាត់ដំបង FM 103.25 MHz វេលាម៉ោង៨ព្រឹក និងម៉ោង៤រសៀល ។

សម្រាប់ព័ត៌មានលម្អិត សូមទាក់ទង ម៉ែន ពិចិត្រ តាមរយៈទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ឬ០៩២ ១៦៨ ៥៤៣ ។

# ជនជាប់ចោទ នួន ជា ប្រឆាំងទៅនឹងការបំបែកសំណុំរឿង ដែលមិនយុត្តិធម៌ចំពោះរូបគាត់នៅក្នុងតុលាការ

នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ជនជាប់ចោទ នួន ជា បានបដិសេធទៅនឹងការបំបែកសំណុំរឿងទីពីរបស់អង្គជំនុំជម្រះសាលាដំបូងនៅក្នុងដីកាបញ្ជូនសំណុំរឿងទៅជំនុំជម្រះក្នុងករណី០០២ ដែលអះអាងថាជាការរំលោភលើសិទ្ធិរបស់គាត់ក្នុងការស្រាយបំភ្លឺនៅក្នុងតុលាការ ។ ទាំងក្រុមមេធាវីការពារក្តីរបស់ នួន ជា និងព្រះរាជអាជ្ញាជាច្រើនរូបស្នើសុំឲ្យអង្គជំនុំជម្រះសាលាដំបូងជួយពន្លឿនសម្របសម្រួលឡើងវិញ និងកំណត់នូវកម្រិតការចោទប្រកាន់ក្នុងការអនុវត្តមុនពេលដំណើរការនីតិវិធីបន្ថែមទៀតចំពោះករណីដែលនៅសេសសល់ ។ ខណៈពេលដែលព្រះរាជអាជ្ញាព្យាយាមបញ្ចូលនូវទីតាំងឧក្រិដ្ឋកម្មមួយបន្ថែមទៀតលើដំណើរការនីតិវិធីក្នុងសំណុំរឿង០០២/០១ នួន ជា ធ្វើការតវ៉ាថា មានតែអង្គជំនុំជម្រះតែមួយសម្រាប់ការចោទប្រកាន់ទាំងអស់នៅក្នុងដីកាបញ្ជូនសំណុំរឿងទៅជំនុំជម្រះតែប៉ុណ្ណោះ ដែលអាចការពារនូវមូលដ្ឋានសិទ្ធិរបស់គាត់បាន ។

បណ្តឹងឧទ្ធរណ៍នៅក្នុងការបំបែកសំណុំរឿងរបស់ នួន ជា កាលពីខែឧសភា បង្ហាញថា ទាំងព្រះរាជអាជ្ញា និងអង្គជំនុំជម្រះសាលាដំបូងបានទទួលស្គាល់នូវតម្រូវការភ័ស្តុតាងផ្សេងៗ និងមធ្យោបាយមួយចំនួននៅក្រៅសំណុំរឿង០០២/០១ហើយនឹងបានយល់ស្របពីការលំបាកក្នុងការ «កំណត់នូវផ្នែកជាក់លាក់» ចំពោះដីការបញ្ជូនសំណុំរឿងដែលបន្តរំលោភលើលទ្ធភាពរបស់ នួន ជា ក្នុងការប្រឈមមុខចំពោះសាក្សី ។ កាលពីដើមខែកក្កដាកន្លងទៅក្រុមមេធាវីការពារក្តីបានស្នើសុំឲ្យអង្គជំនុំជម្រះ តុលាការកំពូលពិចារណាលើឧទាហរណ៍ដែលមានស្រាប់ចំពោះបញ្ហាបន្ថែមទៀតដោយចោទថា ទន្សីករណ៍ថ្មីដែលអង្គជំនុំជម្រះសាលាដំបូងលើកឡើងទំនងជាមានចេតនាបង្ហាញនូវការពិតណាមួយក្នុងសំណុំរឿង០០២/០១ ដោយសំអាងលើភ័ស្តុតាងដែលចុងចោទមិនត្រូវបានផ្តល់ឱកាសក្នុងការបកស្រាយ ។

ដីកាបញ្ជូនសំណុំរឿងទៅជំនុំជម្រះពេញលេញក្នុងករណី ០០២ ដែលត្រូវបានស្គាល់ថាជាគោលការណ៍លាតសន្ធឹងប្រាំប្រទេសចំពោះឧក្រិដ្ឋកម្មចោទប្រកាន់លើអតីតមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមចំពោះទំនួលខុសត្រូវក្នុងការចូលរួមឧក្រិដ្ឋកម្មនេះ ។ ជាកិច្ចឆ្លើយតបទៅនឹងបញ្ហានេះ អង្គជំនុំជម្រះសាលាដំបូងសម្រេចលើ «ការបែងចែកដំណើរការនីតិវិធីក្នុងសំណុំរឿង០០២…ទៅជាផ្នែកតូចជាច្រើនដាច់ៗពីគ្នាការចោទប្រកាន់អាស្រ័យលើអង្គហេតុ និងអង្គច្បាប់ ។ ចំពោះករណីសំណុំរឿង០០២/០១ មានចេតនាចង់បង្ហាញនូវតួនាទី និងទំនួលខុសត្រូវរបស់ចុងចោទទៅលើគោលនយោបាយ (ទាំងប្រាំ) នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះទាំងមូល ។ ទោះបីជាយ៉ាងនេះក៏ដោយ មានតែគោលនយោបាយដែលពាក់ព័ន្ធនឹងការប្រែប្រួលនូវទំហំបរិមាណនៃចំនួនប្រជាជននោះទេដែលត្រូវបាន «សិក្សាស៊ីជម្រៅទៅលើអង្គហេតុ» ។ អាស្រ័យហេតុនេះឆ្លងកាត់រាល់ការជំនុំជម្រះសាលាដំបូងសាក្សីទូទៅតែងតែមានសំណួរលើកឡើងអំពីគោលការណ៍ដែលនៅសល់ត្រូវបានដាក់កំហិតដែលនាំមកនូវលទ្ធផលមិនស្មើគ្នា អាស្រ័យលើទំនាក់ទំនងរវាងការចោទប្រកាន់នីមួយៗ ។

ក្រុមមេធាវីការពារក្តីរបស់ នួន ជា បដិសេធថា ទោះជាមិនមានភាពនឹងន តែការចោទប្រកាន់ទាំងអស់នៅក្នុងករណីសំណុំរឿង០០២/០១ក្រៅពីដីកាបញ្ជូនសំណុំរឿងទៅជំនុំជម្រះដែលមានភាពច្បាស់លាស់ បានក្លាយជាស្រពេចស្រពិលដោយសារការអនុញ្ញាតឲ្យធ្វើការអង្កេតអង្គហេតុក្រៅវិសាលភាពក្នុងសំណុំរឿងនេះ ។ ជាឧទាហរណ៍ កំណត់ហេតុរាប់រយជាលាយលក្ខណ៍អក្សររបស់សាក្សីដោយមិនមានការពន្យល់ និងពាក់ព័ន្ធ ។ ទោះបីនេះជាលើកដំបូងរបស់ក្រុមការពារក្តីរូបនេះក្នុងការប្រឆាំងទៅនឹងការបំបែកសំណុំរឿងយុត្តិធម៌ក៏ដោយ ក៏បញ្ហាប្រឈមជាច្រើនលើកច្រើនសាបានកើតឡើងរួចទៅហើយចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ព្រះរាជអាជ្ញានិងដើមបណ្តឹងរដ្ឋប្បវេណីក្នុងការលើកយកនូវឯកសារចម្លើយសារភាពជាច្រើនជំនួសឲ្យការធ្វើសក្ខីកម្មផ្ទាល់

មាត់ដែលនេះគឺជាការរំលោភលើសិទ្ធិក្នុងការសួរដេញដោលសាក្សីរបស់ជនជាប់ចោទ ។ នៅក្នុងបណ្ដឹងថ្មីរបស់ខ្លួន មេធាវីការពារក្ដី នួន ជា អះអាងថា ការពិភាក្សាលើបណ្ដឹងស្ដីពីឯកសារថ្មីៗបង្ហាញថា ឯកសាររួមមានចម្លើយសាក្សីនឹងត្រូវបានអនុញ្ញាតឲ្យដាក់ជូនថ្មីបើការពិតដែលថា ឯកសារទាំងនោះផ្ទុកព័ត៌មានដែលមិនអាចការពារក្ដីដែលស្ថិតនៅក្រៅវិសាលភាពនៃសំណុំរឿង០០២/០១ ហើយព័ត៌មាននេះជៀសមិនផុតពីការត្រូវផ្អែកលើការចេញសេចក្ដីសម្រេចក៏ដោយ ។

កាលពីចុងខែមិថុនា សវនាការលើបណ្ដឹងឯកសារត្រូវបានធ្វើឡើងទាក់ទងទៅនឹងសហឧក្រិដ្ឋកម្មរួមក្នុងចំណោមមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមដែលមានគោលនយោបាយសហឧក្រិដ្ឋកម្មរួមប្រាំយ៉ាង ។ ដោយសារតែមានការដកចេញការចោទប្រកាន់ពីបទការជម្លៀសដោយបង្ខំ និងការដោសម្លាប់សត្រូវនៅកន្លែងវាលពិឃាតនោះដែលជាការចោទប្រកាន់ក្នុងសំណុំរឿង០០២/០១ ភាគីត្រូវបានជូនដំណឹង ដើម្បីដោះស្រាយលើបញ្ហាអត្ថិភាពនៃគោលនយោបាយសហឧក្រិដ្ឋកម្មរួម មិនមែនជាការអនុវត្តគោលនយោបាយសហករណ៍នោះឡើយដោយសារនេះគឺជាកម្មវត្ថុនៃការជំនុំជម្រះក្ដីនាពេលអនាគត ។ ឧទាហរណ៍ ក្នុងការបដិសេធលើការជំទាស់ទាក់ទងទៅនឹងឯកសាររបស់មេធាវីការពារក្ដី ខៀវ សំផន ចៅក្រមហ្សង់ម៉ាក ឡាវែញ បានសង្កត់ធ្ងន់ថា ឯកសារចោទសួរនោះមិនបានដោះស្រាយអំពីការអនុវត្តគោលនយោបាយសហករណ៍ឡើយ ។ ពិតប្រាកដណាស់ វាគឺជាការអនុវត្តនៅមូលដ្ឋាន ដែលមិនមែនជាផ្នែកនៃការបង្ហាញឯកសារសំខាន់នៃការជំនុំជម្រះក្ដីនេះឡើយ ។

មេធាវីការពារក្ដីទាំងពីររបស់ នួន ជា បានជំទាស់ថា ដើមបណ្ដឹងរដ្ឋប្បវេណី នឹងបង្ហាញនូវចម្លើយសាក្សី ដែលនិយាយអំពីការអនុវត្តគោលនយោបាយនៅមូលដ្ឋាន ។ បន្ទាប់មក សហព្រះរាជអាជ្ញាបាននិយាយលើកហេតុផលថា យោងតាមយុទ្ធសាស្ត្រនៃតុលាការអន្តរជាតិ ទាំងអត្ថិភាព និងការបង្កើតគោលនយោបាយត្រូវបានស្ដែងឲ្យឃើញតាមរយៈរបាយការណ៍ពីមូលដ្ឋានរួមមានអង្គហេតុដែលបង្ហាញពីការអនុវត្តគោលនយោបាយយ៉ាងទូលំទូលាយ ។

ជាការឆ្លើយតប មេធាវីការពារក្ដី ខៀវ សំផន បាននិយាយពោលលើកហេតុផលថា ៖

> នៅចំពោះមុខយើងថ្ងៃនេះ យើងមានស្ថានភាពមួយដែលសហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខដើមបណ្ដឹងរដ្ឋប្បវេណីកំពុងតែប្រាប់អ្នកថា យើងមិនអាចនិយាយអំពីគោលនយោបាយដែលមិនពាក់ព័ន្ធក្នុងសំណុំរឿង០០២/០១ ដោយមិននិយាយអំពីការអនុវត្តគោលនយោបាយនៅមូលដ្ឋានឡើយ ។ តើវាមានន័យយ៉ាងដូចម្ដេចអំពីការនិយាយស្របច្បាប់? វាមានន័យថា អ្នកកំពុងតែផ្ដល់សិទ្ធិអំណាចក្នុងការបង្ហាញភ័ស្ដុតាងស្ដីពីគោលនយោបាយដែលមិនជាប់ពាក់ព័ន្ធក្នុងសំណុំរឿង០០២/០១ ដែលមានន័យថា ឯកសារមួយចំនួនមិនមែនជាកម្មវត្ថុនៃការជំនុំជម្រះក្ដីក្នុងសំណុំរឿង០០២/០១នៅចំពោះមុខអ្នកឡើយ ហើយយើងគួរតែឆ្លើយតបទៅនឹងបញ្ហាទាំងនោះ សូម្បីតែនៅពេលដែលយើងមិនមានភ័ស្ដុតាងណាមួយនៅចំពោះមុខអង្គជំនុំជម្រះដែលសាក្សីនឹងផ្ដល់នោះ ហើយយើងមិនអាចសួរដេញដោលសាក្សីទាំងនោះឡើយ ។ មានទំព័រតិចតួចសម្រាប់យើងក្នុងការបញ្ចប់នូវការនិយាយលើកហេតុផល យើងនឹងមិនអាចធ្វើដូច្នេះបានទេ ។

ចៅក្រម ខេតរាយ ច្រានចោលការជំទាស់ថា ៖

> អង្គជំនុំជម្រះទទួលស្គាល់ថា ឯកសារជាច្រើនដែលភាគីចង់សង្កត់ធ្ងន់អំឡុងពេលសវនាការនេះស្ដីពីឯកសារសំខាន់ៗ ប្រហែលជាផ្ទុកព័ត៌មានដែលទំនងជាគូសបញ្ជាក់អំពីអត្ថិភាព និងការបង្កើតគោលនយោបាយដែលភាគីមានសិទ្ធិធ្វើការអត្ថាធិប្បាយលើទិដ្ឋភាពណាមួយនៃឯកសារដែលត្រូវបានហៅថា ជាតម្លៃភ័ស្ដុតាងរបស់ឯកសារក្នុងសវនាការនេះ ហើយអង្គជំនុំជម្រះនឹងធ្វើការសម្រេចចិត្តក្នុងអំឡុងពេលចេញសាលក្រម ។ ទោះបីជាយ៉ាងណាក៏ដោយ វាជាការចាំបាច់ដើម្បីសង្កត់ធ្ងន់ថា សំណុំរឿង០០២/០១មានតែគោលនយោបាយតែ

*ប៉ុណ្ណោះត្រឹមតែអត្ថិភាព និងការបង្កើតឡើងគោលនយោបាយនោះ ហើយការអនុវត្តគោលនយោបាយក្រៅពីការជម្លៀសប្រជាជនពីទីក្រុង មិនទាក់ទងទៅនឹងសំណុំរឿងនោះឡើយ ។*

មេធាវីការពារក្តី នួន ជា បាននិយាយលើកហេតុផលថា តាមរយៈការអនុញ្ញាតឲ្យមានការបង្ហាញកំណត់ហេតុចម្លើយសាក្សីដែលបរិយាយអំពីការអនុវត្តគោលនយោបាយដែលនៅក្រៅវិសាលភាពនៃសំណុំរឿង០០២/០១ (ហើយជាក់ស្តែងណាស់ដែលត្រូវបានអនុញ្ញាត) អង្គជំនុំជម្រះបានយល់ព្រមលើការបង្ហាញនោះរួចរាល់ហើយ ។ ជាងនេះទៅទៀត មេធាវីការពារក្តីយល់ស្របជាមួយ ព្រះរាជអាជ្ញាថា មានទំនាក់ទំនងរវាងអត្ថិភាពនៃគោលនយោបាយ និងការអនុវត្តគោលនយោបាយនោះ ហើយមេធាវីការពារក្តី នួន ជា លើកហេតុផលថា សម្រាប់ហេតុផលនេះ ការប៉ុនប៉ងរបស់អង្គជំនុំជម្រះក្នុងការញែកការពិភាក្សាអំពីអត្ថិភាពនៃគោលនយោបាយឧក្រិដ្ឋកម្មប្រាំយ៉ាង ចេញពីការពិភាក្សាអំពីការអនុវត្តគោលនយោបាយទទួលបរាជ័យក្នុងការអនុវត្តដោយធ្វើឲ្យទម្រង់នៃការបំបែកកិច្ចដំណើរនីតិវិធីនាពេលបច្ចុប្បន្នលែងដំណើរការ ៖

ប្រសិនបើ "អង្គហេតុថ្នាក់មូលដ្ឋាន" នៅថ្នាក់ក្រោមនៃឋានានុក្រមគឺជាផ្នែក១ នៃការបង្ហាញភស្តុតាងពាក់ព័ន្ធនឹងគោលនយោបាយ ដែលស្ថិតនៅក្រៅវិសាលភាពនៃសំណុំរឿង០០២/០១នោះ អង្គជំនុំជម្រះកំពុងត្រូវបានជំរុញឲ្យសន្និដ្ឋានដោយផ្អែកលើប្រតិចារិកដែលពុំពេញលេញ ឬគ្មានសារសំខាន់អ្វីដែលត្រូវផ្តើមបំបែកកិច្ចដំណើរការនីតិវិធីឡើយ ។ ទាំងសហព្រះរាជអាជ្ញា ទាំងអង្គជំនុំជម្រះសាលាដំបូងពុំធ្លាប់ទទួលបានជោគជ័យ នៅក្នុងការពន្យល់ថាតើ "អង្គហេតុនៅមូលដ្ឋានណាខ្លះ" ដែលពាក់ព័ន្ធនឹង "អត្ថិភាព" នៃគោលនយោបាយសហឧក្រិដ្ឋកម្មរួម ហើយដូច្នេះស្ថិតនៅក្នុងវិសាលភាពនៃសំណុំរឿង០០២/០១ ហើយអង្គហេតុណាខ្លះមិនពាក់ព័ន្ធ និងដោយសារហេតុផលអ្វី ។

មេធាវីការពារក្តី នួន ជា លើកឡើងថា អង្គជំនុំជម្រះសាលាដំបូងបានសម្រេចចិត្តកម្រិតភស្តុតាងស្តីពីគោលនយោបាយសហករណ៍ដើម្បីចង្អុលបង្ហាញភស្តុតាងស្តីពីការសម្រេចចិត្ត និងការដឹកនាំរបស់បក្សកុម្មុយនីស្តកម្ពុជា ឬអង្គជំនុំជម្រះសាលាដំបូងបានសម្រេចចិត្តថា ភស្តុតាងនៃគោលនយោបាយសហករណ៍ដែលស្ថិតនៅក្រៅវិសាលភាពនៃសំណុំរឿង០០២/០១ មិនត្រូវបានអនុញ្ញាតឲ្យបង្ហាញទាំងស្រុងឡើយ ។ ទោះបីជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះសាលាដំបូងមិនអាចសម្រេចមិនកោះហៅសាក្សីឡើយ ហើយក៏មិនអាចហាមឃាត់ភាគី មិនឲ្យពិនិត្យដេញដោលសាក្សីដែលត្រូវបានកោះហៅមកផ្តល់សក្ខីកម្មពាក់ព័ន្ធនឹងអង្គហេតុនៅមូលដ្ឋាននេះដែរ រួចហើយផ្អែកលើភស្តុតាងដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះដោយគ្មានគោលបំណងច្បាស់លាស់ ឬដោយប្រថុយប្រថានដើម្បីធ្វើសេចក្តីសន្និដ្ឋានទាំងមូល អំពីគោលនយោបាយដែលបានបង្កើតឡើងដោយបក្សកុម្មុយនីស្តឡើយ ដោយមិនរំលោភសិទ្ធិជនជាប់ចោទក្នុងការពិនិត្យដេញដោលភស្តុតាងដែលប្រឆាំងខ្លួន ។

មេធាវីការពារក្តី នួន ជា កំពុងស្នើសុំអង្គជំនុំជម្រះតុលាការកំពូលពិចារណាសារណារបស់ខ្លួនថាជាភស្តុតាងថ្មីនៃភាពអយុត្តិធម៌នៃការបំបែកកិច្ចដំណើរនីតិវិធី ។ ទោះបីជាយ៉ាងណាក៏ដោយ ការជំទាស់របស់ខ្លួនគឺជាទស្សនៈថ្មីស្តីពីការចោទប្រកាន់ដែលមានយូរណាស់មកហើយ ដែលជាចន្លោះប្រហោងនៃភាពត្រឹមត្រូវក្នុងការអនុញ្ញាតឲ្យមានការបង្ហាញភស្តុតាងជាច្រើន និងជាពិសេស ចម្លើយសាក្សី ដែលមិនមែនជាកម្មវត្ថុនៃការនិយាយលើកហេតុផលជំទាស់ ។ ការសម្រេចចិត្តរបស់អង្គជំនុំជម្រះ តុលាការកំពូលស្តីពីបណ្តឹងសារទុក្ខបំបែកកិច្ចដំណើរនីតិវិធីលើកទីពីរត្រូវបានរំពឹងទុកនៅខែក្រោយ ។ **អាន ហាញឌុល**



# ប្រវត្តិសាស្ត្រខ្មែរក្រហមក្រោមសម្ពាធនយោបាយ

ការបោះឆ្នោតជាតិឆ្នាំ២០១៣ បានដាក់ប្រវត្តិសាស្ត្រខ្មែរក្រហមឲ្យស្ថិតក្រោមសម្ពាធនយោបាយ ដោយសារការប្រែក្លាយប្រវត្តិសាស្ត្រឲ្យទៅជាប្រធានបទនយោបាយការបដិសេធមិនទទួលស្គាល់អំពើប្រល័យពូជសាសន៍ និងការញុះញង់ប្រកាន់ពូជសាសន៍ ។ ការភ្ជាប់ទំនាក់ទំនងនៃការបរិយាយអំពីប្រវត្តិសាស្ត្រប្រទេសកម្ពុជាសម័យទំនើបទៅនឹងនយោបាយ អាចនាំទៅរកការបែកបាក់សង្គម ការបែងចែកនិន្នាការនយោបាយ និងអំពើហិង្សា ។ គណបក្សប្រជាជនកម្ពុជាដែលគ្រប់គ្រងអំណាច និងគណបក្សសង្គ្រោះជាតិដែលជាគណបក្សប្រឆាំងបានប្រើប្រាស់រឿងរ៉ាវប្រវត្តិសាស្ត្រទាក់ទងនឹងរបបខ្មែរក្រហម ជាយុទ្ធសាស្ត្រមួយដើម្បីទទួលបានសំឡេងឆ្នោតពីប្រជាជន ក្នុងអំឡុងពេលយុទ្ធនាការឃោសនារកសំឡេងបោះឆ្នោត ។

ការគូសបញ្ជាក់អំពីឧក្រិដ្ឋកម្មក្នុងរបបខ្មែរក្រហម និងចំណាត់ថ្នាក់អ្នកដឹកនាំរបស់គណបក្សប្រជាជនកម្ពុជាថាជាអ្នករំដោះប្រទេសជាតិពីអំពើប្រល័យពូជសាសន៍ គឺជាយុទ្ធសាស្ត្រគន្លឹះសម្រាប់គណបក្សប្រជាជនកម្ពុជា ដើម្បីទទួលបានសំឡេងឆ្នោតពីប្រជាជន ។ គណបក្សប្រជាជនកម្ពុជា បានទទួលជោគជ័យចំពោះកិច្ចខិតខំប្រឹងប្រែងនេះ ដោយសារក្រុមគ្រួសារខ្មែរនីមួយៗមានសមាជិកយ៉ាងហោចណាស់ម្នាក់ ដែលបានស្លាប់ឬបានបាត់ខ្លួនក្នុងអំឡុងពេលនៃរបបខ្មែរក្រហម ។ មជ្ឈមណ្ឌលឯកសារកម្ពុជាបានប៉ាន់ប្រមាណថា មានប្រជាជនចន្លោះពី១លាន៧សែនទៅ២លាន២សែននាក់ ដែលបានស្លាប់នៅក្នុងរបបខ្មែរក្រហម ។



អតីតគុកទួលស្លែង ឬមន្ទីរសន្តិសុខស-២១

បទពិសោធន៍ប្រកបដោយទុក្ខវេទនារបស់ប្រជាជនកម្ពុជា នៅក្នុងរបបខ្មែរក្រហមមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយនឹងការអះអាងរបស់គណបក្សប្រជាជនកម្ពុជា ដែលថាថ្ងៃ៧មករា គឺជាថ្ងៃរំដោះ ដែលការលើកឡើងនេះ គឺជាជីពចរនយោបាយដ៏សំខាន់របស់គណបក្សប្រជាជនកម្ពុជា ចាប់តាំងពីឆ្នាំ១៩៧៩មកម្ល៉េះ ។ ជាមួយនឹងការលើកឡើងបែបនេះ គណបក្សប្រជាជនកម្ពុជា បានកើនចំនួនអាសនៈរបស់ខ្លួនយ៉ាងច្រើនសន្ធឹកសន្ធាប់ តាំងពីចំនួន៥១អាសនៈ ក្នុងឆ្នាំ១៩៩៣ ដល់ទៅ៩០អាសនៈក្នុងឆ្នាំ២០០៨ ។ ចាប់តាំងពីពេលនោះមក គណបក្សប្រជាជនកម្ពុជាស្ទើរតែអាចប្រមូលផ្តុំអំណាចទាំងស្រុង ។ គណបក្សរាជានិយមហ្វ៊ុនស៊ិនប៉ិចដែលទទួលបានជ័យជម្នះលើការបោះឆ្នោតលើកដំបូងក្នុងឆ្នាំ១៩៩៣ ដែលរៀបចំឡើងដោយអង្គការសហប្រជាជាតិ បានបាត់បង់អំណាច និងឥទ្ធិពលជាបន្តបន្ទាប់ពីឆាកនយោបាយ ហើយក្លាយទៅជាគណបក្សដែលរណបគណបក្សប្រជាជនកម្ពុជា ។

គណបក្សប្រឆាំង សម រង្ស៊ី បានក្លាយទៅជាគូប្រជែងដ៏ចម្បងតែមួយគត់របស់គណបក្ស ប្រជាជនកម្ពុជាក្នុងឆ្នាំ២០០៨ ។ ទោះជាយ៉ាងនេះក្តី គណបក្សប្រឆាំងនេះមិនអាចនាំមកនូវការផ្លាស់ប្តូរសំខាន់ណាមួយបានទេនៅពេលនោះ ។ ទោះជាយ៉ាងនេះក្តី ជាមួយនឹងការធ្លាក់ចុះយ៉ាងខ្លាំងនូវចំនួនអាសនៈក្នុងរដ្ឋសភារបស់គណបក្សប្រជាជនកម្ពុជា មកត្រឹម៦៨សំឡេង បើយោងតាមលទ្ធផលបណ្តោះអាសន្នមិនផ្លូវការលើកទីមួយរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលបានប្រកាសកាលពីថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៣ ការលើកឡើងអំពីខ្មែរក្រហម ទំនងជានឹងមិនមានប្រសិទ្ធភាពទៀតទេ នៅក្នុងបរិបទនាពេលបច្ចុប្បន្ននេះ ។ អ្នកបោះឆ្នោតវ័យក្មេងជាច្រើន ដែលមិនមានបទពិសោធន៍ផ្ទាល់ខ្លួននៅក្នុងរបបខ្មែរក្រហម ហាក់ដូចជាចង់បានតែការផ្លាស់ប្តូរការដឹកនាំ ហើយបានងាកមកគាំទ្រគណបក្សប្រឆាំង ។

ស្របពេលជាមួយគ្នានេះ ការបដិសេធមិនទទួលស្គាល់អំពើប្រល័យពូជសាសន៍ ដែលមិនធ្លាប់មានពីមុនមក បានលេចឡើងនៅក្នុងអំឡុងពេលនៃការបោះឆ្នោតឆ្នាំ២០១៣ ។ នៅថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៣នេះ លោក កឹម សុខា ដែលជាមេដឹកមួយរូបរបស់គណបក្សប្រឆាំងប្រកបដោយវោហារសាស្រ្ត បានធ្វើបទអត្ថាធិប្បាយនៅក្នុងពិធីជួបជុំជាសាធារណៈថា គុកទួលស្លែងគឺជាឆាក ដែលត្រូវបានប្រឌិតឡើងដោយវៀតណាម ដើម្បីបង្ហាញពីភាពត្រឹមត្រូវចំពោះការឈ្លានពានរបស់វៀតណាមមកលើប្រទេសកម្ពុជា ។ ជាងនេះទៅទៀត លោក កឹម សុខា បានពន្យល់ថា ខ្មែរក្រហម នឹងមិនឆោតល្ងង់រហូតដល់រក្សាទុកគុកទួលស្លែងឲ្យពិភពលោកចោទប្រកាន់ទោសនោះទេ ។ ខ្មែរក្រហមនឹងកម្ទេចទីនោះចោលដើម្បីបំផ្លាញភ័ស្តុតាង ។ អត្ថាធិប្បាយរបស់លោក កឹម សុខា មានលក្ខណៈច្បាស់លាស់ ទោះបីជាក្រោយមក លោកបានបដិសេធ ហើយបានចោទប្រកាន់រដ្ឋាភិបាលថាបានកាត់តសុន្ទរកថារបស់លោកក៏ដោយ ។ អត្ថាធិប្បាយនយោបាយរបស់លោក កឹម សុខា បានបង្កឲ្យមានការខឹងសម្បារពីសំណាក់ជនរងគ្រោះក្នុងរបបខ្មែរក្រហម ដូចជាលោក ជុំ ម៉ី ដែលបានចោទប្រកាន់លោក កឹម សុខា ថាបានប្រមាថមើលងាយព្រលឹងរបស់អ្នកស្លាប់ បង្កឲ្យមានការប៉ះទង្គិចផ្លូវចិត្តជនរងគ្រោះឡើងវិញ និងបំភ្លៃប្រវត្តិសាស្រ្ត ។ លោក ជុំ មី បានទទួលបរាជ័យអំពីការស្នើសុំឲ្យមានការសុំទោសពី លោក កឹម សុខា ហើយក្រោយមកបានដឹកនាំធ្វើបាតុកម្មក្នុងហេតុផលនយោបាយ ដែលមានការចូលរួមពីមនុស្សជាងពីរម៉ឺននាក់ ។

ដូចគ្នានេះដែរ មេដឹកនាំគណបក្សប្រឆាំង លោក សម រង្ស៊ី បានវាយប្រហារគណបក្សប្រជាជនកម្ពុជា តាមរយៈការភ្ជាប់គណបក្សប្រជាជនកម្ពុជា ទៅនឹងបញ្ហាជាច្រើនដែលទាក់ទងទៅនឹងប្រទេសវៀតណាម និងខ្មែរក្រហម ។ យុទ្ធសាស្រ្តរបស់លោក សម រង្ស៊ី គឺទាញចំណាប់អារម្មណ៍ប្រជាជនកម្ពុជាទៅលើបញ្ហានៃការហូរចូលរបស់ជនអន្តោប្រវេសន៍វៀតណាម ដែលគ្មានការគ្រប់គ្រងឲ្យមានប្រសិទ្ធភាពដែលលោកបានអះអាងថា លំហូរនេះនៅតែមានសកម្មភាពនៅឡើយនាពេលបច្ចុប្បន្ន ។ ការចោទប្រកាន់នេះបានបង្កើតឲ្យមានភាពមន្ទិលសង្ស័យជាយូរមកហើយ ក្នុងចំណោមប្រជាជនកម្ពុជាចំពោះឥទ្ធិពលរបស់វៀតណាមមកលើកិច្ចការផ្ទៃក្នុង និងនយោបាយរបស់កម្ពុជា ការបោះបង្គោលតម្រុយព្រំដែនប្រកបដោយជម្លោះ និងភាពមិនប្រក្រតីក្នុងការបោះឆ្នោតនាពេលថ្មីៗ ដែលមានការអះអាងអំពីអ្នកបោះឆ្នោតជនជាតិវៀតណាមខុសច្បាប់ ។ លោកក៏បានអះអាងប្រឆាំងតបចំពោះថ្ងៃទី៧ ខែមករា ថាជាថ្ងៃឈ្លានពានរបស់វៀតណាម ។

សុន្ទរកថារបស់ លោក សម រង្ស៊ី អាចនាំឲ្យមានអារម្មណ៍ស្អប់ខ្ពើមជនជាតិវៀតណាម នៅតាមបណ្តាញទំនាក់ទំនងសង្គមដូចជាហ្វេសប៊ុក ដែលមានឥទ្ធិពលដល់អ្នកបោះឆ្នោតវ័យក្មេង ។ ពាក្យសម្តីរបស់លោក អាចនាំឲ្យមានការញុះញង់ និងការបែងចែក ដែលអាចនាំឲ្យកើតមានអំពើហិង្សាទោះបីជាលោកមិនមានចេតនាបង្កឲ្យមានអំពើហឹង្សាក៏ដោយ ។

ប្រទេសកម្ពុជា បានឆ្លងកាត់នូវអន្តរកាលនយោបាយចម្រុងៗជាច្រើន តាំងពីសម័យអាណានិគមបារាំងដែលកម្ពុជាស្ថិតនៅក្រោមការត្រួតត្រារបស់បរទេស សម័យឯករាជ្យ របបរាជានិយម របបសាធារណរដ្ឋខ្មែរ ដែលកម្ពុជាបានជួបប្រទះនូវសង្គ្រាមស៊ីវិលនិងការទម្លាក់គ្រាប់បែក របបកម្ពុជាប្រជាធិបតេយ្យដែលកម្ពុជាជួបប្រទះនូវអំពើប្រល័យពូជសាសន៍ របបសាធារណរដ្ឋប្រជាមានិតកម្ពុជាដែលមានទំនោរទៅរកសង្គមនិយមបែបសូវៀតសម័យកាលអន្តរកាលរបស់អ៊ុនតាក់ និងចុងក្រោយ របបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ ។ រចនាសម្ព័ន្ធនៃរបបនយោបាយទាំងនេះ មានការបែងចែកឋានៈសង្គម ការប្រមូលផ្តុំអំណាចនៅក្នុងរដ្ឋាភិបាលមជ្ឈិម និងការពឹងផ្អែកភាគច្រើនទៅលើប្រជាប្រិយភាពរបស់បុគ្គលដែលជាមេដឹកនាំ ។ របបនយោបាយទាំងនេះមិនមានប្រព័ន្ធប្រជាធិបតេយ្យរឹងមាំមួយនោះទេ ដែលយើងត្រូវពង្រឹងឲ្យបានកាន់តែរឹងមាំ ។ ដោយបានឆ្លងកាត់សម័យអន្តរកាលធំៗនិងការលំបាកទាំងនេះ ប្រជាជនកម្ពុជាគឺជាជនជាតិមួយប្រកបដោយសក្តានុពល និងប្រកបដោយភាពរឹងមាំ ក្នុងការងើបឡើងកសាងសេចក្តីសុខ និងប្រទេសជាតិរបស់ខ្លួន ។

ដើម្បីឲ្យកម្ពុជាទទួលបាននូវប្រជាធិបតេយ្យ នីតិរដ្ឋ និងការគោរពសិទ្ធិមនុស្សរឹងមាំ អ្នកនយោបាយគួរតែបញ្ឈប់ការធ្វើនយោបាយលើប្រវត្តិសាស្ត្រ ។ ផ្ទុយទៅវិញ យើងគួរតែអប់រំប្រវត្តិសាស្ត្រដល់យុវជនវ័យក្មេង ដែលមានចំនួនប្រមាណបីលានប្រាំសែននាក់ ដែលកើតក្រោយរបបខ្មែរក្រហម ។ ប្រសិនបើគ្មានការសិក្សា និងការស្រាវជ្រាវបែបវិទ្យាសាស្ត្រ យុវជនវ័យក្មេងនឹងបាត់បង់ឱកាស ក្នុងការស្វែងយល់អំពីប្រវត្តិសាស្ត្ររបស់ខ្លួន ។ យើងត្រូវធានាឲ្យបានថា យុវជនជំនាន់ក្រោយមានឱកាសសិក្សាវិភាគ និងវាយតម្លៃប្រវត្តិសាស្ត្ររបស់ខ្លួន ក្នុងរបៀបមួយដែលនឹងបង្កើតនូវវប្បធម៌ ដែលឲ្យតម្លៃសិទ្ធិមនុស្ស លទ្ធិប្រជាធិបតេយ្យ និងនីតិរដ្ឋ ។ ការយល់ដឹងពីប្រវត្តិសាស្ត្រ ការអត់ឱន និងការអធ្យាស្រ័យ គឺជាសីលធម៌គន្លឹះ ដែលមានសារសំខាន់ចំពោះការរីកលូតលាស់ប្រជាធិបតេយ្យរបស់ប្រទេសក្រោយជម្លោះ ។ យុវជនគួរតែត្រូវបានលើកទឹកចិត្តឲ្យសួរដេញដោល និងថែមទាំងមានសេចក្តីក្លាហានហ៊ានប្រឆាំងទៅនឹងអំណាចទាំងឡាយណាដែលដឹកនាំប្រទេសកម្ពុជានៅក្នុងទិសដៅខុស ។ ធ្វើដូច្នេះ យុវជនជំនាន់ក្រោយនឹងអាចក្លាយទៅជាមេដឹកនាំដែលមានសមត្ថភាព និងជាភ្នាក់ងារសកម្ម ក្នុងដំណើរការស្វែងរកសន្តិភាព និងការផ្សះផ្សាជាតិ ។

ការរំដោះប្រវត្តិសាស្ត្រខ្មែរក្រហមចេញពីសម្ពាធនយោបាយ តាមរយៈការអប់រំ គឺជាជំហានដ៏សំខាន់ក្នុងកិច្ចខិតខំប្រឹងប្រែងនេះ ។ ប្រវត្តិសាស្ត្រខ្មែរក្រហម គឺជាប្រវត្តិសាស្ត្ររបស់យើងទាំងអស់គ្នាដែលមិនអាចប្រកែកបាន ។ ប្រវត្តិសាស្ត្រនេះក៏ដូចជាអំពើប្រល័យពូជសាសន៍ដែរ គឺជាកម្មសិទ្ធិរបស់ប្រជាជនកម្ពុជាទាំងមូល ។

**ឌី ខាំបូលី**

# រឿងរ៉ាវពិតដើម្បីប្រវត្តិសាស្ត្រ

មជ្ឈមណ្ឌលឯកសារកម្ពុជាសង្ឃឹមថា ប្រជាជនកម្ពុជាគ្រប់រូបដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហមបាន និងកំពុងសរសេរអត្ថបទឬសៀវភៅអំពីរឿងរ៉ាវពិតផ្ទាល់ខ្លួន ហើយនឹងផ្ញើមកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមអាសយដ្ឋានខាងក្រោម ÷

ផ្ទះលេខ៦៦ មហាវិថីព្រះសីហនុ ភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទលេខៈ (៨៥៥) (២៣) ២១១ ៨៧៥
ទូរស័ព្ទលេខៈ (៨៥៥) (១៦) ៨៧៦ ៦៩២
ទូរសារលេខៈ (៨៥៥) (២៣) ២១០ ៣៥៨
*Email: truthsocheat@dccam.org*
*Home page: www.dccam.org*

# ការិយាល័យព័ត៌មានសាធារណៈ

*«ការិយាល័យព័ត៌មានសាធារណៈ» របស់មជ្ឈមណ្ឌលឯកសារកម្ពុជា បានបើកបម្រើជូននិស្សិត អ្នកស្រាវជ្រាវ បុគ្គលិករាជការ និងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍ចង់យល់ដឹងអំពីប្រវត្តិសាស្ត្ររបបកម្ពុជាប្រជាធិបតេយ្យ និងព្រឹត្តិការណ៍វិវឌ្ឍន៍របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាឬសាលាក្តីខ្មែរក្រហម ។*

*មជ្ឈមណ្ឌលឯកសារកម្ពុជាជាកន្លែងប្រមូលផ្តុំ និងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត ។ ឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាមានប្រាំប្រភេទ ។ ប្រភេទឯកសារទីមួយគឺជាឯកសារជាក្រដាសសន្លឹកដែលមានចំនួនជិតមួយលានទំព័រ ។ ប្រភេទឯកសារទីពីរគឺជាបទសម្ភាសន៍ដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាចុះទៅធ្វើសម្ភាសន៍ជាមួយជនរងគ្រោះនិងអតីតកម្មាភិបាលខ្មែរក្រហម ។ ប្រភេទឯកសារទីបីគឺជារូបថតទាក់ទងទៅនឹងសម័យខ្មែរក្រហម ។ ប្រភេទឯកសារទីបួនគឺជាឯកសារទាក់ទងទៅនឹងការធ្វើផែនទីរណ្តៅសាកសព និងទីតាំងសម្លាប់របស់ខ្មែរក្រហម និងឯកសារប្រភេទទីប្រាំគឺជាខ្សែភាពយន្តឯកសារដែលបានផលិតឡើងក្នុងរបបខ្មែរក្រហមនិងសម័យក្រោយមកទៀត ។*

*តាមរយៈការិយាល័យព័ត៌មានសាធារណៈ សាធារណជនអាចអាននិងស្រាវជ្រាវឯកសារទាំងនេះបាន ។ ឯកសារខ្លះទៀតរួមមាន ៖ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាព កំណត់ហេតុរបស់បក្ស ទូរលេខឆ្លើយឆ្លង ព័ត៌មានដែលបានមកពីការសម្ភាសន៍ជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្ថនិទ្ទេសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍ ។*

*ការិយាល័យព័ត៌មានសាធារណៈមានទីតាំងនៅអគារលេខ៦៦ មហាវិថីព្រះសីហនុ ខាងកើតវិមានឯករាជ្យ ។ ការិយាល័យរបស់យើងបើកជូនសាធារណជនពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង៨ដល់ម៉ោង១២ និងពេលរសៀលពីម៉ោង២ដល់ម៉ោង៥ ។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង ជា ផល្លា តាមរយៈ ទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ។*




















# ទណ្ឌិតផ្លែល្ពៅ



រូបគំនូរដោយអ្នកនិពន្ធ ឆាយ ស៊ូឆាត្រ

**(តពីលេខមុន)**

### ២០) ទៅរៀនសូត្រ

ព្រឹកនេះខ្ញុំមិនបានទៅធ្វើការទេ ដោយសារកាលពីម្សិលមិញ ខ្ញុំបានកាប់គល់ឈើ ហើយចបបានផ្ទាតត្រូវស្មងជើងរបួស ហើយឥឡូវនេះជើងរបស់ខ្ញុំហើម ហើយឈឺយ៉ាងខ្លាំង ។ ខ្ញុំផ្ដាំមិត្តភក្តិ ឲ្យសុំច្បាប់មេក្រុម ហើយស្វែងរកឫសឈើមកបុកដើម្បីបិតរបួសនិងរកថ្នាំផឹកផង ។ ពេលនោះ ក៏ឮសំឡេងរបស់កម្មាភិបាលម្នាក់ស្រែកហៅចំឈ្មោះបងប្រុសខ្ញុំ ។

មិត្ត ថាន់ ប្រញាប់បន្តិចឡើង អ្នកឯទៀតកំពុងរង់ចាំ ។ បងប្រុសខ្ញុំស្ទុះភ្លែតយកបង្វេចមួយរួចលាប្រពន្ធដោយទឹកមុខស្ងួតស្ងប់ ។ នៅពីមុខផ្ទះ មិត្ត គក មកឈប់ដោយមាននីរសារពីរនាក់ បានរង់ចាំជាស្រេច ។ នៅតាមផ្លូវមុខ មានអតីតអ្នករដ្ឋការ លន់ នល់ ប្រហែលជាដប់នាក់កំពុងត្រៀមចេញដំណើរទៅរៀនសូត្រដែរ ។ មិត្ត គក និយាយទៅកាន់បងប្រុសខ្ញុំឲ្យប្រញាប់ឡើង មិនបាច់យកអ្វីតាមទេ ព្រោះមិត្តឯងទៅតែមួយអាទិត្យប៉ុណ្ណោះ ។ ទីបំផុត បងខ្ញុំបានធ្វើដំណើរទៅបាត់ជារៀងរហូត ។ ខ្មែរក្រហមបានប្រើពាក្យ

រៀនសូត្រនេះនៅគ្រប់ទីកន្លែងនិងគ្រប់វេលា ។ ខ្ញុំបានតាមសម្លឹងមើលដំណើរទៅរៀនសូត្ររបស់បងប្រុសខ្ញុំដោយពុំបានដឹងថាជាដំណើរទៅរកសេចក្តីស្លាប់ឡើយ ។ យើងបានរង់ចាំគាត់មួយអាទិត្យ ពីរអាទិត្យ មួយឆ្នាំ ។ គាត់និងអ្នកដទៃទៀតបានធ្វើដំណើរទៅកាន់ពិភពមួយទៀតដែលពុំបានស្គាល់គឺជាការបាត់ខ្លួនជារៀងរហូត ។

## ២១) ជីរំដុសខាត់ខួរក្បាល

បងប្រុស ប៊ុនថាន់ បានចាកទៅហើយ ។ វេលាម៉ោងប្រាំបួន មិត្ត ឡាន មកដល់ដើម្បីបញ្ជូនបងស្រីខ្ញុំ ប៊ុនណាយ និងបងថ្លៃស្រីពីរនាក់ទៀតគឺ ស៊ីថា និង ផានឿ ទៅកាន់កសិដ្ឋានបដិវត្តន៍ ។ ទាំងបីនាក់គឺជាប្រពន្ធអតីតទាហាន លន់ នល់ ដែលត្រូវចាត់ទុកជាអនុប្រជាជន ។ ខ្មែរក្រហមក៏បានហៅកូនៗដែលនៅជីរំកុមារបដិវត្តន៍ឈានមុខជាមួយ ដែរ ។ ប៊ុនណាយ មានកូនម្នាក់និងមានផ្ទៃពោះប្រាំពីរខែផង ។

សមាជិកគ្រួសារខ្ញុំបានចេញជាបន្តបន្ទាប់ ដូច្នេះនៅផ្ទះនេះមានសល់តែឪពុកម្តាយខ្ញុំ និង ស៊ីណេ បងថ្លៃស្រី និងកូនតូច លីនដា ព្រមទាំងរូបខ្ញុំ ។ អ្នកទាំងបីពុំបានដឹងថាដំណើររបស់ខ្លួន គឺទៅជីរំដុសខាត់ខួរក្បាលទៅអូរស្ពាន ឃុំត្រាវពន្លក ទាល់តែសោះ ។ រឿងនេះខ្ញុំបានដឹងពេលបួនឆ្នាំក្រោយមក ។ ដោយមានការរន្ធត់ចិត្តចំពោះការព្រាត់ប្រាស់ដ៏ខ្លោចផ្សាបែបនេះ ជំងឺរបស់ម្តាយខ្ញុំក៏កាន់តែធ្ងន់ធ្ងរឡើង ។ ឪពុកខ្ញុំបានចាកចេញពីផ្ទះដើម្បីកាស់គល់ឈើ និងកាប់សំបកឈើយកមកស្ងោរឲ្យម្តាយខ្ញុំ ។ ចំណែកខ្ញុំចាប់ផ្តើមធ្វើចលនាបេះដូងខណៈដែលសំឡេងស្ត្រីម្នាក់ស្រែកគំហកខ្លាំងៗនៅមុខផ្ទះ ។

មិត្ត ណេ ហេតុអ្វីក៏មិនធ្វើការ? មិត្តឯងដឹងទេថា បើមិនធ្វើការត្រូវអត់បាយហូបណា៎ បាយមានសម្រាប់តែអ្នកដែលទៅធ្វើការតែប៉ុណ្ណោះ ។ ខ្ញុំលបមើលម្ចាស់សំឡេងនោះគឺមិត្ត វ៉ែន មេកងរយរបស់ ស៊ី ណេ ។ ស៊ីណេ លានៅលើផ្ទះ រួចព លីនដា ដើរតាមក្រោយមិត្ត វ៉ែន ទៅបាត់ ។ ធម្មតាខ្ញុំជាយុវជនម្នាក់រឹងមាំ មានស្មារតីអង់អាចក្លាហាន ជាអតីតនិស្សិតសកលវិទ្យាល័យ ពេលនេះ ខ្ញុំចង់ស្រែកទ្រហោយំ ក៏ប៉ុន្តែទឹកភ្នែកពុំស្រក់ចុះមកសោះ ព្រោះវាហួតហែងដោយសារកម្តៅទុក្ខវេទនាហួសប្រមាណ ។ ម្តាយខ្ញុំសម្លឹងមុខខ្ញុំ ក៏ធ្វើដៃជាសញ្ញាជាចុងក្រោយមក ។ គាត់ដង្ហក់តិចៗ រួចក៏ផុតដង្ហើមលាចាកនរកមនុស្សរស់នៅ ដោយបន្សល់ទុកតែរូបខ្ញុំម្នាក់ឯង ដែលយំពុំចេញទឹកភ្នែក ។ រំពេចនោះ ឪពុកខ្ញុំបានមកដល់ ។ គាត់បោះចោលឫសឈើ និងសំបកឈើទៅដី ហើយស្ទុះឡើងលើផ្ទះ ។ នៅពីក្រោយគាត់ មានបុរសចំណាស់ម្នាក់ដែលខ្ញុំបានស្គាល់រួចមកហើយ គឺ តាស្រី ជាមិត្តចាស់របស់ឪពុក កាលជំនាន់អាណាព្យាបាលបារាំង ។ ដោយសារសង្គ្រាម តំបន់នេះស្ថិតនៅក្រោមការគ្រប់គ្រងរបស់កងទ័ពសម្តេចឪ តាស្រី ត្រូវខ្មែរក្រហមចាត់ទុកថាជាប់និន្នាការសង្គមចាស់ ។ គាត់ពុំមានអ្នកណារាប់អាន ឬយកធ្វើជាមុខការអ្វីទេ សូម្បីតែកូនចៅគាត់ក៏ពុំត្រូវបានចាត់តាំងជាកងឈ្លប ឬកម្មាភិបាលអ្វីដែរ តែរូបគាត់ត្រូវអង្គការចាត់តាំងឲ្យធ្វើជាគ្រូព្យាបាលតាមបែបបុរាណ ។ តាស្រី បានប្រាប់ឪពុកខ្ញុំថា សុំកុំធ្វើជាស្គាល់គ្នាឲ្យសោះ ព្រោះអង្គការនឹងតាមដានយើងទាំងពីរនាក់ ។ តាស្រី បានពុះដើមឫស្សីជាប្រាំបីចំរៀក ហើយយកវល្លិ៍ថ្មីងមកវែងនិងធ្វើទ្រៀសសម្រាប់ដាក់សព ។ ទ្រៀសជាឧបករណ៍ម្យ៉ាងប្រើជំនួសក្តាមឈូសសម្រាប់ជនជាតិខ្មែរ និងកួយនៃភាគខាងលិចនៃប្រទេសកម្ពុជាគឺប្រើបន្ទះឫស្សីចំនួនប្រាំបីវែង ដូចជា ព្រួលសម្រាប់រុំសពទៅដុតឬកប់ កាលអំឡុងសង្គ្រាមប្រាំឆ្នាំ ខ្មែរក្រហមតែងតែប្រើទ្រៀសដើម្បីរុំសពយុទ្ធជនយកទៅដុតឬកប់ ។ ពេលនេះសពរបស់ម្តាយខ្ញុំត្រូវរុំ ដោយសំពត់ចាស់នឹងទ្រៀសឫស្សីយកទៅបូជានៅព្រៃក្រោយផ្ទះ ។ ក្បួនហែសពម្តាយខ្ញុំមានគ្នាបួននាក់ដោយមានតាស្រី ជាអាចារ្យដើរមុខកាន់ធូបបីសរសៃ ខ្ញុំ និងយុវជនអ្នកជិតខាងជាអ្នកសែងព្រមទាំងឪពុកខ្ញុំដើរតាមក្រោយ ។

## ២២) ខ្មាំង

ម្តាយខ្ញុំបានលាចាកលោកនេះទៅហើយ ឯឪពុកខ្ញុំក៏ធ្លាក់ខ្លួនឈឺទៀត ចំណែកខ្ញុំនៅឈឺជើងពុំអាចដើរបាន ។ ខ្ញុំត្រូវសម្រាកនៅផ្ទះ ដូច្នេះនៅរោងបាយរួម អង្គការត្រូវកាត់របបអាហារពាក់កណ្តាល ។ ស្រីៗចុងភៅដែលសុទ្ធតែជាអ្នកមូលដ្ឋានចាស់បានសើចចំអកដល់ខ្ញុំ ថាខ្ញុំជាអ្នកជិះជាន់កម្លាំងអ្នកដទៃ ជាមនុស្សខ្ជិល និងជាកម្អែលសង្គមចាស់ ។

ថ្ងៃបន្ទាប់មក ពេលដែលយើងកំពុងតែហូបបបរនៅរោងបាយរួម ស្រាប់តែមានឡានហ្ស៊ីបមួយបានបើកចូលមកឈប់នៅពីមុខសហករណ៍ ។ ខ្ញុំឃើញមនុស្សចំណាស់ម្នាក់ស្លៀកពាក់ពណ៌ខ្មៅពាក់មួកកន្តឹបចុះពីលើឡាន និងមានអង្គរក្សពីរនាក់ដើរតាម

ក្រោយ ។ គណៈសហករណ៍បានចេញទៅទទួលសមមិត្តនោះ ដោយសម្ដែងការគោរពយ៉ាងគោរពខ្លាច ។ ទោះបីជានៅឆ្ងាយបន្ដិចក្ដី ក៏ខ្ញុំអាចស្គាល់បានថា នោះគឺបងជីដូនមួយខ្ញុំឈ្មោះ មាស សំខាន់ ។ យើងបែកគ្នាជាងប្រាំឆ្នាំហើយគឺចាប់តាំងពីរដ្ឋប្រហារទម្លាក់សម្ដេច សីហនុ ថ្ងៃទី១៨ ខែមីនា ១៩៧០មកម្ល៉េះ ។ យើងរស់នៅជាមួយគ្នាដូចបងប្អូនបង្កើត គាត់ត្រូវបានទទួលការប្រោសប្រណីពីឪពុកម្ដាយខ្ញុំ ។ ពេលធំដឹងក្ដី បងសំខាន់ បានប្រឡងជាប់បរិញ្ញាបត្រ ហើយក្លាយជាសាស្ត្រាចារ្យ ប៉ុន្តែសង្គ្រាមបានធ្វើឲ្យយើងបែកគ្នា ។ បងសំខាន់ ផ្លាស់ទៅបង្រៀននៅខេត្តក្រចេះ ហេតុនេះហើយក្រោយរដ្ឋប្រហារ គាត់ក៏បានក្លាយជាជនបដិវត្តន៍ជឿឈានមុខ និងស្និតស្នាញបំផុត ។ បងសំខាន់ បានប្រយុទ្ធតស៊ូប្រឆាំងរបបលន់ នល់ ដោយចូលព្រៃម៉ាកគីដើម្បីតស៊ូជាមួយរណសិរ្សរំដោះជាតិកម្ពុជា ។ ខ្ញុំមិនដឹងថា បងសំខាន់ គាត់និយាយអ្វីខ្លះជាមួយ មិត្ត សឿន នោះទេ ក៏ប៉ុន្តែបន្តិចក្រោយមក មិត្ត សឿន បានដាកមកក្រោយហើយ និយាយសំដៅមកខ្ញុំ ហើយសួរទៅបងសំខាន់ថាគឺម្នាក់នេះមែនទេ មិត្តបង? ខ្ញុំភ្ញាក់ក្រញាង បងសំខាន់ បោះជំហានសំដៅខ្ញុំ ហើយសួរខ្ញុំថា ប្អូនពុកឯងនៅឯណា? ខ្ញុំឆ្លើយថា គាត់នៅឯក្រោលក្របី ឯតាំងព្រេចឯណោះបង!

ពេលនោះ បងសំខាន់ ក៏ដាកទៅនិយាយជាមួយ មិត្ត សឿន ម្ដងទៀត ។ ខ្ញុំស្ដាប់ពុំឮការសន្ទនានោះទេ ។ ប្រហែលមួយម៉ោងក្រោយមក ខ្ញុំឃើញនីរសារម្នាក់បានឌុបកង់ឪពុកខ្ញុំមកដល់ ។ បងសំខាន់ ចាប់ឪបពុកដ៏ចាស់ជរា ដោយសម្រក់ទឹកភ្នែក ។ ប្រាំឆ្នាំកន្លងទៅនេះ បងសំខាន់ បានឆ្លងកាត់សមរភូមិជាច្រើនជាពិសេសគឺសមរភូមិក្រោយខាងកើតរាជធានីភ្នំពេញ គាត់តស៊ូដើម្បីបុព្វហេតុជាតិ បុព្វហេតុវណ្ណៈ និងប្រជាជន ឥឡូវនេះបដិវត្តន៍បានយកជោគជ័យហើយ ក៏ប៉ុន្តែវាបន្តឲ្យមានវិនាសកម្មនិងការព្រាត់ប្រាស់ ។ គាត់បាននាំមកអង្ករមួយការ៉ុងតូច និងខោអាវមួយសំពាយប្រគល់ឲ្យឪពុកខ្ញុំ ហើយនិយាយមកខ្ញុំទាំងពីរថា ខ្ញុំធ្វើបដិវត្តន៍ដើម្បីជាតិ និងប្រជាជន ខ្ញុំនឹងត្រឡប់មកវិញដើម្បីជួយសង្គ្រោះពុក និងប្អូនមិនខាន ។

ពេលលាខ្ញុំទាំងពីរហើយ បងសំខាន់ ក៏ឡើងឡានហ្ស៊ីបចាកចេញទៅ ។ គាត់បានបន្សល់ទុកនូវក្ដីសង្ឃឹមដល់ខ្ញុំយ៉ាងខ្លាំងព្រោះពេលនេះខ្ញុំមានបងម្នាក់ដែលជាកម្មាភិបាលជាន់ខ្ពស់ជាទីពឹងប្រាកដ ដែលអាចរំដោះខ្ញុំ និងគ្រួសារឲ្យផុតពីនរកមនុស្សរស់នេះជាពុំខាន ។

ក្រោយពីបងជីដូនមួយខ្ញុំចាកចេញទៅបាត់ ជំងឺរបស់ពុកកាន់តែធ្ងន់ឡើង ។ គាត់ដេកនៅនឹងកន្ទេលពុំអាចទៅឃ្វាលគោក្របីបានដូចមុនទៀតឡើយ ហើយក៏មិនអាចហូបអ្វីបានដែរ ។ ពិតប្រាកដណាស់ តំបន់នេះជាតំបន់ភ្នំឱរ៉ាល់ដែលល្បីខាងជំងឺគ្រុនចាញ់ខ្លាំងបំផុត បន្ថែមលើការខ្វះចំណីអាហារ និងថ្នាំពេទ្យនោះ មានសង្ឃឹមតិចណាស់ចំពោះឪពុកជរារបស់ខ្ញុំ ។ ពេលនេះ គាត់កាន់តែខ្សោយទៅៗ ហើយទន្ទេញតែឈ្មោះបងជីដូនមួយ មាស សំខាន់ រង់ចាំការវិលមកម្ដងទៀត ក៏ប៉ុន្តែមកដល់ពេលនេះ៣៧ឆ្នាំហើយ ដែលខ្ញុំពុំបានទទួលបានដំណឹងពីគាត់ទាល់តែសោះ ។

ឪពុកខ្ញុំ បានទទួលមរណភាពក្នុងអាយុ៦៩ឆ្នាំគឺបីអាទិត្យ បន្ទាប់ពីបានមកដល់ភូមិកោះកណ្ដាល ឃុំជៀប ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង នាឆ្នាំ១៩៧៥ ។ សពរបស់គាត់ត្រូវបានបញ្ចុះក្រោមដើមចំបក់ដោយរុំនឹងទ្រៀសក្បែរផ្ទះរបស់ម្ដាយខ្ញុំ ។

ពីរថ្ងៃក្រោយមកជើងរបស់ខ្ញុំក៏ជាសះស្បើយអាចដើរបាន ។ ពេលនេះគ្រួសារខ្ញុំនៅសល់តែគ្នាបីនាក់ប៉ុណ្ណោះគឺ ស៊ីណេ និងកូនស្រីតូច លីនដា និងរូបខ្ញុំ ។ ចំណែក កូនពីរនាក់របស់ ស៊ីណេ គឺ ដូលី និង អាក្មួល កំពុងរស់នៅមណ្ឌលកុមារបដិវត្តន៍ឈានមុខ ។ ស៊ីណេ ទៅរស់នៅខ្ទមតែម្នាក់ឯង ហើយត្រូវទៅធ្វើការនៅវាលស្រែជាមួយនិងយុវជនដទៃទៀត ។ មេក្រុមរបស់យើងគឺមិត្ត ផល ដែលមានយុវជនប្រហែល២៥នាក់ ។ នៅក្នុងក្រុមនេះមានម្នាក់ជានិស្សិត សាស្ត្រាចារ្យឈ្មោះ ដុន ពីរនាក់ជានិស្សិតមហាវិទ្យាល័យគឺ ចំរើន និងរូបខ្ញុំ ប្អូននាក់ជាកូនកាត់ចិន គឺជាកូនពាណិជ្ជករមកពីភ្នំពេញ និងសល់ពីនោះគឺជាអ្នកស្រែធម្មតា ។

ក្រុមនេះគឺជាក្រុមដែលខ្ញុំបានធ្វើការជាមួយមុនពេលដែលខ្ញុំមុតផ្ដែចប និងការស្លាប់របស់ឪពុកម្ដាយខ្ញុំ ។ ពេលនេះខ្ញុំបានស្គាល់អ្នកទាំងអស់ជិតស្និទ្ធជាងមុន ។ មិត្ត ផល ដែលជាមេក្រុមថ្មីនេះ ជាមនុស្សស្រគត់ស្រគំ ស្ងាត់ស្ងៀម ទឹកមុខញញឹម តែមិនសូវចេះនិយាយដូច មិត្ត អ៊ន ទេ ។ គាត់មិនបង្ខំយើងឲ្យធ្វើការលឿនទេ តែគាត់ប្រាប់ថា ត្រូវធ្វើការកុំឈប់ព្រោះយើងកំពុងតែត្រូវកងឈ្លបឃ្លាំមើល ដូច្នេះយើងត្រូវពង្រឹងគោលជំហរបដិវត្តន៍ឲ្យបាន

រីងប៉ឹង បើមិត្តឈឺបន្តិចបន្តួចសូមកុំទម្រន់ ព្រោះគាត់ពុំអាចជួយនរណាបានទេដូចទ្រឹស្តីរបស់បដិវត្តន៍ថា «ក្បាលនរណា សក់អ្នកហ្នឹង» ។

មិត្ត ផល បានដំណាលប្រាប់យើងអំពីប្រវត្តិនៃការតស៊ូក្នុងការប្រយុទ្ធនៅសមរភូមិនៅតំបន់ខាងលិចទីក្រុងភ្នំពេញ ។ ពេលនេះសង្គ្រាមបដិវត្តន៍ប្រជាធិបតេយ្យបានបញ្ចប់ហើយ រូបគាត់ក៏ត្រូវបានអង្គការរំសាយដោយសារតែគាត់និន្នាការសង្គមចាស់ ព្រោះពុកគាត់ធ្លាប់ធ្វើជាប៉ូលិសក្នុងរបបសង្គមរាស្ត្រនិយម ។ មិត្ត ផល បានពន្យល់យើងថា ក្នុងអំឡុងសង្គ្រាមអង្គការយល់ថា ប្រមូលផ្តុំក៏ប៉ុន្តែពេលនេះអ្វីៗវាប្រែប្រួលហើយ ព្រោះអង្គការត្រូវការបន្សុទ្ធ អង្គរត្រូវទុកដោយអង្គរ អង្កាមត្រូវទុកដោយអង្កាម ។

មិត្ត ផល ដកដង្ហើមធំហើយបន្តថា ទោះបីយ៉ាងណាក្តី អង្គការគឺជាអ្នកនាំបដិវត្តន៍ដ៏ភ្លឺស្វាង មហាលោតផ្លោះ មហាអស្ចារ្យ!

នោះគឺជាពាក្យដដែលដែលខ្ញុំធុញ ខ្ញុំពុំដឹងថាពាក្យនេះចេញពីដួងចិត្តរបស់កម្មាភិបាលគ្រប់រូប ឬក៏ត្រូវបានបង្ខំឲ្យនិយាយ ។ មិត្ត ផល មិនដូចមិត្ត អ៊ិន ទេ គាត់ចេះអាននិងសរសេរបន្តិចបន្តួច ។ ភូមិរបស់គាត់ត្រូវបានកាន់កាប់ដោយយៀកកុង កាលពីឆ្នាំ១៩៧០ កាលណោះគាត់បានចូលសាលារៀនហើយ ។ បើប្រៀបធៀបនឹងកម្មាភិបាលដទៃទៀត គឺអាចចាត់ទុកថា គាត់គ្រាន់បើជាងគេ ។

អ្នកទាំងអស់គ្នាត្រូវតែពង្រឹងគោលជំហរបដិវត្តន៍ ត្រូវរត់តាមចលនាបដិវត្តន៍ឲ្យដូចជាចលនាទឹកហូរធ្លាក់ពីលើកំពូលភ្នំដែលមានកម្លាំងខ្លាំងក្លាជានិច្ច និងមិនចេះហត់នឿយ គ្មានអ្វីអាចទប់ចរន្តនេះបានទេ ប្រយ័ត្នកង់ប្រវត្តិសាស្ត្រវិលជាន់ ។

គិតទៅគ្រាន់តែមិនដល់មួយខែផង ខ្ញុំបានឮពាក្យនេះរាប់រយដងទៅហើយ តាមខ្ញុំស្មានក្នុងរយៈពេលជិតបួនឆ្នាំ ខ្ញុំបានឮសូរពាក្យនេះប្រហែលប្រាំពាន់ដង ។

ខ្ញុំធ្វើការជាមួយក្រុម ផល ជាងមួយអាទិត្យរហូតដល់មានភាពស្និទ្ធស្នាលជាមួយគាត់ទៀតផង ។ ថ្ងៃមួយ មិត្ត ផល បាននិយាយតិចៗហៅខ្ញុំឲ្យដើរទៅឆ្ងាយពីអ្នកដទៃ ។ គាត់បានសួរខ្ញុំថា តើមិត្តជាបងប្អូនជីដូនមួយរបស់ តាខាន់ មែនទេ?

ក្នុងសម័យនេះកម្មាភិបាលជាន់ខ្ពស់ក្នុងចលនាបដិវត្តន៍ហៅថា «តា» ទាំងអស់ដូចជា តាម៉ុក តាសារុន ។ល។ ពាក្យថា តា ខាន់ គឺសំដៅទៅបងជីដូនមួយខ្ញុំ «មាស សំខាន់» ។ ខ្ញុំឆ្លើយថា ប្រាកដមែន មិត្ត ផល បន្តថា គាត់ត្រូវបានអង្គការចាប់ខ្លួន ដោយចោទថាគាត់ជាជនក្បត់ ជាខ្មាំងស៊ីរូងផ្ទៃក្នុង និងមុខសញ្ញា សេ.អ៊ី.អា ប្រៀបដូចជារន្ទះបាញ់ក្នុងត្រចៀក បងជីដូនមួយខ្ញុំជាជនក្បត់បដិវត្តន៍ ជាភ្នាក់ងារសេ.អ៊ី.អា? មិត្ត ផល សម្លឹងមុខខ្ញុំដោយស្ងៀមស្ងាត់ បន្តមិត្តត្រូវសម្ងំស្ងៀម កុំធ្វើជាដឹងឮអ្វីទាំងអស់ ចំពោះរូបខ្ញុំផ្ទាល់ ខ្ញុំក៏ពុំដឹងថា ជោគវាសនាខ្ញុំនឹងទៅជាយ៉ាងណាដែរ ។ ថ្ងៃស្អែក ខ្ញុំបញ្ជូនមិត្តឲ្យទៅឆ្ងាយពីទីនេះ ដូច្នេះមិត្តត្រូវលាក់ប្រវត្តិរូបរបស់ខ្លួនដើម្បីរក្សាជីវិតឲ្យបានល្អ ។

មិត្ត ផល បានប្រាប់ខ្ញុំថា បងជីដូនមួយរបស់ខ្ញុំតវ៉ាជាមួយអង្គការអំពីការជម្លៀសប្រជាជនចេញពីទីលំនៅហើយក៏ត្រូវចាប់ខ្លួនក្រោយចប់អង្គប្រជុំ ។ គាត់ក៏ត្រូវបាននីរសាររាយការណ៍អំពីការស្វែងរកឪពុករបស់ខ្ញុំ ព្រោះថាបដិវត្តន៍មិនអនុញ្ញាតឲ្យជួយយកអាសាខ្មាំងនោះឡើយ ។ ពេលចប់ការងារ មិត្ត ផល បានចាត់តាំងយុវជនបួននាក់ដើម្បីឲ្យទៅធ្វើការនៅទំនប់ត្រពាំងខ្ទុង ។ យើងទាំងបួននាក់ត្រូវទៅជួបជុំគ្នានៅសហករណ៍ដើម្បីជួបនីរសារឃុំទទួលការណែនាំ ។

ពេលធ្វើដំណើរត្រឡប់មកផ្ទះវិញ ខ្ញុំមានវិប្បដិសារីក្នុងការដែលខ្ញុំបានថ្កោលទោសដល់ជីដូនមួយដែលបំភ្លេចពាក្យសន្យាថានឹងត្រឡប់មកជួយយើងទាំងអស់ តាមការពិតរូបគាត់ផ្ទាល់ជួយតែខ្លួនឯងពុំបានផង គាត់ត្រូវបានអង្គការកម្ទេច ដោយចោទថាជាខ្មាំងទៅហើយ ។ ខ្ញុំនឹកស្រណោះដល់ឪពុកខ្ញុំដែលទន្ទេញតែឈ្មោះក្មួយរបស់គាត់រហូតដល់ដាច់ខ្យល់ ។ គាត់បានរក្សាគឺសង្ឃឹមថាក្មួយរបស់គាត់នឹងត្រឡប់មកជួយកូនប្រុសឲ្យរួចផុតពីក្តីលំបាកវេទនាដោយពុំបានដឹងថា ក្មួយបានទទួលនូវទុក្ខព្រួយដូចអ្នកដទៃទេ ។

## ២៣) កូនឈានមុខដាច់ខាត

ខ្ញុំចាំមិនច្បាស់នូវថ្ងៃពិតប្រាកដទេ ប៉ុន្តែប្រហែលជាខែកក្កដា ១៩៧៥ ដែលមិត្ត ផល បានបញ្ជូនយើងទាំងបួននាក់មានបង ដុន ជានិស្សិតសាស្ត្រចារ្យនៅមហាវិទ្យាល័យគរុកោសល្យ ចំរើន ជាអតីតនិស្សិតមហាវិទ្យាល័យពាណិជ្ជសាស្ត្រ តូច យឿន ជាអតីតសង្ឃ និងរូបខ្ញុំផ្ទាល់ ។ មិត្ត ផល បានប្រាប់យើងថា អង្គការត្រូវការកម្លាំងបួននាក់ដើម្បីបំពេញភារកិច្ចឈានមុខដាច់ខាតទៅធ្វើការនៅទំនប់ត្រពាំងខ្ទុង ។ នៅជួរបដិវត្តន៍មិនប្រើពាក្យថា «មនុស្ស» ទេ

គឺប្រើពាក្យថា "កម្លាំង" ឧទាហរណ៍ មានតម្រូវការយុវជនហាសិបនាក់ គឺថាស្នើកម្លាំងហាសិបនាក់ គឺមិនប្រើពាក្យថា "សុំ" ទេគឺប្រើពាក្យ "ស្នើ" ជំនួសវិញ ។ នេះបានន័យថាខ្មែរក្រហមមិនឲ្យតម្លៃលើមនុស្សជាតិទេ គឺឲ្យតម្លៃលើកម្លាំងតែប៉ុណ្ណោះ បើគ្មានកម្លាំងទេ គឺយើងនឹងក្លាយជារបស់ឥតបានការជាក់ជាពុំខាន ។ យើងមកជួបជុំគ្នានៅស្នាក់ការសហករណ៍ ដែលនៅទីនោះមិត្តនីរសារម្នាក់អាយុប្រហែល១៥ឆ្នាំ បានរង់ចាំយើងជាស្រេចម្នាក់នោះឈ្មោះថា មិត្តវឿន ។ តើមិត្តបងទាំងបួននាក់នេះឬ? ដែលអង្គការចាត់តាំងទៅបំពេញភារកិច្ចនៅទំនប់ត្រពាំងខ្ទុង? បាទ! យើងឆ្លើយព្រមគ្នា ។ មិត្តបងទាំងអស់ត្រូវបានចាត់តាំងដោយអង្គការឲ្យទៅបំពេញភារកិច្ចជាកងឈានមុខដាច់ខាត សូមមិត្តបងពង្រឹងគោលជំហរស្មោះត្រង់ព្រោះថា ទីនោះគឺកន្លែងលត់ដំពង្រឹងគោលជំហរដើម្បីឲ្យក្លាយជាឧបករណ៍ដាច់ខាតរបស់អង្គការដែលឯករាជ្យម្ចាស់ការ ។

មិត្ត វឿន ជិះកង់ទៅមុន រីឯយើងដើរតាមក្រោយ ។ តាមផ្លូវគ្មាននរណាដើរឆ្វេចឆ្វាចទៅមកទេ ហើយបើគ្មានការអនុញ្ញាតគ្មាននរណាមានសិទ្ធិធ្វើដំណើរឡើយ ។ ក្រុមឈ្លបឃុំដែលយាមតាមផ្លូវ នឹងឆែកបើគ្មានសំបុត្រស្នាមទេ ត្រូវឃាត់ ហើយបញ្ជូនទៅកាន់មណ្ឌលអប់រំដែលហៅថា គុក ។ ប្រហែលជាបីគីឡូម៉ែត្រ មិត្ត វឿន បានឈប់នៅកន្លែងឆែកឆេរ ហើយបង្ហាញសំបុត្រធ្វើដំណើរ លុះយើងដើរមកដល់ទើប មិត្ត វឿន ជិះកង់ទៅចាំនៅកន្លែងប៉ុស្តិ៍យាមមួយទៀត ។ យើងធ្វើដំណើរឆ្លងកាត់ ប៉ុស្តិ៍យាមប្រហែលប្រាំពីរកន្លែងទើបយើងមកដល់ការដ្ឋានមួយ ។ មិត្ត វឿន ប្រគល់ក្រដាសទៅឲ្យមិត្ត ស៊ិន ដែលមើលទៅទឹកមុខរបស់គាត់គួរឲ្យខ្លាចពន់ពេក ភ្នែកក្រហមដូចបិសាច ។

សួស្តីមិត្តទាំងអស់គ្នា ទីនេះជាជំរំលត់ដំកងឈានមុខដាច់ខាត សូមមិត្តទាំងអស់គ្នាទៅកាន់ការដ្ឋាន ។ មិត្ត ស៊ិន ពុំបានទុកពេលឲ្យយើងអង្គុយបាត់ហត់ឡើយ គាត់ចង្អុលការដ្ឋានទំនប់ទឹកដែលនៅស្ទឹងតានៃដែលហៅថាទំនប់ត្រពាំងខ្ទុង ។ នៅទីនោះ ខ្ញុំឃើញយុវជនប្រហែលជាងម្ភៃនាក់ក្បាលត្រងោលសក់ទើបនឹងដុះថ្មី ។ អ្នកទាំងនោះជាអតីតសង្ឃដែលអង្គការចាត់ទុកថា វណ្ណៈអធន ពុទ្ធសាសនាដែលត្រូវលត់ដំខ្លាំងជាងប្រជាជនធម្មតា ព្រោះថា ព្រះពុទ្ធសាសនាជាវណ្ណៈជិះជាន់មួយដែលខ្ជិលធ្វើការ ហើយរស់នៅដោយពឹងលើកម្លាំងពលកម្មអ្នកដទៃ ។

ខ្ញុំជាមួយនឹងមិត្តរួមដំណើរទាំងបីនាក់ទៀត គឺមាននិន្នាការវណ្ណៈស្រដៀងនឹងអន្ទិតទាំងនោះដែរ ដូច្នេះយើងត្រូវហាត់ពត់លត់ដំដូចគ្នាដើម្បីឲ្យក្លាយជាជនបដិវត្តន៍ ។ របបអាហារនៅទីនោះរិតតែយ៉ាប់ជាងនៅសហករណ៍ទៅទៀត ។ យើងទទួលបាននូវបបរលាយដំឡូងមួយវែកព្រមទាំងសម្លមួយចានសម្រាប់គ្នាបួននាក់ ។ បបរនោះរាវពន់ពេកណាស់ ហើយសង្កេតឃើញមានដំឡូងជ្វាបីដុំតូចៗ មិត្ត ស៊ិន ឈរមើលយើងហូបហើយពន្យល់ ថាចក្រពត្តិអាមេរិកបានទម្លាក់គ្រាប់បែកបំផ្លាញទឹកដីរបស់យើងធ្វើឲ្យយើងវិនាសហិនហោចអស់ មិត្តទាំងអស់ត្រូវតែទ្រាំពុះពារការលំបាកយើងធ្វើបដិវត្តន៍កសិកម្មដើម្បីឲ្យបានលទ្ធផលមួយហិចតាបីតោន សព្វថ្ងៃយើងរស់នៅជំរំរបបសមូហភាព ឆ្នាំក្រោយយើងនឹងមានហូបគ្រប់គ្រាន់ យើងប្រៀបដូចជាដែកថែប ត្រូវតែលត់ដំសតិអារម្មណ៍ឲ្យរឹងជានិច្ច តស៊ូជានិច្ច ក្រោមការដឹកនាំរបស់អង្គការដ៏មហាក្លៀវក្លាមហាលោតផ្លោះ មហាអស្ចារ្យ ។ គាត់សម្លឹងមកកាន់ខ្ញុំ ដូចជាមិត្តខាងនោះធ្លាប់នៅក្នុងភាពសម្បូរសុខសម្ភ មិត្តមិនធ្លាប់ស្គាល់រសជាតិនៃការជិះជាន់ សង្កត់សង្កិន វណ្ណៈសក្តិភូមិនោះទេ តើការឈឺចាប់ និងកំហឹងវណ្ណៈវាយ៉ាងណា ឥឡូវមិត្តត្រូវកសាងខ្លួន ដើរតាមចន្លាក់នៃចលនាបដិវត្តន៍ហូបបាយហើយត្រូវប្រញាប់ទៅបំពេញភារកិច្ចវិញ ។

## ២៤) ឃ្លោកលេចអំបែងអណ្តែត

"ឃ្លោកលិចអំបែងអណ្តែត" ជាពាក្យដែលខ្ញុំធ្លាប់ស្គាល់ ធ្លាប់ឮតាំងពីកុមារភាពម្ល៉េះ តែខ្ញុំយល់ពុំទាន់ច្បាស់ទេ ។ កងឈានមុខដាច់ខាតយើងមានកម្លាំងម្ភៃប្រាំបីនាក់ ភាគច្រើនជាអន្ទិតទើបនឹងសឹក ។ យើងខំលាក់ប្រវត្តិដោយខំប្រាប់ថា ចេះអក្សរបន្តិចបន្តួចជាអ្នករត់តុនៅហាងគុយទាវ រីឯចំរើន គឺជាតែតុងតាក់ស៊ី បងជុនជាកម្មករនៅរោងចក្រ ។ ប្រហែលជាអង្គការពុំជឿយើងទេ បានជាបញ្ជូនយើងមកដល់ទីនេះ ។ យើងត្រូវក្រោកធ្វើការតាំងពីម៉ោងប្រាំព្រឹករហូតដល់ម៉ោងដប់យប់ គិតទៅដប់ប្រាំមួយម៉ោងក្នុងមួយថ្ងៃ ដើម្បីប្តូររបបអាហារតិចតួចបំផុត ដោយទ្រាំនឹងអាកាសធាតុត្រជាក់នាពេលព្រឹកក្នុងទឹកស្ទឹងតំបន់គ្រុនចាញ់ ។

អ្វីដែលលំបាកសម្រាប់រូបខ្ញុំនោះគឺខ្ញុំពុំធ្លាប់ដើរដោយជើង

ទទេឡើយ ពេលនេះគ្មានផ្សារ ឬលុយដើម្បីទិញស្បែកជើងនោះឡើយ ។ ពេលនេះជើងរបស់ខ្ញុំក៏ហើមរលួយ ហើយត្រូវដើរលើថ្ម ឬស្មៅបណ្តាលឲ្យដាច់ចេញឈាមឈឺផ្សាជាខ្លាំង ក៏ប៉ុន្តែបើយើងហ៊ានថ្ងូរ ឬពុំទៅធ្វើការនោះអង្គការនឹងចោទថា ខ្មាំងសតិអារម្មណ៍ ឬជាជនប្រតិកិរិយាធ្វើវិទ្ធង្សនាប្រឆាំងបដិវត្តន៍ ដូច្នេះមានតែត្រូវដើរទាំងឈឺចាប់រហូតដល់ដំបៅរីកដូចមាត់ខ្ទង ។ ខ្ញុំឮគេប្រាប់ថាឲ្យសកសំបកកន្ទួតព្រៃយកមកទំពារ ហើយព្រួសលើដំបៅនោះនឹងជួយបន្ថយការឈឺចាប់បន្តិច ក៏ប៉ុន្តែនៅតែជួបការលំបាកក្នុងការដើរកាត់បន្ទាឬដុំថ្មដដែល ។ ជារៀងរាល់ថ្ងៃ ខ្ញុំតែងសម្លឹងមើលស្បែកជើងកង់ឡានរបស់សមមិត្តដែលវាហាក់ដូចជា មានភាពសង្ហាខ្លាំងណាស់បើប្រៀបធៀបនឹងស្បែកជើងសម័យឥឡូវនេះវាសង្ហាជាងម៉ាកល្បីដាក់ក្នុងទូកញ្ចក់នៅផ្សារទំនើបទៅទៀត ។ ស្បែកជើងកង់ឡាននេះគឺធន់នឹងបន្លា ហើយពេលចុះទឹកក៏មិនជ្រាបងាយស្រួលដើរដែរ ។ ខ្ញុំស្រមៃចង់បានស្បែកជើងកង់ឡានរបស់សមមិត្តនោះខ្លាំងណាស់ ។ ទោះបីជាឈឺជើងយ៉ាងណាក៏ដោយ ក៏ខ្ញុំត្រូវធ្វើការដែរ ព្រោះបើខ្ញុំមិនទៅធ្វើការទេ អង្គការនឹងកាត់របបរបស់ខ្ញុំដាក់ជាពុំខាន ។ ដោយទ្រាំឈឺជើងពុំបាន ខ្ញុំក៏កើតគំនិតធ្វើស្បែកជើងគាវគ្នោត និងវល្លិថ្មីង ។ ខ្ញុំពាក់សាកលមើល គឺពិបាកដើរខ្លាំងណាស់មើលទៅប្រផេងប្រផាងដូចជាតួអង្គកំប្លែងក្នុងរឿងសាក់ឡូ ។ ពេលកម្មាភិបាល និងក្រុមអន្ទិតឃើញហើយនាំគ្នាសើចចំអកដាក់ខ្ញុំគ្រប់គ្នាថា ពុំដែលឃើញស្បែកជើងបែបនេះទេ តើខ្ញុំបានទៅរៀនច្នៃប្រឌិតនេះពីប្រទេសណា? រឿងនេះបានឲ្យធ្វើខ្ញុំខ្មាស់គេខ្លាំងណាស់ ហើយក៏បោះស្បែកជើងគាវគ្នោតនោះចោល ។ ខ្ញុំនៅតែជួបការលំបាកក្នុងការដើរក្នុងព្រៃដដែល ដោយទ្រាំនឹងការឈឺជើងពុំបាន និងខ្មាសគេផង ខ្ញុំក៏បានយកខ្សែកមាសរបស់ម្តាយខ្ញុំទៅដូរនឹងស្បែកជើងកង់ឡានរបស់សមមិត្តបានមួយសម្រាប់ ។ ស្បែកជើងកង់ឡាននេះខ្ញុំបានពាក់វាអស់រយៈបួនឆ្នាំ រហូតដល់ការដួលរលំនៃរបបនេះ វាបានជួយខ្ញុំផុតពីទុក្ខលំបាកនៃការឈឺជើងដែរ ។ ចំពោះខ្សែកមាសរបស់ម្តាយដែលបានយកទៅដូរស្បែកជើងនោះ បើឥឡូវនេះ ខ្ញុំអាចប្តូរបានស្បែកជើងធម្មតាបានមួយពាន់សម្រាប់ឯណោះ ។

រឿងមួយទៀតដែលខ្ញុំចងចាំអស់មួយជីវិតគឺថាបន្ទាប់ពីមករស់នៅក្នុងកងយុវជនឈានមុខដាច់ខាតនេះ ខ្ញុំបានចុះស្ទូមយ៉ាងខ្លាំងដោយធ្វើការលំបាកហើយហូបពុំគ្រប់គ្រាន់ ។ ខ្ញុំពុំដូចពួកអន្ទិតសុទ្ធតែកូនអ្នកស្រែចម្ការចេះចាប់ត្រី បាញ់កណ្តុរ ដាក់អន្ទាក់សត្វ ជីកក្តាម ជីកកង្កែប ។ ចំណែកខ្ញុំគឺចេះតែចាប់សត្វណាដែលវាយឺតៗដូចជា កូនក្អាត់ កូនខ្មៅតូចៗ និងគីង្គក់ ប៉ុន្តែសត្វទាំងនោះគឺមិនស្រួលរកប៉ុន្មានទេ ព្រោះយើងក៏រក គេក៏រក ដូច្នេះ ខ្ញុំមានតែត្រូវរើសផ្លែធ្លក ដែលជាចំណីសត្វឈ្លូស និងជ្រូកព្រៃយកមកស្ងោរ ។ ធម្មតាអ្នកមូលដ្ឋានចាស់ សូម្បីតែអ្នកទាំងនោះជាអ្នកស្រែចម្ការតែក៏ពុំដែលហូបផ្លែធ្លកដែរ ។ កម្មាភិបាលឃើញហើយនាំគ្នាសើចចំអកឲ្យយើង ពេលនោះហើយដែលខ្ញុំនឹកឃើញនូវពាក្យស្លោក "ឃ្លោកលិចអំបែងអណ្តែត" គឺថាយើងជាអ្នកទីក្រុងដែលធ្លាប់តែមើលងាយអ្នកស្រែចម្ការដល់វេនយើងដែលអ្នកស្រែមើលងាយយើងម្តងវិញហើយ ។

## ២៥) ទុកមិនចំណេញដកចេញមិនខាត

ភារកិច្ចដែលអង្គការប្រគល់ឲ្យកងយុវជនឈានមុខដាច់ខាត គឺកសាងទំនប់ត្រពាំងខ្ទង ដើម្បីយកទឹកធ្វើស្រែនៅតានៃ ទំនប់ថ្មី និងត្រពាំងអាឡោ ។ ទំនប់នេះសង់អំពីឈើដោយមធ្យោបាយយ៉ាងសាមញ្ញគឺត្រូវបោះបង្គោលឈើទៅក្នុងទឹក ហើយសង់ស្ពានឈើក្រាលក្តារ ហើយទ្វារទឹកក៏ជាបន្ទះក្តារសឹកបន្តពីលើគ្នា ។ ទឹកស្ទឹងដែលហូរចុះពីលើភ្នំដាំ តំបន់ភ្នំឱរ៉ាល់នារដូវវស្សាគួចត្របាញ់ធ្វើឲ្យរងាញ័ររញ្ជាក់ ។ យើងចុះទឹកស្ទឹងទាំងព្រឹកព្រលឹម រីឯមិត្ត ស៊ិន ពុំដែលខ្វល់ពីនរណាឡើយ គាត់គិតតែសម្រុកការងារដើម្បីផ្គាប់ចិត្តអង្គការថ្នាក់លើតែប៉ុណ្ណោះ ។ ប្រហែលម៉ោងប្រាំបួនព្រឹក ស៊ិនបានបង្គាប់ឲ្យខ្ញុំទៅបិទទ្វារទឹក ។ តាំងពីកើតមក ខ្ញុំមិនដែលស្គាល់ថាអ្វីជាទ្វារទឹកនោះទេ ។ មិត្ត ស៊ិន ប្រឡោតខឹងយ៉ាងខ្លាំងហើយ ជៀលត្មះខ្ញុំថា អាពួកវណ្ណៈជិះជាន់ វាមិនដែលចេះធ្វើអ្វីទេ គឺចេះតែកេងប្រវ័ញ្ចលើកម្លាំងអ្នកដទៃពួកឯងនេះ មិនសមស៊ីបាយសោះ ថាហើយគាត់ក៏បង្ហាញបន្ទះក្តារដល់ខ្ញុំឲ្យយកទៅសឹកនៅមាត់ទ្វារទឹកហើយជាន់ក្តារទម្លាក់ចុះ ម្តងមួយសន្ទឹកៗ តែពេលនោះ ខ្ញុំក៏របូតដៃដោយសារកម្លាំងទឹកខ្លាំងពេក បោកធ្លាក់ទៅក្រោម ។ ពេលដឹងខ្លួនឡើងក៏ឃើញពួកអន្ទិត កំពុងសែងខ្ញុំឡើងទៅលើមាត់ទំនប់ ខ្ញុំត្រូវរបួសបែកក្បាល បែកមុខ និងដៃជើងជាច្រើនកន្លែង ពេលនោះមិត្តជិតស្និទ្ធរបស់ខ្ញុំគឺ តូច, យឿង, ចំរើន, បងជុន និង សម្បត្តិ បានផ្តេកខ្លួនខ្ញុំទៅ

លើស្មៅ ហើយដើររកវល្លិ៍ដុយដែលមានជ័រពណ៌សដូចទឹកដោះគោ យកមកបន្តក់លើមុខរបួសឲ្យខ្ញុំ ។ ខ្ញុំត្រូវបានគ្រាយកមករោងការដ្ឋាន ដើម្បីសម្រាកព្យាបាល ។ ពេលនោះមិត្ត ស៊ិន ពុំបានសម្តែងនូវការអាណិតអាសូរដល់ខ្ញុំទេ ។ គាត់ក្រវីក្បាលដោយហួសចិត្តថា នេះហើយវណ្ណៈជិះជាន់ មូលធននិយម ចក្រពត្តិដែលធ្លាប់តែជិះជាន់វណ្ណៈអធន កសិករ កម្មករក្រីក្រ តើពួកនេះនឹងអាចហាត់ពត់លត់ដំបដិវត្តន៍បានយ៉ាងដូចម្តេចទៅ? នៅរោងការដ្ឋាន មិត្តដ៏ល្អរបស់ខ្ញុំបានដាក់ខ្ញុំឲ្យដេក ហើយដើររកផ្សិត យកមកពុះហើយស្ងោរឲ្យខ្ញុំផឹក ហើយក៏ប្រញាប់ត្រឡប់ទៅបំពេញភារកិច្ចជូនអង្គការដោយពុំហ៊ាននៅយូរឡើយ ។

របួសរបស់ខ្ញុំធ្ងន់ណាស់ វាឈឺចាប់ហួសប្រមាណ ខ្ញុំកម្រើកដៃជើងពុំបានសោះឡើយ សូម្បីតែដើរទៅរោងបាយក៏ដើរពុំរួច មិត្តខ្ញុំបានយកបបរមកឲ្យខ្ញុំដល់កន្លែងដេក ក៏ប៉ុន្តែខ្ញុំហូបពុំបានអ្វីទេ នោះទើបអង្គការជឿថាខ្ញុំពិតជាពុំមែនឈឺសតិអារម្មណ៍ ។ ថ្ងៃទីពីរនៃការសម្រាកព្យាបាល ខ្ញុំគ្មានថ្នាំអ្វីក្រៅពីសំបកឈើ និងផ្សិតសុក្រំដែលមិត្តរបស់ខ្ញុំបានដាំនឹងកំសៀវកញ្ចាស់មួយយកមកឲ្យខ្ញុំផឹក ឯមិត្តខ្លះក៏បានយកត្រីដុកអាំងនិងមើមដំឡូងព្រៃយកមកឲ្យខ្ញុំហូប ។ ពេលដែលខ្ញុំកំពុងតែដេកលក់រលីវៗ នោះស្រាប់តែឮសំឡេងមិត្ត ស៊ិន និយាយគ្នាជាមួយស្ត្រីម្នាក់ ។ ខ្ញុំលួចបើកភ្នែកមើល ក៏ឃើញមិត្ត ស៊ិន បញ្ចេញអាកប្បកិរិយាឱនលំទោន ដូចជាខ្លាចស្ត្រីនោះខ្លាំងណាស់ ។ មិត្ត ស៊ិន និយាយមួយៗយ៉ាងសុភាពទៅកាន់ស្ត្រីរូបនោះថា វានោះឈ្មោះអាស្លឹក ជាអតីតកងកុម្មង់ដូ កងឈ្លបយើងបានចាប់ក្នុងពេលកំពុងលួចដំឡូង ពេលយើងចងវាដើម្បីសួរចម្លើយ វាធ្វើបុកក្រអឺត ហើយមិនឆ្លើយអ្វីទាំងអស់ ស្ត្រីនោះនិយាយដោយទឹកមុខពោរពេញទៅដោយកំហឹងថា ជាខ្មាំងស៊ីរូងផ្ទៃក្នុងប្រឆាំងបដិវត្តន៍ ប្រតិកិរិយា ត្រូវបញ្ជូនទៅការដ្ឋានជាបន្ទាន់ អាពួកនេះ បើទុកក៏មិនចំណេញ ហើយដកចេញក៏មិនខាត ។ ខ្ញុំឮមិត្ត ស៊ិន ឆ្លើយតបថា បាទៗ ញាប់មាត់ហើយក៏ដើរចេញទៅ ។ ពេលក្រោយមក ទើបខ្ញុំដឹងថាស្ត្រីម្នាក់នោះឈ្មោះ មិត្ត មឿន ជាលេខាបក្សឃុំជៀប ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង ។ គាត់គឺជាជនបដិវត្តន៍ ជាសកម្មជនដែលត្រូវបានអង្គការទុកចិត្ត ជាស្ត្រីដែលមានគោលជំហរដាច់ខាត គាត់ទទួលបន្ទុកត្រួតពិនិត្យអង្គការវិន័យ ហើយជាអ្នកសម្រេចជោគវាសនាជនណាដែលប្រឆាំងបដិវត្តន៍ ពេលដែល មិត្ត មឿន ទៅដល់ទីណា តែងតែមានមនុស្សបាត់ខ្លួន អ្នកណាក៏ខ្លាចគាត់ដែរ ។ ខ្ញុំបានឃើញ ស្លឹក ត្រូវចងក្រៀកដៃក្រពាត់ទៅក្រោយសម្លៀកបំពាក់ត្រូវសម្រាតចេញពីខ្លួនទុកតែខោខ្លីដោយមានកងឈ្លបពីរនាក់បណ្តើរនាំចេញទៅ ។

បដិវត្តន៍កំពុងតែធ្វើបន្សុទ្ធកម្មអង្ករត្រូវទុកដោយអង្ករ ចំណែកអង្កាមត្រូវតែកម្ទេចចោល ។ ពីរបីថ្ងៃក្រោយមក ទោះបីជាខ្ញុំពុំជាស្រួលបួលក៏ដោយ ក៏ខ្ញុំត្រូវតែបង្ខំចិត្តចេញទៅធ្វើការដែរ ព្រោះខ្ញុំសង្កៀរត្រចៀកនឹងសម្តី មិត្តស៊ិន តែងតែរអ៊ូរទាំពីការងារដែលស្ទះដោយសារកម្លាំងមិនបញ្ចេញពលកម្មពេញលេញធ្វើឲ្យចលនាបដិវត្តន៍មិនជឿនលឿនទៅមុខ ។ មិត្ត ស៊ិន ជាជនបដិវត្តន៍សកម្មខ្លាំងណាស់ គាត់មិនដែលចេះញញឹមឬសួរសុខទុក្ខនរណាទេ ក្នុងខួរក្បាលគាត់គឺបំពេញចិត្តអង្គការថ្នាក់លើដើម្បីឲ្យគាត់ទទួលដំណែងខ្ពស់ក្នុងជួរអង្គការជាន់ខ្ពស់ ។ ខណៈដែលខ្ញុំបានជាធូរពីមុខរបួសបន្តិចស្រាប់តែ បងដុន បានធ្លាក់ខ្លួនឈឺជំងឺរាកយ៉ាងធ្ងន់ធ្ងរ ។ ខ្ញុំពុំដឹងជាជួយ បងដុន យ៉ាងណាទេ មានតែដើរស្ទោះសំបកត្របែកយកមកដាំទឹកបីយកទឹកមួយឲ្យគាត់ផឹក នៅពេលនោះ គាត់ដេកនឹងកន្ទេលពុំមានកម្រើកសោះ ព្រោះគាត់ចុករាគហូរដូចទឹក ពីរម៉ោងក្រោយមក គាត់ក៏ដាច់ខ្យល់ស្លាប់ ។ មិត្ត ស៊ិន បានចាត់តាំងខ្ញុំ គួច ឃឿន និង ចំរើន ឲ្យយកសព បងដុន ទៅដុត ។ យើងបានរុំសពបងដុន និងទ្រៀសរនាបប្រាំបីទៅដុតនៅក្បែរគុម្ពឫស្សីប្រហែលប្រាំរយម៉ែត្រពីជំរំ ។

## ២៦) កង់ប្រវត្តិសាស្ត្រវិលជាន់ឯងហើយ

រាល់ល្ងាចយើងឈប់ធ្វើការនៅម៉ោងប្រាំបីយប់ តែក៏ពុំអាចទៅដេកទេ គឺត្រូវប្រជុំជីវភាព ឬប្រជុំទិតៀន និងស្វ័យទិតៀន ។ ឬអាចហៅម្យ៉ាងទៀតថា ជាការប្រជុំដើម្បីឆ្កឹះចន្ទុះ ។ ធម្មតាចន្ទុះកាលណាដុតយូរៗ ទៅវាមានក្រមរដែលធ្វើឲ្យស្រអាប់ លុះត្រាតែយើងឆ្កឹះវាយកក្រមរចេញទើបភ្លឺ យ៉ាងណាមិញ សតិអារម្មណ៍របស់មនុស្សក៏ដូចគ្នា បើមិនប្រជុំដាស់តឿនទេ វានឹងក្លាយទៅជាស្ពឹកស្រពន់មិនមានចលនាទៅមុខដែលជាហេតុធ្វើឲ្យស្ទះចលនាបដិវត្តន៍ ។ កិច្ចប្រជុំរាល់យប់ពុំដែលមិនមានបញ្ហាអ្វីទេ ទោះបីជាយើងអស់កម្លាំងយ៉ាងណាក្តី ក៏ទ្រាំនៅស្តាប់រហូតដល់ចប់ ក៏ប៉ុន្តែមានយប់មួយ មានអន្ទិតម្នាក់ឈ្មោះ ឈឿន បានសូមបញ្ចេញយោបល់ផ្ទាល់ខ្លួន ។

ឈឿន ជាអតីតភិក្ខុជាសមាជិកនិស្សិតនៅពុទ្ធិកមហាវិទ្យាល័យ ក្រុងភ្នំពេញ ជាយុវជនដែលមានការចេះដឹងទាំងផ្លូវលោក ផ្លូវធម៌ ហើយមានរាងហោរក្បោះក្បាយណាស់ ។

សូមគោរពអង្គប្រជុំ សូមគោរពកម្មាភិបាលទាំងអស់ រូបខ្ញុំពេញចិត្តនឹងចលនាបដិវត្តន៍ណាស់ ជាទ្រឹស្តីឃើញថា បដិវត្តន៍ល្អឥតខ្ចោះ ក៏ប៉ុន្តែបើពន្យល់ទៅលើសច្ចភាព ខ្ញុំគិតថា យើងមិនអាចទទួលបាននូវភាពស្មើគ្នា និងយុត្តិធម៌បានទេ ។ សូមអង្គការពិចារណាឲ្យដិតដល់ថា ទោះបីជាប្រើគោ ក៏ត្រូវឲ្យវាស៊ីស្មៅឆ្អែតដែរ ចុះហេតុអ្វីក៏យើងទាំងអស់គ្នាអន់ជាងគោទៅទៀត ដោយត្រូវធ្វើការដប់ប្រាំមួយម៉ោងហើយទទួលម្ហូបអាហារតិចតួចយ៉ាងនេះទៅវិញ?

ពេលនោះ មិត្ត ស៊ិន ប្រែទឹកមុខ ។ គាត់ក្រោកឈរឡើងយ៉ាងយឺតៗ ឯសំឡេងរបស់គាត់ក៏ប្រែប្រួល ហើយនិយាយទៅកាន់អង្គប្រជុំថា មិត្តទាំងអស់! ពេលនេះយើងរកមុខឃើញខ្មាំងស៊ីរូងផ្ទៃក្នុងហើយ គឺជាពួកប្រតិកិរិយាប្រឆាំងបដិវត្តន៍ ។ មិត្ត ស៊ិន ងាកមុខទៅរកនិសារពីរនាក់ដែលនៅក្បែរនោះ ដោយធ្វើដៃជាសញ្ញា ឈឿន ត្រូវចងស្លាបសេក ហើយបណ្តើរទៅកាន់មាត់ស្ទឹង ។ នាពេលយប់ងងឹត យើងត្រូវបាន មិត្ត ស៊ិន ហៅទៅមើលដោយដុតចន្លុះបំភ្លឺផង ។ មិត្តស៊ិន បានប្រាប់យើងទាំងអស់គ្នាចាំមើលកង់ប្រវត្តិសាស្ត្រដែលវិលជាន់ក្បាលវា ។ មិត្ត ស៊ិន ចង្អុលទៅទឹកដែលកំពុងហូរគ្របាញ់ ព្រោះភ្លៀងបណ្តាលឲ្យទឹកជន់យ៉ាងខ្លាំង ។

ចរន្តបដិវត្តន៍ប្រៀបដូចជាទឹកហូរធ្លាក់ពីលើកំពូលភ្នំ! តើឯងអាចយកឫស្សីពីរបីដើមទៅទប់ទឹកនោះបានដែរទេ? ដូច្នេះបើឯងចង់ដឹងចូរសាកល្បងហែលឆ្លងទឹកស្ទឹងដែលកំពុងជន់នេះចុះ បើឯង ហែលឆ្លងរួច ឯងនឹងបានរស់ ។ បន្ទាប់មក មិត្ត ស៊ិន ក៏ច្រានឈឿន ទម្លាក់ចូលទៅក្នុងទឹកស្ទឹងដែលកំពុងហូរយ៉ាងខ្លាំង យើងយល់យ៉ាងណាចំពោះយុវជនម្នាក់ដែលត្រូវចងដៃទៅក្រោយ តើឈឿន អាចហែលឆ្លងទឹកស្ទឹងដែលកំពុងជន់យ៉ាងនេះបានដែរ? ឈឿន ត្រូវទាញមកវិញដោយខ្សែពួរដែលចងបន្ទាយពីក្រោយចំណងមកលើដោយបាត់ស្មារតីទៅហើយ ។ មិត្ត ស៊ិន ក៏បញ្ជាឲ្យធាក់ទម្លាក់ជាលើកទីពីរ រួចទាញស្រាវមកលើសាជាថ្មី ។ លើកទីពីនេះ ឈឿន បានដាច់ខ្យល់ស្លាប់ទៅហើយ ។ មិត្ត ស៊ិន ងាកមកមើលយើង ហើយប្រាប់ថា មិត្តទាំងឡាយ! តើមាននរណាចង់ស្គាល់រស់ជាតិកង់ប្រវត្តិសាស្ត្រជាន់ក្បាលទេ ។ យើងនៅស្ងៀម មិត្ត ស៊ិន បញ្ជាឲ្យអូសខ្មោច ឈឿន ទៅកប់ ។ **(នៅមានត)** **ឆាយ ស៊ុឆាត្រ**

# ដំណឹងស្វែងរកគ្រួសារ



នាងខ្ញុំឈ្មោះ វង ជន ហៅ ង៉ែត ភេទស្រី ពីសង្គមចាស់រស់នៅភូមិបឹងទំពន់ ហៅ ទំនប់ថ្មី ក្រុងភ្នំពេញ ។ បច្ចុប្បន្ន នាងខ្ញុំរស់នៅភូមិទួលក្រាំង ឃុំក្រាំងយ៉ូវ ស្រុកស្អាង ខេត្តកណ្តាល ។ នាងខ្ញុំបានបែកពីប្តីឈ្មោះ អ៊ិត ដាំណា ហៅ យ៉ត ពេលខ្មែរក្រហមជម្លៀសគ្រួសារខ្ញុំចេញពីក្រុងភ្នំពេញ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ វេលាម៉ោង៩ព្រឹក ។ ពេលនោះ នាងខ្ញុំមានកូនស្រីម្នាក់ឈ្មោះ អ៊ិត ចាន់រី ហៅ អាស្រី មានអាយុ៤ឆ្នាំ និងកំពុងមានផ្ទៃពោះ៧ខែ កូនទីពីរទៀត ។

ក្រោយមក ទើបនាងខ្ញុំទទួលដំណឹងថា ប្តីរបស់នាងខ្ញុំដែលបានបែកគ្នាជំនាន់ខ្មែរក្រហមបានមកសួររកនាងខ្ញុំនៅភូមិដែលរស់នៅបច្ចុប្បន្ន ប៉ុន្តែអ្នកជិតខាងបានប្រាប់ថា នាងខ្ញុំនិងកូនបងប្អូន ព្រមទាំងឪពុកម្តាយស្លាប់អស់ហើយ ។ នាងខ្ញុំមិនចាំពេលវេលាដែលប្តីនាងខ្ញុំមករកទេ ។

បច្ចុប្បន្នខ្ញុំ និងកូន ព្រមទាំងបងផាន បងផល រស់នៅក្នុងភូមិទួលក្រាំង ។ ប្រសិនបើបងប្អូនណាបានទទួលដំណឹងនេះ សូមទាក់ទងមកនាងខ្ញុំតាមរយៈអាសយដ្ឋានរបស់នាងខ្ញុំដូចខាងលើ ឬទូរស័ព្ទ ០ ១២ ៩៩២ ១៧១ ឬទាក់ទងមកមជ្ឈមណ្ឌលឯកសារកម្ពុជា ផ្ទះលេខ៦៦ ផ្លូវព្រះសីហនុ ក្រុងភ្នំពេញ ។ **សូមអរគុណ!**

# ជីតាខ្ញុំរៀបរាប់ប្រាប់

របបកម្ពុជាប្រជាធិបតេយ្យដែលត្រូវបានប្រជាជនទូទៅស្គាល់ថាជារបបខ្មែរក្រហម ឬជារបបប្រល័យពូជសាសន៍បានសម្លាប់ប្រជាជនកម្ពុជាស្លូតត្រង់អស់ជិតពីរលាននាក់ ។ បើទោះបីជារបបនេះដួលរលំអស់រយៈពេល៣៤ឆ្នាំហើយក៏ដោយក្តី ក៏ខ្ញុំកត់សម្គាល់ឃើញថា ប្រជាជនកម្ពុជាភាគច្រើន ពិសេសជនរងគ្រោះផ្ទាល់ពីសម័យនោះ ដែលទទួលរងទុក្ខទាំងផ្លូវកាយ និងផ្លូវចិត្តនៅតែធ្វើឲ្យគាត់មិនអាចបំភ្លេចបាននូវអ្វីដែលបានកើតឡើងចំពោះខ្លួនគាត់ផ្ទាល់ ។

ចំពោះខ្ញុំដែលជាយុវជនខ្មែរជំនាន់ក្រោយ ពិតជាពិបាកនឹងជឿនូវអ្វីដែលបានកើតឡើងចំពោះប្រជាជនកម្ពុជាទូទាំងប្រទេសដែលបានធ្វើទុក្ខបុកម្នេញពីសំណាក់ខ្មែរក្រហម តែវាជាការពិតមិនអាចប្រកែកបាន ពិសេសការជម្លៀសប្រជាជនពីទីក្រុងឲ្យទៅរស់នៅ និងធ្វើការនៅតាមទីជនបទ ការសម្លាប់ ការធ្វើទារុណកម្ម ការបង្អត់អាហារ ការបង្ខំឲ្យធ្វើការហួសកម្លាំង និងជំងឺ ។ ទុក្ខវេទនា និងការឈឺចាប់ទាំងនោះនៅតែជិតដាមជាប់ជាមួយជនរងគ្រោះជានិច្ច ។


ជួន ឡោ (ជីតារបស់ ណៃហ៊ីរ) ថតនៅឆ្នាំ១៩៨៣

ជាក់ស្តែង ជីតារបស់ខ្ញុំដែលសព្វថ្ងៃគាត់មានអាយុ៨០ឆ្នាំហើយ បានរៀបរាប់ប្រាប់ខ្ញុំពីរឿងដែលគាត់បានឆ្លងកាត់ចាប់តាំងពីសម័យសង្គមរាស្ត្រនិយមមកដល់សព្វថ្ងៃ ។ គាត់ជាកសិករនៅភូមិចុងកោះតូច ឃុំគាលន់ ស្រុកស្អាង ខេត្តកណ្តាល ។ នៅឆ្នាំ១៩៧០ នៅពេលដែលលោកសេនាប្រមុខលន់ នល់ ធ្វើរដ្ឋប្រហារទម្លាក់សម្តេចព្រះនរោត្តម សីហនុ អ្នកភូមិទាំងឡាយមិនសុខចិត្ត និងបានកេណ្ឌកម្លាំងតវ៉ា រួមជាមួយការអំពាវនាវពីសំណាក់ព្រះអង្គផង ប្រជាជនបានធ្វើបាតុកម្មប្រឆាំងនឹងលោកសេនាប្រមុខលន់នល់ តែត្រូវបានបង្ក្រាបទៅវិញ ។ ចាប់ពីពេលនោះមក ការតស៊ូប្រឆាំងនឹងរបបសាធារណរដ្ឋរបស់លោកសេនាប្រមុខលន់នល់ ក៏ចាប់កើតមានឡើង ។

គាត់បានបន្តថា នៅក្នុងខែឧសភា ឆ្នាំ១៩៧០ មានការវាយប្រយុទ្ធគ្នារវាងកងទ័ព

រំដោះខ្មែរក្រហម ជាមួយនឹងកងទ័ពស្រោចស្រង់របស់លោក សេនាប្រមុខ លន់ នល់ នៅម្តុំវត្តតាលន់ ស្ថិតក្នុងភូមិតាលន់ ឃុំតាលន់ ស្រុកស្អាង ខេត្តកណ្តាល ដោយទ័ពរដ្ឋាភិបាលចោទទៅលើទ័ពរំដោះថា ជាទ័ពរបស់យៀកកុង ។ ការប្រយុទ្ធគ្នានេះចាប់ផ្តើមនៅពេលព្រឹក ហើយមកដល់ម៉ោងប្រហែលប្រាំល្ងាចស្រាប់តែមានយន្តហោះរបស់រដ្ឋាភិបាលមកធ្វើការបាញ់រះលើកងទ័ពរំដោះ ។ បន្ទាប់ពីថ្ងៃនេះមក ការប្រយុទ្ធមានសភាពស្ងប់ស្ងាត់ទៅវិញ ដោយសារកងទ័ពរដ្ឋាភិបាលរបស់លោកសេនាប្រមុខ លន់ នល់ បានដកថយទៅបោះបន្ទាយនៅស្អាងព្រែកតូច ព្រែកយុគ ត្រើយខាងកើត និងម្តុំទួលក្រសាំង (ក្រវាត់ក្រុងភ្នំពេញ) វិញ ។

ចំណែកសភាពការណ៍ក្នុងភូមិវិញ ជីតាខ្ញុំបានប្រាប់ថា កាលណោះ ចន្លោះឆ្នាំ១៩៧០ ដល់១៩៧៥ មានការផ្លោងគ្រាប់ពីសំណាក់កងទ័ពរដ្ឋាភិបាល ដែលហៅថា «កងទ័ពស្រោចស្រង់ជាតិ» មកលើតំបន់ដែលគាត់រស់ដោយគ្រាប់បានផ្លោងចេញពីព្រែកតូច ។ មានម្តងនោះ ជីតាខ្ញុំនៅចាំបានថា មានគ្រាប់ផ្លោងមួយគ្រាប់បានធ្លាក់នៅម្តុំព្រែកភេ ដែលនៅចម្ងាយប្រហែលជា ៣០០ម៉ែត ពីផ្ទះរបស់ គាត់ ធ្វើឲ្យម្ចាស់ផ្ទះម្នាក់ឈ្មោះ ក្ងីង និងប្រជាជនជាច្រើននាក់ទៀតបានស្លាប់ រងរបួស និងបណ្តាលឲ្យខូចខាតទ្រព្យសម្បត្តិ ឆេះផ្ទះ និងងាប់សត្វពាហនៈជាច្រើន ។

ថ្ងៃមួយ នៅប្រហែលជាម៉ោងប្រាំល្ងាច ក្នុងឆ្នាំ១៩៧៥ ពេលដែលលោកតាខ្ញុំកំពុងធ្វើចម្ការក្រោយភូមិ ស្រាប់តែមានគ្រាប់ផ្លោងធ្លាក់នៅក្នុងភូមិពូស្វរគ្រាំងៗ បណ្តាលឲ្យគោរបស់លោកតា លាង ដែលចងនៅក្នុងព្រែក ងាប់ក្លាមៗ ។ នៅក្នុងស្រុកភូមិជួបអសន្តិសុខ ព្រោះមានគ្រាប់ផ្លោង និងយន្តហោះស្ទាបកាត់ពីរគ្រឿងបានមកទម្លាក់គ្រាប់បែកជាញឹកញាប់ ។ ជីតាខ្ញុំបានរំឭកឲ្យដឹងទៀតថា គាត់ក៏ធ្លាប់ធ្វើជាអ្នកដឹកគ្រាប់ឲ្យទាហានរំដោះដែរ គឺដឹកចេញពីព្រែកតាឡូ ចេញទៅព្រែកឃ្លោក និងពេលខ្លះទៅដល់ទន្លេមេគង្គ ។

ក្រោយថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ ជីតាខ្ញុំបានឃើញប្រជាជនជាច្រើនត្រូវខ្មែរក្រហមជម្លៀសចេញពីភ្នំពេញមកតំបន់ដែលគាត់រស់នៅ ។ គាត់មិនដឹងថា ប្រជាជនដែលជម្លៀសមកថ្មីចំនួនប៉ុន្មាននាក់នោះទេ គ្រាន់តែដឹងថាមានចំនួនច្រើនដែលជម្លៀសមកពីភ្នំពេញ ឬហៅថាប្រជាជនថ្មី ឬ ប្រជាជន១៧មេសា ។ ដោយសារប្រជាជនថ្មីមកច្រើន អង្គការតម្រូវឲ្យអ្នកភូមិសង់ផ្ទះថ្មីសម្រាប់ប្រជាជនថ្មីនេះក្នុងមួយភូមិឲ្យបានបីផ្ទះបន្ថែមទៀត ។ ប៉ុន្តែមិនមែនជាផ្ទះធំៗទេ គឺផ្ទះដែលសង់ពីឫស្សី ប្រក់ស្លឹកត្នោត ។ ប្រជាជនថ្មីដែលនៅសេសសល់ត្រូវបានខ្មែរក្រហមបញ្ជូនឲ្យរស់នៅជាមួយអ្នកភូមិតែម្តង ។

ប្រជាជនថ្មីនេះបានរស់នៅជាមួយអ្នកភូមិបានប្រមាណជិតមួយឆ្នាំ គឺរហូតដល់ឆ្នាំ១៩៧៦ ទើបខ្មែរក្រហមជម្លៀសប្រជាជនទាំងនេះទៅតំបន់ផ្សេងទៀត ។ ចំពោះជីវភាពប្រជាជនថ្មីដែលបានរស់នៅក្នុងស្រុកភូមិរបស់ជីតា ខ្ញុំមានការលំបាកខ្លាំងជាងប្រជាជនចាស់ ។ ចំណែករបបអាហារ ដំបូងអង្គការក៏បានចែកអង្ករទៅឲ្យតែក្រោយមកមិនចែកឲ្យទៀតទេ ។ ដោយសារសម័យនោះមិនចាយលុយ ធ្វើឲ្យប្រជាជនមកពីភ្នំពេញមិនអាចយកលុយទៅទិញអ្វីបានទេ ។ ក្រោយមក ដោយសារគ្មានអ្វីហូប ប្រជាជនថ្មីបានយករបស់របរមាន ដូចជា មាស ខោអាវ និងរបស់របរប្រើប្រាស់ជាដើម យកទៅដោះដូរជាមួយប្រជាជនចាស់ យកអង្ករដំឡូងជាដើម ដើម្បីហូប ។

មកដល់ឆ្នាំ១៩៧៦ ការរស់នៅកាន់តែលំបាកទៅៗ ហើយសូម្បីតែប្រជាជនមូលដ្ឋានក៏គ្មានអាហារហូបដែរ ។ ខ្មែរក្រហមចាប់ផ្តើមបង្កើតឲ្យមានសហករណ៍រួម និងចាប់ផ្តើមជម្លៀសប្រជាជនថ្មីឲ្យទៅនៅតំបន់ថ្មីទៀត ។ ខ្មែរក្រហមបានដកយកជ្រូកដែលលោកតាខ្ញុំចិញ្ចឹមទៅធ្វើចែកគ្នាហូប ដោយប្រជាជនចាស់អាចទទួលបានសាច់ទម្ងន់មួយខាំ ចំណែកប្រជាជនថ្មីទទួលបានតែកន្លះខាំប៉ុណ្ណោះសម្រាប់មនុស្សម្នាក់ ។

នៅក្នុងសម័យខ្មែរក្រហម លោកតាខ្ញុំមិនដែលឃើញគេសម្លាប់មនុស្សទេ តែគាត់ឃើញឈ្លបចាប់មនុស្សយកទៅ ដែលភាគច្រើនយកទៅសម្លាប់ចោលនៅកោះគ និងកោះថ្មី ។ ជីតាខ្ញុំបានរំឭកប្រាប់ថា ខ្មែរក្រហមបានប្រើល្បិចសម្ងាត់ក្នុងការចាប់យកនរណាម្នាក់ទៅសម្លាប់ចោលដោយប្រាប់ឲ្យទៅជួយនេះ ជួយនោះជាដើម តែអ្នកដែលយកទៅហើយមិនឃើញត្រឡប់មកវិញទេ ។ មានប្រជាជនថ្មីជាច្រើនបានបាត់ខ្លួនដោយមិនដឹងមូលហេតុ ។ លោកតាខ្ញុំបានបន្ថែមថា មានប្រជាជនថ្មីជាច្រើនដែលមានស្រុក

កំណើតនៅក្នុងភូមិរបស់គាត់ (ហើយទៅរស់នៅស្រុកផ្សេង) ប៉ុន្តែពេលដែលខ្មែរក្រហមជម្លៀសអ្នកទាំងនោះមកវិញ គឺខ្មែរក្រហមមិនអនុញ្ញាតឲ្យរស់នៅជាមួយឪពុកម្ដាយទេ ។ ខ្មែរក្រហមបានចាត់ទុកអ្នកទាំងនោះជាអ្នករដ្ឋការ អ្នកមូលធនដែលប្រឆាំងនឹងអង្គការ ។ ជាក់ស្ដែង ប្អូនថ្លៃរបស់ជីតាខ្ញុំម្នាក់ឈ្មោះ ឡេង ចំណាន ហៅលីហាក់ ជាដើម ត្រូវខ្មែរក្រហមជម្លៀសគាត់ (ឡេង ចំណាន) និងប្រជាជនថ្មីដទៃទៀតជាច្រើនឲ្យទៅរស់នៅស្រុកមោងឫស្សី ខេត្តបាត់ដំបង ។ ក្រោយមក ទើបគាត់ដឹងថាគ្រួសាររបស់ ឡេង ចំណាន បានស្លាប់ដោយសារអត់អាហារ ។

ជីតារបស់ ខ្ញុំបានរៀបរាប់ទៀតថា ប្អូនស្រីរបស់គាត់ម្នាក់ទៀតឈ្មោះ វួចលី និងប្ដីឈ្មោះ ឈា ដែលពីសម័យ លន់ នល់ បួរមករស់នៅទីក្រុងភ្នំពេញក៏ត្រូវបានខ្មែរក្រហមជម្លៀសយកទៅដែរ តែមិនឃើញត្រឡប់មកវិញជារៀងរហូត ។ ពេលនោះ ខ្មែរក្រហមបានប្រើល្បិចថាអ្នកណាដែលមានមុខតំណែងនៅក្នុងជួររដ្ឋាភិបាលសម័យ លន់ នល់ ឲ្យទៅកាន់មុខតំណែងដូចដើមវិញ តាមពិតគឺយកទៅសម្លាប់ចោល ។

ចំពោះប្រជាជនថ្មី គឺខ្មែរក្រហមបានបង្ខំឲ្យធ្វើការដូចប្រជាជនមូលដ្ឋានដែរ ។ បើអ្នកណាមិនព្រមទៅធ្វើឬក៏ត្អូញត្អែរពីការលំបាកនោះប្រាកដជាចាប់ខ្លួនដាក់ជាមិនខានឡើយ ។ ដោយឡែកប្រជាជនមូលដ្ឋានដែលមានទ្រព្យសម្បត្តិស្ដុកស្ដម្ភ ត្រូវបានអង្គការចាត់ទុកជាអ្នកមូលធន ដោយបង្ខំឲ្យធ្វើការវេទនារលំបាក និងត្រូវបានចាប់ខ្លួនយកទៅសម្លាប់ចោលដែរ ។

មិនខុសពីប្រជាជនដទៃទៀតទេ ជីតាខ្ញុំក៏ត្រូវខ្មែរក្រហមបង្ខំឲ្យធ្វើការធ្ងន់ធ្ងរដែរ និងស្ទើរតែគ្មានពេលសម្រាក ។ នៅពេលនោះ ខ្មែរក្រហមបានបង្ខំឲ្យប្រជាជនក្នុងឃុំ រួមជាមួយជីតារបស់ខ្ញុំទៅលើកទំនប់នៅទួលក្រសាំង សព្វថ្ងៃផ្លូវជាតិលេខ២១ (ពីតាខ្មៅទៅស្អាង) ដែលតម្រូវឲ្យលើកប្រវែង៣០០ម៉ែត្រ កម្ពស់បីម៉ែត្រ បាតក្រោម២០ម៉ែត្រ និងខ្នងលើ១០ម៉ែត្រ ហើយត្រូវចំណាយរយៈពេលមួយខែកន្លះទើបហើយរួចរាល់ ។ មានកម្មករជាច្រើនបានស្លាប់ក្នុងពេលនោះដោយសារបាក់កម្លាំង និងការចាប់យកទៅសម្លាប់ ។

ក្រៅពីលើកទំនប់ ខ្មែរក្រហមបានប្រើគាត់ឲ្យធ្វើស្មៅ កាស់គល់ឈើ បោចស្មៅ ភ្ជួរស្រែ ស្ទូងស្រូវ ដឹកសំណាប ដោយមិនឲ្យមានពេលទំនេរទេ ។ នៅវេលាម៉ោងបីទៀបភ្លឺ មេកងដើរដាស់គាត់ឲ្យប្រជុំជួរ និងបេ្តជ្ញាធ្វើស្រែឲ្យបានបីតោនក្នុងមួយហិចតា បន្ទាប់មកត្រូវចុះទៅធ្វើការរហូតដល់ម៉ោង១១ ទើបឈប់ហូបបាយ រួចហើយចុះធ្វើបន្តចាប់ពីម៉ោងពីររហូតដល់ម៉ោងប្រាំ ។ ពេលខ្លះជីតាគាត់ត្រូវធ្វើរហូតដល់កណ្ដាលអធ្រាតក៏មានដែរ ។

ចំពោះរបបអាហារវិញ ជីតារបស់ខ្ញុំទទួលបានតែបាយមួយវែក ឬបបរមួយវែក ឬក៏ពោតពីរផ្លែប៉ុណ្ណោះ ។ ជីតាខ្ញុំហូបមិនដែលឆ្អែតទេ ហើយក៏មិនមានមេដឹកនាំកំពូលណាម្នាក់បានចុះមកពិនិត្យមើលដល់មូលដ្ឋានដែរ ។

លោកតាបានឲ្យដឹងទៀតថា នៅក្នុងឃុំតាលន់ មានមេដឹកនាំបីនាក់គឺ តា លក ដែលរស់នៅក្នុងភូមិចុងកោះតូច, ជូ ជាអ្នកស្រុកស្អាងភ្នំ និង តាហួត អ្នកស្រុកក្រាំងយ៉ូវ មកធ្វើជាគណៈឃុំតាលន់ ។ អ្នកទាំងបីនាក់នេះ គ្រប់គ្រងតឹងរ៉ឹង និងម៉ឺងម៉ាត់ជាទីបំផុត គឺមិនដែលយោគយល់ដល់អ្នកណាមួយឡើយ ។

នៅសម័យនោះ ថ្វីត្បិតតែខ្មែរក្រហមមិនបានជម្លៀសគ្រួសារជីតាខ្ញុំចេញពីភូមិពិតមែន ប៉ុន្តែក៏មិនអនុញ្ញាតឲ្យគាត់បានរស់នៅជាមួយកូនប្រពន្ធគាត់ដែរ ។ ក្រោយពីរបបខ្មែរក្រហមបានដួលរលំបាត់ទៅ ជីតារបស់ខ្ញុំបានបាត់បង់បងប្អូនបង្កើតប្រាំនាក់គឺឈ្មោះ ហៃ, ប៉េងលាង និង ឡោបាន ដែលត្រូវខ្មែរក្រហមយកទៅសម្លាប់ ចំណែកប្អូនប្រុសឈ្មោះ ឈៀក ធ្វើជាយោធាខ្មែរក្រហមបានបាត់ខ្លួន និងប្អូនស្រីឈ្មោះ វួចលី និងប្ដីរបស់គាត់ឈ្មោះ ឈា និងកូនប្រាំបីនាក់ទៀតបានបាត់ខ្លួនពេលខ្មែរក្រហមជម្លៀសទៅខេត្តបាត់ដំបង ។

ឆ្លងតាមបទពិសោធន៍ក្នុងរបបសាហាវឃោរឃៅនេះ ក្នុងនាមខ្ញុំជាយុវជនកម្ពុជាជំនាន់ក្រោយ មិនចង់ឲ្យរបបនេះត្រឡប់មកសាជាថ្មីទេ ។ ខ្ញុំចង់ឲ្យបង្រៀនប្រវត្តិសាស្ត្រនេះទៅដល់ក្មេងជំនាន់ក្រោយឲ្យចេះសិក្សាស្វែងយល់ ចេះត្រិះរិះពិចារណា និងថ្លឹងថ្លែងឲ្យបានល្អិតល្អន់មុននឹងធ្វើអ្វីមួយ និងត្រូវតែធ្វើការកាត់ទោសជនដៃដល់ឲ្យសមនឹងកំហុសដែលខ្លួនបានប្រព្រឹត្តដើម្បីកុំឲ្យក្មេងជំនាន់ក្រោយយកគម្រាប់តាម ។

**វ៉ែត ណៃហ៊័រ**

# បទពិសោធន៍ពុកម៉ែធ្វើឱ្យខ្ញុំរៀនប្រវត្តិសាស្ត្រ

នាងខ្ញុំឈ្មោះ កោ សែប ជានិស្សិតឆ្នាំទី២ ផ្នែកប្រវត្តិសាស្ត្រ នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ។ នាងខ្ញុំមានស្រុកកំណើតនៅភូមិអំពៅដៀប ឃុំជ្រោយនាងងួន ស្រុកស្រីស្នំ ខេត្តសៀមរាប ។ ទោះជានាងខ្ញុំមិនបានធ្លាប់ឆ្លងកាត់របបខ្មែរក្រហមក៏ដោយ ប៉ុន្តែខ្លួននាងខ្ញុំផ្ទាល់គឺជាកូនរបស់អតីតជនរងគ្រោះនៃរបបនេះតែម្តង ។

ឪពុកម្តាយនិងជីដូនជីតាខ្ញុំធ្លាប់ឆ្លងកាត់របបនេះ ហើយខ្ញុំក៏ធ្លាប់ដឹងពីទុក្ខលំបាកតាមរយៈការនិយាយរបស់គាត់ពីមុនមកដែរ ។

មុនថ្ងៃទី១៧ ខែមេសា ១៩៧៥ ឪពុកម្តាយរបស់ខ្ញុំរស់នៅភូមិអំពៅដៀប ឃុំជ្រោយនាងងួន ។ ប៉ុន្តែក្រោយមក ម្តាយព្រមទាំងមីងខ្ញុំត្រូវបានខ្មែរក្រហមជម្លៀសឲ្យទៅនៅភូមិបេង ស្រុកស្រីស្នំ ខេត្តសៀមរាប ។ ការជម្លៀសនោះបានធ្វើឲ្យគ្រួសាររបស់ម្តាយខ្ញុំរួមមានប្តី និងកូនជាទីស្រឡាញ់បានបែកបាក់ជារៀងរហូត ។

ពេលទៅដល់ភូមិបេង ប្រធានសហករណ៍តម្រូវឲ្យម្តាយនិងជីដូនខ្ញុំធ្វើការងារជាច្រើនដូចជា ក្រងស្បូវ បោចវល្លិ៍ កាប់ដងកណ្តាប ជីកដំឡូងហាល ព្រមទាំងរែកដីដំបូកយកទៅចាក់ក្នុងស្រែដើម្បីធ្វើជាជី និងស្ទូងស្រូវដោយអង្គការវាស់ដីឲ្យស្ទូងក្នុងម្នាក់ឲ្យបានបណ្តោយ១០០ម៉ែត្រ ទទឹង១០ម៉ែត្រក្នុងរយៈពេញមួយថ្ងៃ ។ ប្រសិនបើការងារនោះធ្វើមិនហើយ អង្គការនឹងមិនផ្តល់របបអាហារឲ្យទេ ព្រមទាំងត្រូវទទួលទារុណកម្មទៀត ។

ចំពោះរបបអាហារដែលអង្គការផ្តល់ឲ្យ គឺមួយថ្ងៃទទួលបានពីរពេលសម្រាប់ម្នាក់ដែលមានត្រឹមតែបបរមួយវែកប៉ុណ្ណោះ គឺបបរសដែលគ្មានបង់អំបិលលាយជាមួយកំពឹងចេក លុង ក្តួច និងកំភ្លឹង ។ នៅថ្ងៃមួយ ដោយសារតែនឹករព្ញកកូនពេក អ្នកម្តាយរបស់ខ្ញុំក៏សុំច្បាប់ប្រធានសហករណ៍ទៅលេងកូន ។ ប៉ុន្តែថ្ងៃដែលម្តាយខ្ញុំមកលេងកូន ស្រាប់តែប្រធានសហករណ៍ផ្តាច់របបអាហារគាត់មួយពេល ។ នៅអំឡុងឆ្នាំ១៩៧៧ ម្តាយរបស់ខ្ញុំមានទម្ងន់កូនទីពីរ ហើយទោះបីពេលដែលម្តាយរបស់ខ្ញុំពរពោះជិតគ្រប់ខែហើយក៏ដោយ ក៏អង្គការតម្រូវឲ្យគាត់ធ្វើការងារដូចអ្នកភូមិផ្សេងដែរ គឺអុំស្រូវ និងដកសំណាប ។ រហូតដល់ថ្ងៃម្តាយខ្ញុំឆ្លងទន្លេ ប្រធានកងមិនបានឲ្យឪពុករបស់ខ្ញុំមកមើលថែឡើយ ព្រោះម្តាយខ្ញុំនិងឪពុកខ្ញុំរស់នៅសហករណ៍ផ្សេងគ្នា ។

នៅប្រហែលឆ្នាំ១៩៧៨ យាយតាខ្ញុំបានស្លាប់ដោយសារមិនមានអាហារហូបគ្រប់គ្រាន់ ហើយនៅពេលនោះ ម្តាយរបស់ខ្ញុំក៏មិនត្រូវបានអនុញ្ញាតឲ្យទៅឃើញសាកសពគាត់ទាំងពីរដែរ ។ នៅអំឡុងឆ្នាំ១៩៧៩ ម្តាយខ្ញុំនិងមីងខ្ញុំ រួមជាមួយនឹងប្រជាជនចំនួន៨៣គ្រួសារផ្សេងទៀតត្រូវបានអង្គការជម្លៀសឲ្យទៅភូមិចុងកាល់ ស្រុកសំរោង ខេត្តឧត្តរមានជ័យ ក្នុងគោលបំណងយកទៅសម្លាប់ចោល ។ មុនពេលដឹកយកទៅ អង្គការបានយកទឹកត្នោតជូរលាយទឹកអង់ទ្រីនឲ្យផឹកដើម្បីឲ្យស្រវឹងដើម្បីងាយស្រួលក្នុងការសម្លាប់ ។ បុរសៗ អង្គការតម្រូវឲ្យដឹកមុន ចំណែកស្ត្រីតម្រូវឲ្យដឹកក្រោយ ។ អ្នកដែលបានដឹកមុនបានជួលសន្ទប់និងស្លាប់អស់ជាច្រើន ។ ចំណែកម្តាយខ្ញុំនិងមីងខ្ញុំដែលត្រូវដឹកក្រោយមានការតក់ស្លុតយ៉ាងខ្លាំង ព្រោះគាត់គិតថា តមកទៀតនឹងដល់វេនគាត់ហើយ ។ ប៉ុន្តែអ្វីដែលនឹកស្មានមិនដល់នោះគឺមិនទាន់ដល់វេនម្តាយនិងមីងខ្ញុំផងក៏កងទ័ពវៀតណាមមកទម្លាក់គ្រាប់បែក ។ ម្តាយនិងមីងខ្ញុំព្រមទាំងប្រជាជនដែលនៅសេសសល់ក៏បានរួចពីការសម្លាប់នោះ ។

បទពិសោធរបស់សមាជិកក្រុមគ្រួសារនាងខ្ញុំបានជួយបណ្តុះគំនិតខ្ញុំឲ្យកាន់តែខិតខំសិក្សាប្រវត្តិសាស្ត្រខ្មែរក្រហម ។ ខ្ញុំបានចូលធ្វើជាបុគ្គលិកស្ម័គ្រចិត្តនៅមជ្ឈមណ្ឌលឯកសារកម្ពុជាក្នុងគោលបំណងមួយគឺដើម្បីសិក្សាស្រាវជ្រាវពីឧក្រិដ្ឋកម្មនិងអំពើឃោរឃៅដែលបានកើតមានឡើងក្នុងរបបខ្មែរក្រហម ។ ខ្ញុំមិនត្រឹមតែអាចទទួលបានចំណេះដឹងពីប្រវត្តិសាស្ត្រខ្មែរក្រហមតាមរយៈការអានឯកសារនិងការស្តាប់សម្តីជនរងគ្រោះនិងជនដៃដល់ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងអាចយកចំណេះដឹងនេះទៅចែករំលែកដល់យុវជនជំនាន់ក្រោយ ដើម្បីរួមចំណែកទប់ស្កាត់របបដ៏ព្រៃផ្សៃមួយនេះកុំឲ្យរបបនេះកើតមានឡើងសាជាថ្មីម្តងទៀត ។ **កោ សែប**

# ហូបមិនគ្រប់ ម្តាយខ្ញុំធ្លាក់ខ្លួនឈឺ

ម្តាយរបស់ខ្ញុំឈ្មោះ តាំង សុខទៀង សព្វថ្ងៃគាត់មានអាយុ ៥២ឆ្នាំ រស់នៅខណ្ឌដូនពេញ ក្រុងភ្នំពេញ ។ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ គ្រួសារគាត់មានសមាជិកចំនួនប្រាំមួយរូប រួមមានឪពុកម្តាយ ជាមួយបងប្រុសបីនាក់ និងគាត់ជាកូនស្រីពៅ ។ មុនពេលរបបនេះចូលមកដល់គ្រួសាររបស់គាត់រស់នៅឃុំដីដែក ស្រុកសូត្រនិគម ខេត្តសៀមរាប ។

នៅចុងឆ្នាំ១៩៧៣ គ្រួសាររបស់គាត់ត្រូវបានជម្លៀសចេញពីស្រុកកំណើត ដោយខ្មែរក្រហមបាននិយាយថា មានខ្មាំងចូលមកវាយលុក ដូចនេះប្រជាជនទាំងអស់ត្រូវជម្លៀសចេញពីផ្ទះរយៈពេលបីថ្ងៃ ហើយគ្រួសាររបស់ម្តាយខ្ញុំបានធ្វើដំណើរទៅវត្តត្របែក ដែលមានចម្ងាយប្រមាណប្រាំបីគីឡូម៉ែត្រពីផ្ទះ ។ ប៉ុន្តែនៅអំឡុងពេលនោះ មិនដូចពាក្យសម្តីដែលខ្មែរក្រហមបានពោលនោះទេ គឺគ្រួសារគាត់ត្រូវទៅរស់នៅតាមវាលស្រែអស់រយៈពេលប្រមាណកន្លះខែ ទើបបានវិលត្រឡប់ចូលភូមិវិញដែលនៅពេលនោះខ្ញុំទើបតែមានអាយុ១២ឆ្នាំប៉ុណ្ណោះ ។

ក្រោយពីបានវិលចូលស្រុកបានបួនថ្ងៃ ខ្មែរក្រហមបានជម្លៀសអ្នកស្រុកទាំងអស់ចេញទៅម្តងទៀត ដោយប្រាប់ថាមិនចាំបាច់យករបស់របរអ្វីទៅជាមួយទេ គ្រាន់តែបីថ្ងៃនឹងអាចវិលចូលស្រុកវិញហើយ ។ ម្តងនេះ គ្រួសារម្តាយខ្ញុំ និងអ្នកស្រុកភូមិត្រូវបានជម្លៀសរហូតដល់ស្រុកព្រៃលៀនដែលមានចម្ងាយ១២គីឡូម៉ែត្រពីផ្ទះ ។ គាត់បានបន្តទៀតថា ពាក្យទាំងអស់ដែលខ្មែរក្រហមបាននិយាយសុទ្ធតែជាពាក្យកុហក ។ ក្រោយពីបានទៅស្នាក់នៅស្រុកព្រៃលៀនបានប្រមាណបីខែ អ្នកស្រុកទាំងអស់ត្រូវបានជម្លៀសបន្តទៀត គឺទៅរហូតដល់ស្រុកបិទមាស "ជាភូមិថ្មីដែលខ្មែរក្រហមសង់ខ្ទមតូចៗឲ្យស្នាក់នៅ" ។

គាត់មានទឹកមុខក្រៀមក្រំ និងចងយំ នៅពេលដែលគាត់រំឭកដល់ជីវិតរបស់បងប្អូនគាត់ ។ នៅពេលនោះ គាត់ត្រូវបង្ខំឲ្យទៅដកស្ទូង ដាំស្រូវ ដឹកឡូងឈើ និងលើកភ្លឺស្រែ ជីកប្រឡាយ និងលើកទំនប់ ។ រីឯបងប្រុសធំរបស់គាត់ត្រូវទៅជីកជញ្ជូនដីណាំលើកទំនប់ និងប្រឡាយទឹក តែក្រោយមកអ្វីដែលគ្រួសារគាត់នឹកស្មានមិនដល់នោះគឺ បងប្រុសធំរបស់គាត់ត្រូវបានកងឈ្លបយល់ច្រឡំថាគិញសម្ងាត់ ក៏យកដើមឫស្សីវាយគាត់រហូតដល់ស្លាប់រួចយកទៅកប់នៅឯចុងភូមិ ។ ចំណែកបងទីពីត្រូវបានជម្លៀសឲ្យទៅស្រុកវត្តលង់ព្រលឹង ចម្ងាយប្រមាណ១៦គីឡូម៉ែត្រពីស្រុកបិទមាសដើម្បីលើកទំនប់ ជីកប្រឡាយ និងកាប់ព្រៃ ដោយទទួលបាន អង្ករតែមួយស្លាបព្រា សម្រាប់មនុស្សមួយនាក់ក្នុងមួយថ្ងៃ ។ នៅខណៈនោះ បងទីបីរបស់គាត់ត្រូវអង្គការចាត់តាំងឲ្យទៅដាំបន្លែនៅឯកងចល័ត និងធ្វើការងារធ្ងន់ផ្សេងៗទៀត ។

ដោយសារការហូបមិនគ្រប់គ្រាន់ បានធ្វើឲ្យម្តាយខ្ញុំធ្លាក់ខ្លួនឈឺ និងមានជំងឺគ្រុនចាញ់ និងស្គមរីងរៃ នៅសល់តែស្បែកនិងឆ្អឹង ។ ម្តាយខ្ញុំប្រាប់ថា នៅពេលដែលខ្មែរក្រហមជម្លៀសដំបូង គឺគាត់មានអាហារហូបគ្រប់គ្រាន់ដោយសារបានយកអាហារតាមខ្លួន តែក្រោយមកត្រូវបានខ្មែរក្រហមដកហូត និងបង្ខំអោយអ្នកស្រុកទាំងអស់ធ្វើការធ្ងន់ធ្ងរ និងឲ្យហូបនៅសហករណ៍ ដែលមានតែបបររាវប៉ុណ្ណោះ ។ ក្រោយពីរបបឃោរឃៅនោះដួលរលំ ម្តាយខ្ញុំបាត់បង់បងប្រុសរបស់គាត់ ហើយរឿងនេះបានធ្វើឲ្យគាត់ឈឺចាប់រហូតដល់សព្វថ្ងៃនេះ ។ **គីម ឡេង**

- ◆ **និយាយពីការរស់នៅក្នុងសម័យខ្មែរក្រហម គឺនិយាយពីការផ្សះផ្សា អប់រំកូនចៅឱ្យអត់ឱន អធ្យាស្រ័យគ្នា**
- ◆ **រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ គឺរៀនពីការទប់ស្កាត់អំពើប្រល័យពូជសាសន៍**

# ដំណឹងសួររកបងប្អូន

នាងខ្ញុំឈ្មោះ លាង រស្មី អាយុ៥៨ឆ្នាំ ពីមុនធ្វើការខាងឱសថការី ឥឡូវនៅផ្ទះ មានប្តីធ្វើការខាងឱសថការី ។ សព្វថ្ងៃ នាងខ្ញុំរស់នៅផ្ទះលេខ561Eo ផ្លូវកម្ពុជាក្រោម សង្កាត់ផ្សារដេប៉ូ៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។ នាងខ្ញុំមានក្មួយស្រីម្នាក់ឈ្មោះ ទឹម វីណែត ធ្វើការនៅមន្ទីរអប់រំខេត្តព្រៃវែង និងប្តីឈ្មោះ ឡេវ ពិរុន សព្វថ្ងៃធ្វើការនៅមន្ទីរសង្គមកិច្ចខេត្តព្រៃវែង ដែលត្រូវជាក្មួយ និងកូនប្រសារលោក លាង លក្ខិណា ។

យើងខ្ញុំទាំងប្អូននាក់សូមប្រកាសរកឈ្មោះ លាង លក្ខិណា ហៅ ម៉ារីន បច្ចុប្បន្នមានអាយុប្រហែល៦៥ឆ្នាំ ដែលត្រូវជាបងប្រុស និងឪពុកដែលបានបាត់ខ្លួននៅក្នុងសម័យខ្មែរក្រហមនៅចុងឆ្នាំ១៩៧៨ ។ មុនឆ្នាំ១៩៦៩ គាត់ជាសាស្ត្រាចារ្យនៅសាលាយុគន្ធរ រហូតដល់ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ទើបខ្មែរក្រហមជម្លៀសចេញពីក្រុងភ្នំពេញ ។ ក្រោយមកទើបយើងដឹងថា ខ្មែរក្រហមចាប់ខ្លួនគាត់ រួចបញ្ជូនទៅឃុំឃាំងនៅឃុំព្រែកពោធិ៍ ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម ។ អ្នកធ្លាប់ជាប់ឃុំឃាំងជាមួយគាត់បានប្រាប់យើងនៅចុងឆ្នាំ១៩៧៨ថា អង្គការបានដោះលែងគាត់ ប៉ុន្តែយើងមិនដែលទទួលដំណឹងពីគាត់ទេ ។

អាស្រ័យហេតុនេះ ប្រសិនបើបងប្អូនណាបានស្គាល់ ឬឮឈ្មោះ លាង លក្ខិណា សូមទាក់ទងមកនាងខ្ញុំតាមរយៈទូរស័ព្ទលេខ ០ ១២ ២៨៦ ៤៣៧ ឬ មជ្ឈមណ្ឌលឯកសារកម្ពុជា ផ្ទះលេខ៦៦ មហាវិថីព្រះសីហនុ រាជធានីភ្នំពេញ ។ ***សូមអរគុណ!***

---

# ដំណឹងស្វែងរកបងប្អូន

នាងខ្ញុំឈ្មោះ លឹម គៀង អាយុ៤៣ឆ្នាំ មានស្រុកកំណើតនៅទីក្រុងភ្នំពេញ បច្ចុប្បន្នរស់នៅភូមិអំពៅដៀប ឃុំជ្រោយនាងងួន ស្រុកស្រីស្នំ ខេត្តសៀមរាប ។ នាងខ្ញុំមានឪពុកឈ្មោះ លឹម ដាថៃ (ស្លាប់) និងម្តាយឈ្មោះ មុយ ជូវ (ស្លាប់) ហើយមានបងប្អូនបង្កើតចំនួន៦នាក់គឺៈ ១) លឹម ស្រេង ភេទប្រុស (បាត់ខ្លួន) ២) លឹម ឃឹម ភេទប្រុស (បាត់ខ្លួន) ៣) នាងខ្ញុំ (លឹម គៀង) ៤) លឹម ដេង ភេទប្រុស (ស្លាប់ដោយជំងឺក្នុងសម័យខ្មែរក្រហម) ៥) លឹម អ៊ុយ ភេទប្រុស (ស្លាប់ដោយជំងឺក្នុងសម័យខ្មែរក្រហម) ៦) លឹម ស៊ាក់ ភេទប្រុស (ស្លាប់ដោយជំងឺក្នុងសម័យខ្មែរក្រហម) ។

នាងខ្ញុំសូមប្រកាសរកបងប្រុសទាំងពីរខាងលើឈ្មោះ លឹម ស្រេង និង លឹម ឃឹម ។ យើងទាំងបីនាក់បានបែកគ្នាក្រោយឆ្នាំ១៩៧៩ ពេលធ្វើដំណើរចេញពីស្ពានស្រែង ក្នុងគោលបំណងត្រឡប់មកទីក្រុងភ្នំពេញដែលជាស្រុកកំណើតវិញ ។ លុះដើរមកដល់ស្រុកក្រឡាញ់ ខេត្តសៀមរាប បងប្រុសទាំងពីររបស់ខ្ញុំបានសុំអ្នកបររទេះគោផ្ញើខ្ញុំឲ្យជិះជាមួយ ដោយសារតែខ្ញុំពិការជើងទាំងពីរតាំងពីកំណើត ។ ពេលធ្វើដំណើរយើងក៏បែកគ្នា ហើយក៏ខ្ញុំចុះពីរទេះគោចាំផ្លូវគាត់តែមិនឃើញ ។ ក្រោយមកក៏បានជួបនឹងមីងម្នាក់មានចិត្តអាណិតខ្ញុំ ក៏យកខ្ញុំទៅរស់នៅជាមួយនៅភូមិអំពៅដៀប ឃុំជ្រោយនាងងួន ស្រុកស្រីស្នំ ខេត្តសៀមរាប រហូតដល់បច្ចុប្បន្ន ។ ដោយសារតែពេលនោះនាងខ្ញុំមានអាយុត្រឹមតែប្រាំបួនឆ្នាំ ហេតុនេះខ្ញុំមិនបានចាំអាយុបងប្រុសទាំងពីរនោះទេ ។

ប្រសិនបើបងប្អូនណាបានស្គាល់ ឬឮឈ្មោះ លឹម ស្រេង និង លឹម ឃឹម សូមទាក់ទងមកនាងខ្ញុំតាមទូរស័ព្ទៈ ០៩៧ ៤ ១៣៤ ១៤៥ ឬ មជ្ឈមណ្ឌលឯកសារកម្ពុជា ផ្ទះលេខ៦៦ មហាវិថីព្រះសីហនុ រាជធានីភ្នំពេញ ទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ។ ***សូមអរគុណ!***

# សៀវភៅរំឭកវិញ្ញាណក្ខន្ធអ្នកដែលបានស្លាប់ នៅក្នុងរបបខ្មែរក្រហម

មជ្ឈមណ្ឌលឯកសារកម្ពុជា គ្រោងនឹងបោះពុម្ពផ្សាយនូវសៀវភៅមានកត់ត្រាឈ្មោះរបស់អ្នកដែលស្លាប់បាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហម ។ កន្លងមក មជ្ឈមណ្ឌលឯកសារកម្ពុជាបានចងក្រងនូវឈ្មោះអ្នកដែលស្លាប់ជាង១លាននាក់រួចមកហើយ ។ ប្រសិនបើលោកយាយ លោកតា អ៊ំ ពូ មីង ប្រាថ្នាចង់ឲ្យឈ្មោះសមាជិកក្រុមគ្រួសារដែលបានស្លាប់បាត់បង់ជីវិតមាននៅក្នុងសៀវភៅនេះ សូមទាក់ទងមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជាតាមរយៈ អេង កុកថាយ ទូរស័ព្ទលេខ ០១២ ៩៥៥ ៨៥៨ ឬ អ៊ីម៉ែល ៖ truthkokthay@dccam.org ឲ្យបានឆាប់រហ័សតាមពេលវេលាដែលអាចធ្វើទៅបាន ។










***សូមផ្តល់ព័ត៌មានដូចខាងក្រោម៖***

១) ឈ្មោះអ្នកប្រកាសប្រាប់, ២) តើមានបងប្អូនបង្កើតរួមទាំងឪពុកម្តាយស្លាប់ប៉ុន្មាននាក់នៅក្នុងសម័យខ្មែរក្រហម? ៣) ឈ្មោះអ្នកស្លាប់, ៤) ភេទអ្នកស្លាប់, ៥) អាយុអ្នកស្លាប់ (បើអាចចាំបាន), ៦) ត្រូវជាអ្វីនឹងអ្នកប្រកាស (ឧទាហរណ៍៖ ឪពុក ម្តាយ បងប្រុស ប្អូនប្រុស បងស្រី ឬប្អូនស្រី), ៧) សាច់រឿងទាក់ទងនឹងការស្លាប់ (ឧទាហរណ៍ ៖ ស្លាប់នៅទីណា? មូលហេតុអ្វី?), ៨) វត្ថុតាងទាក់ទងនឹងអ្នកស្លាប់ (ឧទាហរណ៍៖ រូបថត ឯកសារ ឬវត្ថុផ្សេងៗ), ៩) ព័ត៌មានសម្រាប់មជ្ឈមណ្ឌលទាក់ទង (ឧទាហរណ៍៖ លេខទូរស័ព្ទ អាស័យដ្ឋាន) ។

***ប្រសិនបើចង់ស្វែងរកអ្នកដែលបាត់ខ្លួនសូមផ្តល់ព័ត៌មានខាងក្រោម៖***

១) ឈ្មោះអ្នកបាត់ខ្លួន, ២) ភេទ, ៣) អាយុ, ៤) ត្រូវជាអ្វី, ៥) សាច់រឿងទាក់ទងនឹងការបែកគ្នា, ៦) វត្ថុតាងទាក់ទងនឹងអ្នកបាត់ខ្លួន (ឧទាហរណ៍៖ រូបថត ឯកសារ ឬវត្ថុផ្សេងៗ) ។

ដើម្បីយុត្តិធម៌និងការចងចាំ
ដែលជាមូលដ្ឋានដ៏សំខាន់ក្នុងការផ្សះផ្សាជាតិ

ឧបត្ថម្ភការបោះពុម្ពផ្សាយដោយរដ្ឋាភិបាល សហរដ្ឋអាមេរិក
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មានលេខ ០២៩១ពម.៩៩ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

**មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ការិយាល័យព័ត៌មានសាធារណៈ**
ផ្ទះលេខ ៦៦, មហាវិថីព្រះសីហនុ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ ៖ (៨៥៥) ២៣ ២១១ ៨៧៥ ទូរសារ ៖ (៨៥៥) ២៣ ២១០ ៣៥៨

DC-Cam/PIR : #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ Fax: (855) 23 210 358 ◆ dccam@online.com.kh ◆ www.dccam.org.
A magazine of the Documentation Center of Cambodia: Searching for the truth. ◆ Number 164, August 2013 ◆ Funded by USA.
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No.0291 P.M/99, 2 August 1999.